**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Science Economiqes**

**Royal University of Law and Economics**

## សារណាបញ្ចប់ការសិក្សា

# កិច្ចការពារម៉ាក និងយន្តការដោះស្រាយ អំពើរំលោភបំពាននៃម៉ាកនៅកម្ពុជា

ស្រាវជ្រាវ ពីថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយនិស្សិតៈ

លោក **ម៉ៅ លាភ**

កញ្ញា **លាប សុគន្ធ**

សាស្ត្រាចារ្យណែនាំ

លោក **ទេព សុខ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Science Economiqes**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# កិច្ចការពារម៉ាក និងយន្តការដោះស្រាយ អំពើរំលោភបំពាននៃម៉ាកនៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយនិស្សិត៖

លោក **ម៉ៅ លាភ**

កញ្ញា **លាប សុគន្ធ**

សាស្ត្រាចារ្យណែនាំ

លោក **ឆេព សុខ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរនាក់ឈ្មោះ **មៅ លាភ** និង **លាប សុគន្ធ** ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី ១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ

លោកឪពុក **ស៊ាម ម៉ៅ** និងអ្នកម្តាយ **ឡុង ថេង** ព្រមទាំង

លោកឪពុក **រស់ លាភ** និងអ្នកម្តាយ **នេត្រ សារ៉ុី** ដែលលោកជាអ្នកផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ថ្នាក់ថ្នមរូប យើងខ្ញុំតាំងពីពេលចាប់កំណើតរហូតមកដល់សព្វថ្ងៃនេះដោយក្តីស្រលាញ់ និងការសណ្តោសប្រណី ជាពិសេសគឺជាគ្រូដែលបង្ហាត់បង្រៀន និងបានផ្តល់នូវការអប់រំ ទូន្មានដំបូងបំផុតនៃជីវិតរបស់យើងខ្ញុំទាំងពីរ លើសពីនេះទៅទៀតលោកទាំងទ្វេរ តែងតែជួយជ្រោមជ្រែងគ្រប់សព្វបែបយ៉ាង ទាំងស្មារតី និងសម្ភារៈសម្រាប់ផ្គត់ផ្គង់ដល់ការរៀនសូត្ររបស់យើងខ្ញុំតាំងពីថ្នាក់បឋមសិក្សារហូតដល់បញ្ចប់ការសិក្សាថ្នាក់ បរិញ្ញាបត្រនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ពុំដែលត្អូញត្អែរពីភាពនឿយហត់បន្តិចណាសោះឡើយ ទាំងនេះគឺកម្លាំងដ៏អស្ចារ្យមួយដែលឋិតនៅពីក្រោយភាពជោគ ជ័យរបស់យើងខ្ញុំទាំងពីរក្នុងពេលបច្ចុប្បន្ននេះផងដែរ។

យើងខ្ញុំសូមគោរពថ្លែងអំណរគុណផងដែរចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស និងលោក លោកស្រី សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ទាំងអស់ដែលបានយកចិត្តទុកដាក់ចំណាយពេលវេលា និងកម្លាំងកាយកម្លាំងចិត្ត ញើសឈាមដ៏មានតម្លៃរបស់អស់លោកដើម្បីបណ្តុះបណ្តាល និងបំពេញបន្ថែមនូវពុទ្ធិដល់រូបយើងខ្ញុំ ក៏ដូចជាមិត្តនិស្សិតទាំងអស់ដែលសិក្សានៅក្នុងសាកលវិទ្យាល័យនេះ គ្រប់មុខវិជ្ជាតាំងពីថ្នាក់សិក្សាមូលដ្ឋាន រហូតដល់បញ្ចប់ការសិក្សា។

យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **លោកសាស្ត្រាចារ្យ ទេព សុខ** ដែលលោកសាស្ត្រាចារ្យបានទទួលយកនូវការដឹកនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ ដោយលោកបានចំណាយនូវពេលវេលាដ៏មមាញឹក និងមានតម្លៃ ថែមទាំងចំណាយកម្លាំងកាយ និងកម្លាំងចិត្តក្នុងបណ្តុះបណ្តាល និងពន្យល់ណែនាំផ្តល់ជាចង្កៀងដើម្បីបំភ្លឺនូវគំនិតដល់យើងខ្ញុំក្នុងរយៈពេលកន្លងមកនេះ ជាពិសេសបានចំណាយពេលយ៉ាងច្រើនដើម្បីកែតម្រូវកិច្ចការសារណាមួយនេះ រហូតយើងខ្ញុំបានចងក្រងនូវសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រមួយនេះឡើងដោយភាពជោគជ័យ។

ជាទីបញ្ចប់យើងខ្ញុំទាំងពីររូប សូមគោរពជូនពរដល់អស់ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រី សាស្ត្រាចារ្យ** និងសិស្សនិស្សិតទាំងអស់ សូមឲ្យបានជួបប្រទះតែនូវពុទ្ធពរទាំងបួនប្រការគឺៈ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីយើងខ្ញុំបានធ្វើការសិក្សាយ៉ាងលម្អិតអស់រយៈពេលបួនឆ្នាំទៅលើផ្នែកនីតិសាស្ត្រ នៅក្រោម ការបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ពីសំណាក់ លោក លោកស្រី សាស្ត្រាចារ្យទាំងអស់ជាហេតុនាំឲ្យយើងខ្ញុំទាំងពីរនាក់ទទួលបាននូវចំណាត់ល្អ ហើយត្រូវបានសាកលវិទ្យាល័យតម្រូវឲ្យយើងខ្ញុំសរសេរសារណាដើម្បីបញ្ជាក់ ក៏ដូចជាបង្ហាញពីសមត្ថភាពចំណេះដឹងដែលទទួលបានពីការសិក្សារៀនសូត្រកន្លងមកនេះ។ សារណាមួយក្បាលនេះ គឺជាសមទ្ធិផលមួយដែលកើតឡើងពីការខិតខំប្រឹងប្រែង ព្យាយាមក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ហើយក៏ជាស្នាដៃមួយដើម្បីបន្សល់ទុកមុននឹងឈានជើងចាកចេញពីសាកលវិទ្យាល័យនាពេលខាងមុខនេះ និងដើម្បីជាគុណប្រយោជន៍សម្រាប់សិស្ស និស្សិតជំនាន់ក្រោយៗក្នុងការសិក្សាស្រាវជ្រាវបន្ត។

គ្រប់មុខវិជ្ជាដែលយើងខ្ញុំបានរៀន គឺសុទ្ធតែជាមុខវិជ្ជាសំខាន់ៗសម្រាប់អនុវត្តក្នុងសង្គមយើងបច្ចុប្បន្ននេះ។ ប្រទេសកម្ពុជាយើងសព្វថ្ងៃជាប្រទេសដែលកំពុងអភិវឌ្ឍន៍ទើបបណ្តាលឲ្យមានការផ្តោតអារម្មណ៍យ៉ាងខ្លាំងទៅលើមុខវិជ្ជានីតិកម្មសិទ្ធិបញ្ញា។ កម្មសិទ្ធិបញ្ញាជាឧបករណ៍មួយដ៏សំខាន់សម្រាប់ពង្រីកវិស័យពាណិជ្ជកម្មដើម្បីទាក់ទាញវិនិយោគជាតិ និងអន្តរជាតិ។ កម្មសិទ្ធិបញ្ញាគឺទាក់ទងទៅនឹងមូលហេតុចំបងពីរគឺៈ **(ទី១)** បុគ្គលដែលបានខិតខំប្រឹងព្យាយាមក្នុងការបង្កើតគំនិតថ្មី និងអនុវត្តគំនិតនោះដើម្បីបង្កើតជាស្នាដៃដែលអាចទទួលបាននូវផលប្រយោជន៍ពីលទ្ធផលនៃគំនិតរបស់ខ្លួន។ **(ទី២)** នៅពេលបុគ្គលដែលបានបង្កើតស្នាដៃចេញពីគំនិតប្រាជ្ញារបស់របស់ខ្លួនរួចហើយត្រូវទទួលសិទ្ធិការពារលើការខិតខំប្រឹងប្រែងផ្នែកប្រាជ្ញារបស់គាត់ បើមិនដូច្នោះទេ នឹងមានការរំលោភបំពានទៅលើស្នាដៃនោះជាក់ជាមិនខាន។ ដោយសារនីតិកម្មសិទ្ធិបញ្ញា គឺជាមុខវិជ្ជាដ៏សំខាន់ ជាហេតុផលធ្វើឲ្យយើងខ្ញុំបានជ្រើសរើសយកការស្រាវជ្រាវសារណាមួយនេះឡើងក្រោមប្រធានបទស្តីអំពី ‶ **កិច្ចការពារម៉ាក និងយន្តការដោះស្រាយអំពើរំលោភបំពាននៃម៉ាកនៅកម្ពុជា** ″ **(ចាប់ពីឆ្នាំ ១៩៩៩ ដល់ឆ្នាំ ២០២០)**។

ទោះបីជាយ៉ាងណាក៏ដោយ យើងខ្ញុំក៏សូមធ្វើការខន្តីអភ័យទោសនូវរាល់ចំណុចខ្វះខាតដូចជាពាក្យពេចន៍ អត្ថន័យ ឬកំហុសឆ្គងអចេតនាណាមួយដែលមាននៅក្នុងសារណាមួយនេះទុកជាមុន ព្រោះយើងខ្ញុំជឿជាក់ថាៈ ពិតជាគ្មានអ្វីដែលអាចល្អឥតខ្ចោះបាននោះឡើយ ដូចនេះយើងខ្ញុំត្រូវតែទទួលស្គាល់នូវកំហុស និងទទួលយកនូវការកែតម្រូវតាមរយៈការផ្តល់ជាមតិយោបល់ រិះគន់ដើម្បីភាពស្ថាបនារបស់មិត្ត និស្សិត អ្នកអានទាំងអស់ ដើម្បីឲ្យស្នាដៃមួយនេះកាន់តែមានភាពល្អប្រសើរឡើង។

# មាតិកា

ទំព័រ

សេចក្ដីផ្ដើម ........ ១

## ជំពូកទី១
## សញ្ញាណគតិយុត្តនៃម៉ាក

ផ្នែកទី១៖ និយមន័យ និងប្រភេទនៃម៉ាក ........ ៣

កថាភាគទី១៖ និយមន័យ ........ ៣

១. ម៉ាកជាសញ្ញាដែលឃើញ ........ ៣

១.១.ម៉ាកដែលមើលឃើញ ........ ៣

១.២. ម៉ាកដែលមើលមិនឃើញ ........ ៣

២. ម៉ាកអាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវារបស់សហគ្រាសនីមួយៗ ........ ៣

២.១. ម៉ាកសម្គាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវា ........ ៣

២.២. សហគ្រាសនីមួយៗ ........ ៤

កថាភាគទី២៖ ប្រភេទផ្សេងៗនៃម៉ាក ........ ៤

១. ម៉ាកធម្មតា (Traditional Mark) ........ ៤

១.១. ពាក្យ ឬឈ្មោះបុគ្គល អក្សរ ឬលេខ ........ ៤

១.២. បង្គុំនៃពណ៌ និង សញ្ញា ........ ៤

២. ម៉ាកមិនធម្មតា (Non-traditional Mark) (ទំនើប) ........ ៤

៣ . ពាណិជ្ជនាម ម៉ាកសមូហភាព និង ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ........ ៥

៣.១. ម៉ាកពាណិជ្ជនាម (Trade Name) ........ ៥

៣.២. ម៉ាកសមូហភាព ........ ៥

៣.៣. ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ........ ៦

ផ្នែកទី២៖ ម៉ាកដែលមិនអាចចុះបញ្ជីបាន ........ ៦

កថាភាគទី១៖ ម៉ាកដែលធ្វើឲ្យមានការភ័ន្តច្រឡំ ........ ៦

១. ម៉ាកដែលមិនសម្គាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវា ........ ៦

១.១. លក្ខណៈខុសគ្នានៃទំនិញ ឬសេវា ........ ៧

១.២. ដូចគ្នានឹងម៉ាករបស់ម្ចាស់ផ្សេង ........ ៧

២. ម៉ាកដែលធ្វើឲ្យភ័ន្តច្រឡំ ........ ៩
២.១. ភ័ន្តច្រឡំនឹងប្រភពភូមិសាស្ត្រ ........ ៩
២.២. ភ័ន្តច្រឡំជាមួយម៉ាកល្បី ........ ៩
**កថាភាគទី២៖ ម៉ាកដែលប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ និងសញ្ញានៃស្ថាប័នរដ្ឋ** ........ ១០
១. ម៉ាកដែលប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ ........ ១០
១.១. សណ្ដាប់ធ្នាប់សាធារណៈ ........ ១១
១.២. សីលធម៌ ឬប្រពៃណីល្អរបស់ជាតិ ........ ១១
២. ម៉ាកដែលប៉ះពាល់ដល់សញ្ញានៃស្ថាប័នរដ្ឋ ........ ១១
២.១. ស្ថាប័នរដ្ឋ ឬអង្គការ ........ ១២
២.២. សញ្ញានៃស្ថាប័នរដ្ឋ ឬអង្គការ ........ ១២

## ជំពូកទី២

## នីតិវិធីក្នុងការចុះបញ្ជីម៉ាក

**ផ្នែកទី១៖ ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក** ........ ១៤
**កថាភាគទី១៖ លក្ខខណ្ឌគ្រឹះ** ........ ១៤
១. នីត្យានុកូលភាពនៃម៉ាក ........ ១៤
២. លក្ខណៈខុសប្លែកគ្នានៃម៉ាក ........ ១៥
៣. ភាពទំនេរនៃម៉ាក ........ ១៥
**កថាភាគទី២៖ លក្ខខណ្ឌទម្រង់** ........ ១៦
១. ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ........ ១៦
១.១. ការដាក់ពាក្យស្នើសុំ ........ ១៦
១.២. ការបំពេញគំរូពាក្យស្នើសុំ ........ ១៦
២. ការត្រួតពិនិត្យលើពាក្យស្នើសុំ ........ ១៧
២.១. ការទទួលយកពាក្យស្នើសុំ និង ការចេញលិខិតទទួលស្គាល់ការដាក់ពាក្យ ........ ១៧
២.២. ការបដិសេធ និងការកែតម្រូវពាក្យស្នើសុំចុះបញ្ជី ........ ១៨
**ផ្នែកទី២៖ ការត្រួតពិនិត្យខ្លឹមសារម៉ាក** ........ ១៨
**កថាភាគទី១៖ ការត្រួតពិនិត្យខ្លឹមសារដោយជោគជ័យ** ........ ១៨
១. លិខិតទទួលស្គាល់ការចុះបញ្ជីម៉ាក ........ ១៨

២. កាតព្វកិច្ចបង់ថវិកា ........ ១៩
កថាភាគទី២៖ ការត្រួតពិនិត្យខ្លឹមសារដែលមានបញ្ហា ........ ១៩
១. ការកែតម្រូវ ........ ១៩
២. នីតិវិធីដំណាក់កាលសវនាការ ........ ២០
៣. នីតិវិធីដំណាក់កាលក្រុមប្រឹក្សាដោះស្រាយបណ្ដឹងតវ៉ា ........ ២០
៤. បណ្ដឹងទៅតុលាការមានសមត្ថកិច្ច ........ ២១
ផ្នែកទី៣៖ ការចេញវិញ្ញាបនបត្រចុះបញ្ជីម៉ាក ........ ២១
កថាភាគទី១៖ ការបោះផ្សាយនៅក្នុងព្រឹត្តិបត្រផ្លូវការ ........ ២១
១. ទម្រង់នៃព្រឹត្តិបត្រផ្លូវការ ........ ២២
២. អានុភាពនៃព្រឹត្តិបត្រផ្លូវការ ........ ២២
កថាភាគទី២៖ បណ្ដឹងជំទាស់ម៉ាកដែលបានចុះបញ្ជីរួចហើយ ........ ២៣
១. មូលដ្ឋាននៃបណ្ដឹងជំទាស់ ........ ២៣
២. នីតិវិធីក្នុងការបណ្ដឹងជំទាស់ ........ ២៤
កថាភាគទី៣៖ រយៈពេលការពារម៉ាកដែលបានចុះបញ្ជីជាស្ថាពរ ........ ២៥
១. រយៈពេលការពារម៉ាកដែលបានចុះបញ្ជី ........ ២៥
២. ការសុំចុះបញ្ជីម៉ាកសាជាថ្មី ........ ២៥

## ជំពូកទី៣
## សិទ្ធិនៃម្ចាស់ម៉ាក ការរំលោភម៉ាក និងយន្តការដំណោះស្រាយ

ផ្នែកទី១៖ សិទ្ធិទទួលបានពីការចុះបញ្ជីម៉ាក ........ ២៧
កថាភាគទី១៖ ការធ្វើអាជីវកម្ម ........ ២៧
១. ការប្រើប្រាស់ម៉ាកត្រូវមានការយល់ព្រមពីម្ចាស់ម៉ាក ........ ២៧
២. សិទ្ធិប្ដឹងទៅតុលាការ ........ ២៧
កថាភាគទី២៖ ការផ្ដល់អាជ្ញាប័ណ្ណចំពោះម៉ាក ........ ២៨
១. កិច្ចសន្យាទូទៅ (កិច្ចសន្យាអនុប្បទាន) និងកិច្ចសន្យាអាជ្ញាប័ណ្ណ ........ ២៨
១.១. កិច្ចសន្យាទូទៅ (កិច្ចសន្យាអនុប្បទាន) ........ ២៨
១.២. កិច្ចសន្យាអាជ្ញាប័ណ្ណ ........ ២៩
២. លក្ខណៈពិសេសនៃកិច្ចសន្យាអាជ្ញាប័ណ្ណចំពោះម៉ាក ........ ៣៣

២.១. ការត្រួតពិនិត្យដោយមានប្រសិទ្ធភាព ........ ៣៣
២.២. លក្ខណៈផ្សេងទៀតនៃកិច្ចសន្យាអាជ្ញាប័ណ្ណ ........ ៣៣
**ផ្នែកទី២៖ ការរំលោភលើម៉ាក និងយន្តការដោះស្រាយ** ........ ៣៣
**កថាភាគទី១៖ ការរំលោភលើម៉ាក** ........ ៣៣
**១. ការប្រើប្រាស់ម៉ាកដោយគ្មានការយល់ព្រមពីម្ចាស់ម៉ាក** ........ ៣៤
**២. ការក្លែងបន្លំម៉ាក** ........ ៣៥
២.១. ការផលិតឡើងវិញនៃម៉ាក ........ ៣៥
២.២. ការធ្វើត្រាប់តាមម៉ាក ........ ៣៥
**៣. ការច្រកផលិតផល** ........ ៣៦
**កថាភាគទី២៖ យន្តការដំណោះស្រាយ** ........ ៣៦
**១. វិធានការរដ្ឋបាល** ........ ៣៦
១.១. វិធានការតាមមាត់ច្រកព្រំដែន ........ ៣៦
១.២. យន្តការផ្ទៃក្នុងនៃក្រសួងពាណិជ្ជកម្ម ........ ៤០
**២. ដំណោះស្រាយតាមផ្លូវតុលាការ** ........ ៤៥
២.១. វិធានការបណ្តោះអាសន្ន ........ ៤៥
២.២. តុលាការមានសមត្ថកិច្ច និងទោសបញ្ញត្តិនៃការរំលោភម៉ាក ........ ៤៧
**សេចក្តីសន្និដ្ឋាន** ........ ៥២
**អនុសាសន៍** ........ ៥៥
**ឯកសារយោង** ........ ៥៦
**ឧបសម្ព័ន្ធ** ........ ៥៧

# សេចក្តីផ្តើម

# សេចក្តីផ្តើម

នៅពេលបច្ចុប្បន្នការប្រកួតប្រជែងនៅលើទីផ្សារកំពុងតែមានសន្ទុះយ៉ាងខ្លាំងក្លាស្ទើរគ្រប់វិស័យ ជាពិសេសប្រទេសដែលមានរបបទីផ្សារសេរី។ ការប្រកួតប្រជែងនេះបើពិនិត្យលើទិដ្ឋភាពពាណិជ្ជកម្មវិញ សូម្បីតែអង្គការពាណិជ្ជកម្មពិភពលោក (WTO) ក៏មានគោលដៅបង្កើតឲ្យមានបែបបទនៃការប្រកួតប្រជែងនៅក្នុងទីផ្សារសេរីផងដែរ។ យើងឃើញថារាល់ទំនិញ ឬសេវាគឺមានលក្ខណៈសម្បូរបែបណាស់ដោយទំនិញ ឬសេវាខ្លះដូចគ្នា ឬប្រហាក់ប្រហែលគ្នាដែលជាហេតុនាំឲ្យមានផលវិបាកមួយក្នុងការញែកឲ្យដាច់ពីគ្នានៃទំនិញ ឬពីសេវារបស់សហគ្រាសមួយទៅនឹងសហគ្រាសមួយផ្សេងទៀត។ ហេតុនេះហើយម្ចាស់ទំនិញ ឬសេវាទាំងនោះត្រូវធ្វើយ៉ាងណាដើម្បីឲ្យអតិថិជនរបស់ខ្លួនរួមទាំងមនុស្សទូទៅមានភាពងាយស្រួលក្នុងការកត់សម្គាល់ថា: ទំនិញ ឬសេវាទាំងនោះគឺជារបស់ខ្លួន។ តាមរយៈនេះបានធ្វើឲ្យម្ចាស់ទំនិញ ឬសេវាត្រូវតែធ្វើសញ្ញាមួយយ៉ាងច្បាស់លាស់ដើម្បីសម្គាល់ទៅលើទំនិញ ឬសេវារបស់ខ្លួនឲ្យសាធារណៈជនអាចសម្គាល់បានថា: ទំនិញ ឬសេវាទាំងនោះ គឺជាទំនិញ ឬសេវារបស់ខ្លួន ដែលសញ្ញាសម្គាល់នេះត្រូវបានឲ្យឈ្មោះថា "**ម៉ាក**"។

ស្របពេលដែលម៉ាកត្រូវបានគេពេញនិយមយកមកប្រើប្រាស់ច្រើនសម្រាប់ដាក់នៅលើទំនិញ ឬសេវាដើម្បីសម្គាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវានៃសហគ្រាសនីមួយៗពេលនោះយើងឃើញថា: មានម៉ាកខ្លះដូចគ្នា ហើយម៉ាកខ្លះទៀតស្ទើតែដូចគ្នាដែលជាហេតុនាំឲ្យមានការច្រឡំគ្នា។ តើមានអ្វីកើតឡើងប្រសិនបើម៉ាកដូចគ្នា ឬប្រហាក់ប្រហែលគ្នា? ជាការពិតណាស់បញ្ហានឹងកើតមានឡើងទាំងចំពោះអ្នកប្រើប្រាស់ និងម្ចាស់ម៉ាកផ្ទាល់។ ចំពោះអ្នកប្រើប្រាស់អាចទិញប៉ះចំទំនិញ ឬសេវាក្លែងក្លាយ ឬមានសញ្ញាស្រដៀងគ្នាទៅនឹងទំនិញ ឬសេវានៃម៉ាកដែលគាត់ចង់ទិញទំនិញ ឬសេវានោះ។ ប៉ុន្តែប្រសិនគុណភាពនៃទំនិញនោះដូចគ្នា ឬប្រហាក់ប្រហែលគ្នាវាមិនជាមានបញ្ហាអ្វីទេ។ ដោយឡែកចំពោះទំនិញ ឬសេវាដែលមិនដូចគ្នាវិញ គាត់អាចច្រឡំថាទំនិញ ឬសេវានោះគឺជាផលិតផលនៃម៉ាកដែលពួកគេចង់បាន។ រីឯម្ចាស់ម៉ាកវិញក៏ខូចប្រយោជន៍ច្រើនផងដែរ ដូចជាអ្នកដែលចូលចិត្តទំនិញ ឬសេវារបស់ពួកគាត់ បែរជាទៅទិញទំនិញ ឬសេវាផ្សេងដែលមានម៉ាកដូចគ្នាទៅវិញ។ លើសពីនេះទៀតនៅពេលដែលអ្នកប្រើយកទៅប្រើប្រាស់ពិនិត្យឃើញថា: ទំនិញ ឬសេវានោះគ្មានគុណភាព នោះពួកគាត់នឹងឈប់ទិញ ឬឈប់ប្រើសេវាដែលមានម៉ាកប្រភេទនេះទៀត រួមទាំងទំនិញឬសេវារបស់ពួកគាត់ផងដែរ។ ទន្ទឹមនឹងពេលវេលាដែលសេដ្ឋកិច្ចកំពុងតែមានការរីកចំរើន នោះបច្ចេកវិទ្យាក៏មានការរីកលូតលាស់ខ្លាំងផងដែរ ដែលបច្ចេកទេសទាំងនោះកើតឡើងពីការច្នៃប្រឌិត និងការប្រកួតប្រជែងរបស់មនុស្ស ដូច្នេះអ្វីដែលគួរឲ្យយកចិត្តទុកដាក់ខ្លាំងបំផុតនោះគឺ បញ្ហានៃការការពារកម្មសិទ្ធិបញ្ញាមិនថានៅប្រទេកម្ពុជាយើងនោះទេជាពិសេសនៅទូទាំង

ពិភពលោកតែម្តង។ ដើម្បីឆ្លើយតបទៅនឹងបញ្ហាទាំងអស់នោះរាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់យ៉ាងខ្លាំងដោយកម្ពុជាបានចូលជាហត្ថលេខីនៃសន្ធិសញ្ញាជាច្រើនដែលពាក់ព័ន្ធទៅនឹងវិស័យកម្មសិទ្ធិបញ្ញាជាពិសេស "**ម៉ាក**" តែម្តង។ លើសពីនេះទៀតដើម្បីឲ្យមានកិច្ចការពារទៅលើម៉ាកកាន់សម្បូរបែប យើងឃើញថារាជរដ្ឋាភិបាលបានរៀបចំបទដ្ឋានគតិយុត្តមួយចំនួនដូចជា៖ ច្បាប់ស្តីពីម៉ាកពាណិជ្ជ នាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់លេខ នស/រកម/០២០២ /០០៦, ចុះថ្ងៃទី០៧ កុម្ភៈ ឆ្នាំ២០០២ និងអនុក្រឹត្យស្តីពីការអនុវត្តន៍ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់,លេខ ៦៤អនក្រ/បក, ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៧ និងលិខិតបទដ្ឋានពាក់ព័ន្ធមួយចំនួនទៀត។ មានផ្នែកមួយចំនួននៃអត្ថបទច្បាប់ទាំងនេះបានបញ្ញត្តិអំពលក្ខខណ្ឌដើម្បីទទួលបាននូវកិច្ចការពារលើម៉ាករួមទាំងម៉ាក ដែលមិនអាចចុះបញ្ជីបានដើម្បីជៀសវាងរាល់ការភ័ន្តច្រឡំ ការប៉ះពាល់ដល់ស្ថាប័នជាតិ និងអន្តរជាតិ។ ហើយសិទ្ធិដែលមានលើម៉ាកត្រូវបានច្បាប់ទទួលស្គាល់តាមរយៈការចុះបញ្ជីម៉ាក ប៉ុន្តែក៏មានអញ្ញត្តិកម្មផងដែរចំពោះម៉ាកដែលល្បីៗ។ ទន្ទឹមនឹងការទទួលបាននូវសិទ្ធិលើម៉ាក យើងក៏ឃើញមាននូវយន្តការដោះស្រាយវិវាទមួយចំនួនដែលត្រូវកំណត់ដោយច្បាប់។ នៅពេលនេះអ្នកនឹងមានចម្ងល់ជាច្រើនថា៖

តើត្រូវធ្វើយ៉ាងណាដើម្បីទទួលបាននូវកិច្ចការពារលើម៉ាកដែលខ្លួនបានចុះបញ្ជី?

តើអ្នកនឹងទទួលបានអ្វីខ្លះពីការចុះបញ្ជីម៉ាក?

តើត្រូវដោះស្រាយដូចម្តេចខ្លះពេលមានវិវាទ?

ដើម្បីឆ្លើយតបទៅនឹងសំណួរទាំងនេះយើងគប្បីសិក្សាស្វែងយល់ដោយផ្តោតសំខាន់ទៅលើ៖

១. ជំពូកទី១៖ សញ្ញាណគតិយុត្តនៃម៉ាក

២. ជំពូកទី២៖ នីតិវិធីក្នុងការចុះបញ្ជីម៉ាក

៣. ជំពូកទី៣៖ សិទ្ធិនៃម្ចាស់ម៉ាក ការរំលោភម៉ាក និងយន្តការដំណោះស្រាយវិវាទ

ចំពោះជំពូកទាំងបីខាងលើ យើងខ្ញុំនឹងធ្វើការបកស្រាយនៅទំព័របន្តបន្ទាប់ទៀតដែលមានខ្លឹមសារទាំងស្រុងដូចខាងក្រោមនេះ៖

# ជំពូកទី១
# សញ្ញាណគតិយុត្តនៃម៉ាក

# ជំពូកទី១
# សញ្ញាណគតិយុត្តនៃម៉ាក

## ផ្នែកទី១៖ និយមន័យ និងប្រភេទនៃម៉ាក

### កថាភាគទី១៖ និយមន័យ

**និយមន័យ:** "**ម៉ាក**" គឺជាសញ្ញាដែលមើលឃើញហើយអាចសម្គាល់លក្ខណ:ខុសគ្នានៃទំនិញ ឬសេវានៃសហគ្រាសនីមួយៗ[១]។ លើសពីនេះទៅទៀតយោងតាមមាត្រា១៥ កថាខណ្ឌទី១ នៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIP)[២]បានកំណត់ថា: សញ្ញាណណាមួយ ឬបង្គុំណាមួយនៃសញ្ញាដែលអាចញែកដាច់ពីគ្នានូវទំនិញ ឬសេវារបស់សហគ្រាសណាមួយពីទំនិញ ឬសេវារបស់ណាមួយសហគ្រាសផ្សេងទៀតអាចបង្កើតបានជាម៉ាក។ ម៉ាកអាចប្រើប្រាស់សម្រាប់សម្គាល់ទំនិញហៅថា "**ពាណិជ្ជសញ្ញា**" រីឯម៉ាកសម្រាប់សម្គាល់សេវាហៅថា "**សេវា សញ្ញា**"។

#### ១. ម៉ាកជាសញ្ញាដែលឃើញ

##### ១.១.ម៉ាកដែលមើលឃើញ

**ម៉ាកដែលមើលឃើញ** គឺជាសញ្ញាទាំងឡាយណាដែលយើងអាចមើលឃើញដោយភ្នែក ហើយអាចសម្គាល់លក្ខណ:ខុសគ្នានៃទំនិញ ឬសេវានៃសហគ្រាសនីមួយៗ។

##### ១.២. ម៉ាកដែលមើលមិនឃើញ

**ម៉ាកដែលមើលមិនឃើញ** គឺជាសញ្ញាដែលយើងមិនអាចមើលឃើញដោយភ្នែកទេដូចជា៖ ម៉ាកគំនូសបីជ្រុង សម្លេង ក្លិន រសជាតិ។ ប៉ុន្តែម៉ាកប្រភេទនេះបើផ្អែកតាមមាត្រា២ នៃច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួត ប្រជែងមិនស្មោះត្រង់នៃប្រទេសកម្ពុជា គឺមិនបានទទួលស្គាល់ម៉ាកដែលជាសម្លេង ឬក៏ជាក្លិននោះទេ ហើយក៏មិនបានការពារដែរ។ ប៉ុន្តែនៅបណ្តាប្រទេសមួយចំនួនទៀតនៅលើពិភពលោក ច្បាប់នៃរដ្ឋមួយចំនួនបានការពារលើម៉ាកដែលមើលមិនឃើញនេះ។

**ឧទាហរណ៍:** ក្លិនទឹក អប់ម៉ាក Chanel [៣]។

#### ២. ម៉ាកអាចសម្គាល់លក្ខណ:ខុសគ្នានៃទំនិញ ឬសេវារបស់សហគ្រាសនីមួយៗ

##### ២.១. ម៉ាកសម្គាល់លក្ខណ:ខុសគ្នានៃទំនិញ ឬសេវា

❖ "*ពាណិជ្ជសញ្ញា*" គឺជាសញ្ញាទាំងឡាយណាដែលប្រើប្រាស់ក្នុងទំនាក់ទំនងជា

---

[១] មាត្រា២ ចំនុច "ក" នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនសោះត្រង់, លេខ នស/រកម/០២០២/០០៦,០៧ កុម្ភៈ ២០០២

[២] TRIP: The Agreement on Trade Related Aspects of Intellectual Property Rights.

[៣] រូបភាព នៅឧបសម្ព័ន្ធទី១

មួយ និងទំនិញដូចជា៖ ម៉ាក Samsung, Panasonic, Sony…។ល។

➢ "*សេវាសញ្ញា*" គឺជាសញ្ញាទាំងឡាយ ដែលប្រើប្រាស់ក្នុងទំនាក់ទំនងជាមួយ និងសេវាកម្មដូចជា៖ ប្រើប្រាស់ចំពោះសណ្ឋាគារ ក្រុមហ៊ុនទេសចរណ៍ និងភោជនីយដ្ឋានជាដើម។

### ២.២. សហគ្រាសនីមួយៗ

➢ សហគ្រាសពាណិជ្ជកម្ម: គឺជាទំនាក់ទំនងបង្កើតឡើងរវាងបុគ្គល និងបុគ្គល ដែលចាត់ចែងនូវមុខរបរជារួមក្នុងគោលដៅធ្វើឲ្យបានសម្រេចនូវប្រាក់ចំណេញ។

## កថាភាគទី២៖ ប្រភេទផ្សេងៗនៃម៉ាក

### ១. ម៉ាកធម្មតា (Traditional Mark)

### ១.១. ពាក្យ ឬឈ្មោះបុគ្គល អក្សរ ឬលេខ

➢ "**ពាក្យ ឬឈ្មោះ**" អាចជាឈ្មោះក្រុមហ៊ុន ឈ្មោះភូមិសាស្ត្រ នាមត្រកូល ឈ្មោះ ហើយនឹងពាក្យដទៃផ្សេងៗទៀត ទោះបីជាពាក្យមួយមាត់ ឬជាពាក្យស្លោកក៏ដោយ ក៏យើងចាត់ទុកថាជាម៉ាកដែរ។

**ឧទាហរណ៍:** ទឹកក្រូច Coca Cola និងទូរស័ព្ទដៃ Samsung [៤]

➢ "**អក្សរ ឬលេខ**" សំដៅទៅលើអក្សរមួយ ឬច្រើនតួ លេខមួយតួ ឬលេខច្រើនតួ ឬបូកបញ្ចូលគ្នារវាងតួលេខ និងអក្សរទាំងអស់បញ្ចូលគ្នា។

**ឧទហរណ៍:** ថ្មពិល( 555) និង អាគុយ(3K) [៥]

### ១.២. បង្គុំនៃពណ៌ និង សញ្ញា

➢ **បង្គុំនៃពណ៌:** សំដៅទៅលើការរួមបញ្ចូលគ្នានៃពណ៌ជាច្រើនក្នុងម៉ាកតែមួយ។

**ឧទហរណ៍:** ក្រុមហ៊ុន Cellcard និង Smart [៦]

➢ **បង្គុំនៃសញ្ញា:** សំដៅទៅលើការបង្គុំគ្នានៃសញ្ញាច្រើនបញ្ចូលគ្នាក្នុងម៉ាកតែមួយ"។

### ២. ម៉ាកមិនធម្មតា (Non-traditional Mark) (**ធំនើប**)

➢. ***តំនូសបីជ្រុង*** (Three dimensional sign) អាចជារូបរាងនៃទំនិញ ឬការវេចខ្ចប់របស់ទំនិញ[៧]។

---

[៤] រូបភាព នៅឧបសម្ព័ន្ធទី១

[៥] រូបភាព នៅឧបសម្ព័ន្ធទី១

[៦] រូបភាព នៅឧបសម្ព័ន្ធទី១

[៧] រូបភាព នៅឧបសម្ព័ន្ធទី១

[៨] Intellectual Property Law Works Shop

➥. ***ម៉ាកជាក្លិន*** គឺជាម៉ាកដែលសម្គាល់ទៅលើប្រភេទនៃក្លិនរបស់ក្រុមហ៊ុននៃសហគ្រាសណាមួយ។ ឧទាហរណ៍: ក្លិនទឹកអប់ម៉ាក Chanel, និងម៉ាក Clive Christian's N0.1។

➥. ***ម៉ាកជាសម្លេង*** គឺជាម៉ាកនៃសម្លេងដែលបង្កើតចេញពីសម្លេងភ្លេង ឬឃ្លានៃភ្លេង។

**ឧទាហរណ៍:** សម្លេងភ្លេងទូរស័ព្ទពេទ៍ Nokia; សម្លេងភ្លេងទូរស័ព្ទពេទ៍ iPhone; សម្លេងភ្លេងទូរស័ព្ទពេទ៍ Samsung...[៩]។ល។

➥. ***ម៉ាករសជាតិ*** គឺជាម៉ាកដែលសំដៅទៅលើប្រភេទរសជាតិនៃផលិតផលរបស់ក្រុមហ៊ុននីមួយៗ ហើយរសជាតិទាំងនោះគឺមានលក្ខណៈមិនដូចគ្នាឡើយ។

**ឧទាហរណ៍:** រសជាតិកាហ្វេរបស់ហាងកាហ្វេ Brown ខុសពីរសជាតិកាហ្វេរបស់ហាងកាហ្វេ Amazon, រសជាតិ Pizza របស់ហាង Pizza Company មានរសជាតិខុសពី Pizza របស់ហាងផ្សេងៗទៀត។

យោងតាមមាត្រា២៦ នៃច្បាប់ម៉ាក ចំពោះម៉ាកល្បី ទោះបីជាមិនបានចុះបញ្ជីក៏ដោយ ក៏ត្រូវបានការពារក្រោមច្បាប់ម៉ាករបស់ប្រទេសកម្ពុជាផងដែរ។ ប្រសិនបើប្រទេសកម្ពុជាទទួល ឬអនុញ្ញាតិឲ្យចុះ បញ្ជីម៉ាក Non-Traditional Mark ហើយម៉ាក Non-Traditional Mark ជាម៉ាកល្បីនៃប្រទេសណាមួយដែលជាសមាជិកនៃកិច្ចព្រមព្រៀង TRIPS ឬអនុសញ្ញានៃទីក្រុងប៉ារីស ហើយត្រូវបានប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា តើប្រទេសកម្ពុជាអាចការពារម៉ាននោះបានដែររឺទេក្នុងករណីដែលមានការរំលោភសិទ្ធិលើម៉ាក?

## ៣ . ពាណិជ្ជនាម ម៉ាកសមូហភាព និង ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

### ៣.១. ម៉ាកពាណិជ្ជនាម (Trade Name)

**ពាណិជ្ជនាម** (Trade Name) គឺជាឈ្មោះ ឬសញ្ញាសម្គាល់ ឬជាឈ្មោះ និងសញ្ញាសម្គាល់សម្រាប់បញ្ជាក់ពីលក្ខណៈ ឬភាពខុសៗគ្នានៃសហគ្រាសនីមួយៗ[១០]។ ពាណិជ្ជនាមទាំងនោះមានដូចជា៖ ឈ្មោះរបស់រូបវន្តបុគ្គល (ស្រា Johny and Walker), រហស្សនាម...ជាដើម។

### ៣.២. ម៉ាកសមូហភាព

**ម៉ាកសមូហភាព** គឺជាម៉ាកដែលត្រូវបានគ្រប់គ្រងដោយសមាគមន៍ ម៉ាកសមូហភាពដែលត្រូវបានកំណត់ដោយបញ្ញត្តិដោយឡែក។ ហើយបើតាមមាត្រា២ (ខ) នៃច្បាប់ម៉ាកកំណត់និយមន័យថា "ម៉ាកសមូហភាព គឺជាសញ្ញាដែលមើលឃើញសំដៅប្រើក្នុងការដាក់ពាក្យសុំចុះបញ្ជី ហើយអាច

[៩] មាត្រាL.711-1,b នៃក្រមកម្មសិទ្ធិបញ្ញាបារាំង៖ "ម៉ាកអាចបង្កើតឡើងដោយសម្លេង ឬឃ្លាភ្លេង"

[១០] និយមន័យនេះដកស្រង់ចេញពីសៀវភៅនីតិកម្មសិទ្ធិបញ្ញា និពន្ធដោយ ឯកឧត្តម ឥន យឿន និងសាស្ត្រាចារ្យ អ៊ុក វណ្ណារ័ត្ន (បោះពុម្ពលើកទី១ ឆ្នាំ ២០១៣)

សម្គាល់នូវប្រភពដើមនៃទំនិញ ឬសេវា ឬសម្គាល់នូវចារិកលក្ខណៈរួមដទៃទៀតគិតទាំងគុណភាពនៃទំនិញ ឬសេវារបស់សហគ្រាសផ្សេងៗគ្នា ដែលប្រើសញ្ញានោះក្រោមការគ្រប់គ្រងរបស់ម្ចាស់ម៉ាកសមូហភាពដែលបានចុះបញ្ជី"។

### ៣.៣. ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

**ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ** គឺសំដៅទៅលើសញ្ញាសម្គាល់ និង/ឬ រូបភាពផ្សេងៗទៀតដែល មានលក្ខណៈញែកដាច់ដែលជាឈ្មោះ ឬតំណាងឲ្យប្រភពដើមនៃតំបន់ភូមិសាស្ត្រមួយហើយឈ្មោះ សម្គាល់ និង/ឬ រូបភាពនោះសម្រាប់កំណត់អត្តសញ្ញាណទំនិញមានប្រភពក្នុងភូមិសាស្ត្រនោះ ដែលបានផ្តល់ជាមូលដ្ឋានគ្រឹះដល់គុណភាព កិត្តិសព្ទ ឬចរិតលក្ខណៈផ្សេងទៀតនៃទំនិញដែល កើតចេញពីតំបន់ភូមិសាស្ត្រនោះ[១១]។

**ឧទាហរណ៍:** ធុរេនកំពត ម្រេចកំពត ធុរេនកំពង់ចាម...[១២]។ល។

## ផ្នែកទី២៖ ម៉ាកដែលមិនអាចចុះបញ្ជីបាន

### កថាភាគទី១៖ ម៉ាកដែលធ្វើឲ្យមានការភាន់ច្រឡំ

#### ១. ម៉ាកដែលមិនសម្គាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវា

ម៉ាកដែលមិនអាចចុះបញ្ជីបានគឺ "ម៉ាកដែលមិនអាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវារបស់សហគ្រាសមួយទៅសហគ្រាសមួយផ្សេងទៀត[១៣]។ ជាទូទៅម៉ាកនីមួយៗគឺមានលក្ខណៈខុសប្លែកពីគ្នា អាស្រ័យទៅតាមផលិតផល សេវា និងគុណភាព ហើយម៉ាកទាំងអស់មិនអាចមានរូបរាង សញ្ញាសំគាល់ ឬឈ្មោះដូចគ្នានោះទេ។ លើសពីនេះទៅទៀត ម៉ាកដែលបានសរសេរអក្សរខុសគ្នា ប៉ុន្តែការបញ្ចេញសម្លេងមានសូរសម្លេងដូចគ្នា ក៏មិនអាចចុះបញ្ជីបានដែរ។

**ឧទាហរណ៍:** ក្រុមហ៊ុនទឹកក្រូច មួយបានផលិតទឹកក្រូចមួយប្រភេទ ហើយបានដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកនោះហៅថា: Kocakola ទៅលើទឹកក្រូចដែលខ្លួនបានផលិត។ បើយោងតាមមាត្រា ៤ នៃច្បាប់ម៉ាក សរបញ្ជាក់ឲ្យឃើញថា ម៉ាកនេះមិនអាចចុះបញ្ជីបាននោះទេ ពីព្រោះម៉ាក Kocakola ដែលដាក់លើទឹកក្រូចនោះ វាអាចធ្វើឲ្យអតិថិជនមានការភាន់ច្រឡំនិងម៉ាក Cocacola ដែលជាម៉ាកទឹកក្រូចដ៏ល្បីដែលបានផលិតតាំងពីឆ្នាំ១៨៨៦ នៅប្រទេសសហរដ្ឋអាមេរិក ទោះបីជាម៉ាកទាំងពីរនេះសរសេរអក្សរខុសគ្នាក៏ដោយ ប៉ុន្តែការបញ្ចេញសូរសំលេងរបស់វាគឺមានសូរសម្លេងដូចគ្នា ដូចនេះវា

---

[១១] មាត្រា៤ នៃច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ

[១២] រូបភាព នៅឧបសម្ព័ន្ធទី១

[១៣] មាត្រា២, ចំណុច ក នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

ជាហេតុមួយដែលអាចធ្វើឲ្យអតិថិជនភ័ន្តច្រឡំ។ ដូចនេះរាល់ម៉ាកដែលសុំចុះបញ្ជីទាំងអស់ត្រូវធ្វើយ៉ាងណាកុំឲ្យមានការភ័ន្តច្រឡំ ឬមិនអាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវារបស់ម៉ាកដែលបានចុះបញ្ជីរួចហើយ។ ប្រសិនបើម៉ាកដែលបានចុះបញ្ជីនោះមានលក្ខណៈដូចគ្នា និងមិនអាចសំគាល់លក្ខណៈខុសគ្នានៃម៉ាកដែលបានចុះបញ្ជីរួចហើយនោះទេ នាយកដ្ឋានកម្មសិទ្ធិបញ្ញាមិនអាចចុះបញ្ជីឲ្យបានឡើយ។

**ឧទាហរណ៍:** ការបិទ 502 ម៉ាក 502 តែមួយប៉ុន្តែជារបស់ក្រុមហ៊ុនពីរផ្សេងគ្នា ហើយបើយើងក្រឡេកមើលទៅម៉ាកទាំងពីរនេះ គឺមានលក្ខណៈដូចគ្នាស្ទើតែមិនអាចសម្គាល់លក្ខណៈខុសគ្នានៃទំនិញនោះបានទេ។ ដូចនេះម៉ាកទាំងពីរនេះ គឺត្រូវមានម៉ាកណាមួយដើរចេញពីទីផ្សារ និងមិនអាចចុះបញ្ជីបានឡើយ[១៤]។

### ១.១. លក្ខណៈខុសគ្នានៃទំនិញ ឬសេវា

ម៉ាកទំនិញ ឬសេវារបស់ក្រុមហ៊ុនមួយមិនត្រូវបង្កឲ្យមានលក្ខណៈដូច ឬស្រដៀងដែលធ្វើឲ្យមានការភ័ន្តច្រឡំទៅនឹងម៉ាកទំនិញ ឬសេវារបស់ក្រុមហ៊ុនមួយផ្សេងទៀតឡើយ។ រាល់ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកទាំងឡាយណាដែលមានលក្ខណៈដូចបានរៀបរាប់ខាងលើ អាចត្រូវបានបដិសេធមិនអនុញ្ញាតឲ្យចុះបញ្ជីការពារក្នុងប្រទេសកម្ពុជាដោយមន្ត្រីចុះបញ្ជី។

### ១.២. ដូចគ្នានឹងម៉ាករបស់ម្ចាស់ផ្សេង

ជាគោលការណ៍ម៉ាកមួយនឹងពុំអាចត្រូវបានផ្តល់ការការពារដោយស្វ័យប្រវត្តិនោះទេ ប៉ុន្តែអាចទទួលបានការការពារសិទ្ធិតាមរយៈការចុះបញ្ជី។ តាមការបកស្រាយលើគោលការណ៍នេះ កាលណាបើមានអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីលើម៉ាកដែលស្រដៀង ឬដូចគ្នាលើទំនិញ ឬសេវា ដែលដូចគ្នា ឬប្រហាក់ប្រហែលគ្នាក្នុងចំនួនច្រើននាក់ផ្សេងពីគ្នា នោះយើងគប្បីត្រូវផ្តល់អាទិភាពដល់ម្ចាស់ម៉ាកដែលបានរួសរាន់មកដាក់ពាក្យស្នើសុំចុះបញ្ជីមុនគេ នេះជាគោលការណ៍នៃអ្នកមកចុះបញ្ជីបានមុនគេ ត្រូវបានទទួលការការពារមុន ***(នេះគឺជាគោលការណ៍នៃអ្នកដែលមកចុះបញ្ជី បានទទួលការការពារមុន)***។ ប៉ុន្តែអត្ថន័យដូចដែលបានបកស្រាយខាងលើនេះពុំត្រូវបានប្រកាន់ ខ្ជាប់ដោយច្បាប់ខ្មែរយើងដោយតឹងរឹងនេះទេ ជាពិសេសក្នុងដំណាក់កាលស្នើសុំចុះបញ្ជីស្របពេលគ្នានេះតែម្តង។ នៅក្នុងករណីដែលមានអ្នកដាក់ពាក្យស្នើសុំមានចំនួនច្រើនលើម៉ាកដែលដូចគ្នា ឬស្រដៀងគ្នា អាចនឹងនាំឲ្យមានការច្រឡំគ្នានោះ ការសម្រេចទទួលចុះបញ្ជីសម្រាប់ម្ចាស់ម៉ាកណាមួយ គឺអាស្រ័យទៅនឹងការបែងចែករវាងសម្មតិកម្មនៃពេលវេលាដែលមកដាក់ពាក្យស្នើសុំនោះ ពោលគឺក្នុងពេលខុស

---

[១៤] រូបភាព នៅឧបសម្ព័ន្ធទី១

គ្នា ឬក្នុងពេលជាមួយគ្នា[១៥]។ កាលបើពួកគេមកធ្វើការដាក់ពាក្យស្នើសុំក្នុងពេលខុសគ្នានោះមន្ត្រីកាន់កាប់បញ្ជីធ្វើការសម្រេចផ្តល់សិទ្ធិដល់ម្ចាស់ពាក្យស្នើសុំណាមួយឲ្យអាចចុះបញ្ជី និងបដិសេធអ្នកស្នើសុំផ្សេងទៀតដោយអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនតែម្តង ឬអាចចាត់ឲ្យមានការសម្រុះសម្រួលគ្នារវាងម្ចាស់ពាក្យស្នើសុំទាំងនោះ រួចទើបខ្លួនធ្វើការសម្រេចយល់ព្រម ឬអត់ជាក្រោយ[១៦]។ ដោយពុំបានបញ្ជាក់អំពីមូលដ្ឋាននៃការសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជី នៅក្នុងករណីនេះសិទ្ធិអំណាចសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជីហាក់បីដូចជាមានលក្ខណៈទូលំទូលាយណាស់។ ប៉ុន្តែសេចក្តីសម្រេចនេះនៅតែជាកម្មវត្ថុនៃការប្តឹងជំទាស់ដដែល។

ដោយឡែកបើពួកគេមកធ្វើការស្នើសុំចុះបញ្ជីម៉ាកក្នុងពេលវេលាជាមួយគ្នាវិញ នោះមន្ត្រីកាន់កាប់បញ្ជីពុំអាចធ្វើការសម្រេចជ្រើសរើសយកអ្នកស្នើសុំរូបណាមួយដោយឆន្ទានុសិទ្ធិរបស់ខ្លួនឡើយ ប៉ុន្តែត្រូវចាត់ឲ្យមានកិច្ចពិគ្រោះយោគយល់គ្នាទៅវិញទៅមករវាងអ្នកស្នើសុំទាំងអស់ដើម្បីជ្រើសរើសយកអ្នកស្នើសុំតែមួយរូបគត់សម្រាប់ការដាក់ពាក្យស្នើសុំនេះ។ បើទោះជាពុំមានអំណាចសម្រេចក៏គ្មានអត្ថបទច្បាប់ណាមួយហាមឃាត់មន្ត្រីកាន់កាប់បញ្ជីក្នុងការដើរតួនាទីជាអ្នកសម្របសម្រួលនោះដែរ។

យន្តការសម្រុះសម្រួលគ្នា ឬការសម្រេចដោយឆន្ទានុសិទ្ធិរបស់មន្ត្រីកាន់កាប់ចុះបញ្ជីខាងលើនេះនឹងពុំអាចត្រូវបានយកមកប្រើប្រាស់ឡើយ បើក្នុងចំណោមអ្នកស្នើសុំទាំងនោះ មានអ្នកស្នើសុំណាម្នាក់ជាម្ចាស់នៃសិទ្ធិអាទិភាព។

អាទិភាពនៃសិទ្ធិចុះបញ្ជីម៉ាកត្រូវបានបញ្ញត្តទទួលស្គាល់នៅក្នុងមាត្រា៦ នៃច្បាប់ស្តីពីម៉ាក។ យោងតាមមាត្រានេះ អ្នកស្នើសុំចុះបញ្ជីអាចស្នើសុំអាទិភាពនៃការចុះបញ្ជីដោយអមមកជាមួយនូវប្រកាសស្តីពីអាទិភាពដែលខ្លួនមានតាមរយៈការស្នើសុំចុះបញ្ជីនៅប្រទេសណាមួយដែលជាសមាជិកនៃអនុសញ្ញាទីក្រុងប៉ារីស។ ដោយឡែកទាក់ទងនឹងសិទ្ធិអាទិភាពក្នុងការចុះបញ្ជីម៉ាកនេះមាត្រា៦ ចំណុច C នៃអនុសញ្ញាទីក្រុងប៉ារីសបានកំណត់រយៈពេល៦ (ប្រាំមួយ) ខែ ដោយគិតពីការបរិច្ឆេទនៃការដាក់ពាក្យស្នើសុំចុះបញ្ជីមុនគេនៅក្នុងប្រទេសសមាជិកណាមួយនៃអនុសញ្ញានេះ (កាលបរិច្ឆេទនេះហៅថាកាលបរិច្ឆេទអាទិភាព) របៀបនៃការរាប់ការបរិច្ឆេទអាទិពភាពនេះ មានចែងច្បាស់នៅក្នុងមាត្រា៤ ចំណុច C នេះ។

[១៥] មាត្រា៩ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

[១៦] មាត្រា៩ ចំណុច "ក" នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

### ២. ម៉ាកដែលធ្វើឲ្យភ័ន្តច្រឡំ

ច្បាប់ម៉ាករបស់ប្រទេសកម្ពុជាមានគោលដៅការពារម្ចាស់ម៉ាកដែលស្របច្បាប់ ក្នុងការធ្វើពាណិជ្ជកម្មទៀងត្រង់ និងជាពិសេសអ្នកប្រើប្រាស់[១៧]។ ដូច្នេះរាល់ការប្រើប្រាស់ម៉ាកមិនត្រូវបង្កើតឲ្យមានការភ័ន្តច្រឡំដល់សាធារណៈជនទៅលើប្រភេទទំនិញ ឬសេវាពីសហគ្រាសមួយទៅសហគ្រាសមួយទៀតឡើយ[១៨]។ មន្ត្រីកាន់កាប់បញ្ជីមានសិទ្ធិបដិសេធរាល់ការចុះបញ្ជីម៉ាកដែលមានលក្ខណៈធ្វើឲ្យសាធារណៈជន ឬមជ្ឈដ្ឋានពាណិជ្ជកម្មភ័ន្តច្រឡំទៅនឹងប្រភពភូមិសាស្ត្រនៃទំនិញ ឬសេវាពាក់ព័ន្ធ ឬធាតុដើម ឬលក្ខណៈខាងក្រៅរបស់ទំនិញ ឬសេវានោះ។

#### ២.១. ភ័ន្តច្រឡំនឹងប្រភពភូមិសាស្ត្រ

##### ២.១.១. ប្រភពភូមិសាស្ត្រ

សំដៅទៅលើការប្រើប្រាស់ឈ្មោះតំបន់ដូចជា៖ ឈ្មោះស្រុក ខេត្ត ក្រុង លើផលិតផលទំនិញ ឬសេវាដែលអាចធ្វើឲ្យអ្នកប្រើប្រាស់ផលិតផល ឬសេវាយល់ថាៈ ទំនិញ ឬសេវានោះត្រូវបានធ្វើឡើងចេញពីតំបន់ ឬដោយបុគ្គលនៃតំបន់នោះ[១៩]។

**ឧទាហរណ៍:** "ទឹកត្រីកោះកុង" ទឹកត្រីនេះមាននៅខេត្តកោះកុងទេ ប៉ុន្តែក៏មានផលិតផលនេះផលិតនៅខេត្តកំពតផងដែរ រួចបែរជាដាក់ឈ្មោះជាទឹកត្រីកោះកុងទៅវិញ។

##### ២.១.២. ធាតុដើម ឬលក្ខណៈខាងក្រៅ

សំដៅទៅលើការប្រើប្រាស់ម៉ាកទាំងឡាយណាដែលធ្វើឲ្យសាធារណៈជនមានការភ័ន្តច្រឡំ ទៅនឹងសារធាតុ គុណភាព ឬមុខងារនៃផលិតផលសេវានោះ។

**ឧទាហរណ៍:** "កាល់ស្យូម Calcium" ជាផលិតផលនៃថ្នាំពេទ្យ។ ការប្រើប្រាស់បែបនេះធ្វើឲ្យសាធារណៈជនយល់ថា ជាថ្នាំដែលមានសារជាតិកាល់ស្យូមដែលអាចព្យាបាលជម្ងឺខ្វះកាលស្យូម។

#### ២.២. ភ័ន្តច្រឡំជាមួយម៉ាកល្បី

**"ម៉ាកល្បី"** គឺជាប្រភេទទំនិញ ឬសេវាជាក់លាក់ណាមួយ ដែលត្រូវបានសាធារណៈជនទូទៅស្គាល់នៅលើពិភពលោក។ ម៉ាកល្បីៗត្រូវបានការពារដោយស្របច្បាប់នៅក្នុងប្រទេសកម្ពុជាយើង ទោះបីជាម៉ាកល្បីទាំងនោះត្រូវបានចុះបញ្ជីក្តី ឬមិនបានចុះបញ្ជីក្តី។ កិច្ចការពារម៉ាកល្បីដោយប្រទេស

---

[១៧] ប្រទេសកម្ពុជាពុំទាន់មានច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់នៅឡើយ

[១៨] មាត្រា១ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

[១៩] ជំពូកទី៥ (ម៉ាកសម្គាល់ភូមិសាស្ត្រ) នៃគន្លឹទី២ នៃសៀវភៅនីតិកម្មសិទ្ធិបញ្ញាកម្ពុជា បោះពុម្ពលើកទី១ ឆ្នាំ២០១៣ របស់ លោក នី វិចិត្រ

កម្ពុជាត្រូវបានធ្វើឡើងដោយអនុលោមតាមកិច្ចព្រមព្រៀងអន្តរជាតិដែលកម្ពុជាជាសមាជិក[២០]។

### ២.២.១. លក្ខណៈវិនិច្ឆ័យនៃម៉ាកល្បី

ដើម្បីសម្គាល់នៃម៉ាកល្បី គឺមិនត្រឹមតែសម្គាល់ភាពល្បីរបស់ម៉ាកនោះតែប៉ុណ្ណោះទេ ពោល គឺម៉ាកល្បីត្រូវបំពេញលក្ខខណ្ឌបន្ថែមទៀតដូចជាៈ

- ការចុះបញ្ជីនៃម៉ាកនោះនៅតាមបណ្តាប្រទេសជាច្រើនលើពិភពលោក
- រយៈពេលនៃការប្រើប្រាស់ម៉ាក
- មានការទទួលស្គាល់ពីសាធារណៈជនទូទាំងពិភពលោក
- មានការផ្សព្វផ្សាយពាណិជ្ជកម្មស្ទើរគ្រប់តំបន់ និង
- របាយការណ៍ហិរញ្ញវត្ថុ...។ល។

ចំនុចទាំងអស់ខាងលើនេះហើយដែលជាកត្តាចម្បង ដើម្បីបំពេញបន្ថែមលើកិច្ចព្រមព្រៀង អន្តរជាតិដែលអនុញ្ញាតឲ្យប្រទេសដែលជាសមាជិកអាចពិចារណាទៅលើភាពល្បីនៃម៉ាកនោះ។

### ២.២.២. ម៉ាកល្បីដែលមិនបានចុះបញ្ជី

ម៉ាកល្បីទោះបីមិនបានចុះបញ្ជីក៏ដោយ ក៏ត្រូវបានការពារដោយច្បាប់ដែរ។ ថ្វីត្បិតយ៉ាងនេះ ក៏ពិតមែន តែបើប្រៀបធៀបទំហំនៃសិទ្ធិទទួលបានកិច្ចការពារ គឺវាមានលក្ខណៈខុសគ្នាជាមួយម៉ាក ល្បីដែលបានចុះបញ្ជី។ យោងតាមមាត្រា៤ ចំណុច (ង) នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃ ការប្រកួតប្រជែងមិនស្មោះត្រង់ គឺមិនអនុញ្ញាតឲ្យចុះបញ្ជីឡើយរាល់ម៉ាកដែលដូចគ្នា ឬប្រហាក់ ប្រហែលគ្នាដែលនាំឲ្យមានការច្រឡំគ្នា ឬប្រហាក់ប្រហែលគ្នានៃសហគ្រាសមួយទៀត។ ក្នុងន័យ នេះយើងឃើញថាៈ ម៉ាកល្បីដែលមិនបានចុះបញ្ជី គឺទទួលបានការការពារប្រឆាំងនឹងម៉ាកដែលប្រើ ចំពោះតែទំនិញ ឬសេវាដូចគ្នា ឬប្រហាក់ប្រហែលគ្នាតែប៉ុណ្ណោះ[២១]។

## **កថាភាគទី២៖ ម៉ាកដែលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសញ្ញានៃស្ថាប័នរដ្ឋ**

### **១. ម៉ាកដែលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ**

ម៉ាកដែលអាចចុះបញ្ជីបាន គឺជាម៉ាកដែលមិនប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សីលធម៌ និងប្រពៃណីល្អរបស់ជាតិឡើយ។ ម៉ាកដែលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សីលធម៌ និង ប្រពៃណីល្អរបស់ជាតិ គឺមិនបានកំណត់ឲ្យច្បាស់ថាជាម៉ាកប្រភេទណានោះទេ ហើយយើងក៏មិន ដឹងថាម៉ាកបែបណាដែលធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ ឬសីលធម៌ និងប្រពៃណីនោះដែរ ព្រោះ

[២០] មាត្រា៦ ស្ទួននៃអនុសញ្ញាទីក្រុងប៉ារីស ឆ្នាំ១៨៨៣ ស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម

[២១] មាត្រា៤ ចំណុច "ង" និង "ច" នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/ រកម/0២0២/00៦, 0៧ កុម្ភៈ ២00២

ការប៉ះពាល់សណ្តាប់ធ្នាប់ ឬសីលធម៌ ប្រពៃណី គឺអាចបកស្រាយទៅតាមការបរិបទ និងស្ថានភាពជាក់ស្តែងនៅក្នុងសង្គមនីមួយៗ។

យើងអាចធ្វើការបកស្រាយបានម្យ៉ាងទៀតថា ម៉ាកដែលប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ សីលធម៌ និងប្រពៃណី គឺជាម៉ាកទាំងឡាយណាដែលប៉ះពាល់នឹង៖

### ១.១. សណ្តាប់ធ្នាប់សាធារណៈ

**សណ្តាប់ធ្នាប់សាធារណៈ:** គឺជាម៉ាកទាំងឡាយ ដែលប៉ះពាល់ដល់ភាពទូលាយនៃសណ្តាប់ធ្នាប់សាធារណៈដូចជា៖ សន្តិសុខសុវត្ថិភាព ភាពស្ងៀមស្ងាត់ ភាពស្អាត ឬមានអនាម័យ និងការបង្កឲ្យមានភាពចលាចល ឬអសន្តិសុខនៅក្នុងសង្គម។

**ឧទាហរណ៍:** ការយកស្លាកសញ្ញាគណបក្សនយោបាយណាមួយមកធ្វើជាម៉ាក ឬម៉ាកដែលមានរូប ប៉ុលពត...ជាដើម។

### ១.២. សីលធម៌ ឬប្រពៃណីល្អរបស់ជាតិ

➢ **សីលធម៌:** គឺជាម៉ាកណាដែលមានសញ្ញា ឬឈ្មោះដែលមានរូបអាសអាភាស ពាក្យអសុរោះ និងម៉ាកផ្សេងៗទៀតដែលធ្វើប៉ះពាល់ដល់តម្លៃនៃសីលធម៌របស់ប្រទេសកម្ពុជា។

**ឧទាហរណ៍:** ផ្ទះសំណាក់ស៊ិច ភោជនីយដ្ឋានព្រះពុទ្ធ ឬអប្សរាក្លឹប...។ល។

➢ **ប្រពៃណីល្អ:** ម៉ាកទាំងឡាយណាដែលពាក់ព័ន្ធនឹងជាតិ ជំនឿ សាសនា ភេទ ដែលបង្ហាញឲ្យឃើញតាមរយៈរូបភាព ពាក្យ អក្សរ ដែលមានន័យអាក្រក់។

**ឧទាហរណ៍:** ផលិតផលម៉ាក BB ដើម្បីបណ្តុះសក់ហើយដាក់រូបព្រះសង្ឃពាក់មួក។

ដូចនេះហើយម៉ាកដែលបង្ហាញរូបអាសអាភាស ការរួមភេទ ឬរូបភាពអាក្រាតកាយ រូប ឬសញ្ញារបស់គណៈបក្សនយោបាយណាមួយក៏ត្រូវបានហាមឃាត់ដែរ។

**ឧទាហរណ៍:** តូបលក់សាច់កម្ពុជា, ហាងសាច់មាន់លោក[២២], Black Women Night Club, Apsara Night Club or Bar គឺមិនត្រូវទទួលបានចុះបញ្ជីនោះទេ ពីព្រោះវាប៉ះពាល់ទៅនឹងសីលធម៌ ប្រពៃណី ជំនឿ និងទំនៀមទំលាប់ ល្អរបស់កម្ពុជា។

## ២. ម៉ាកដែលប៉ះពាល់ដល់សញ្ញានៃស្ថាប័នរដ្ឋ

អនុសញ្ញាទីក្រុងប៉ារីសមាត្រា៦ស្ទួន ទី២(ter) បានហាមឃាត់រាល់បណ្តាប្រទេសជាសមាជិកមិនឲ្យចុះបញ្ជីម៉ាកទាំងឡាយណាដែលមានលក្ខណៈដូចទៅនឹងសញ្ញាជាតិ ឬទង់ជាតិនៃរដ្ឋណាមួយដែលជារដ្ឋមួយនៃរដ្ឋសមាជិកនៃសហគមន៍អឺរ៉ុប ឬអង្គការអន្តរជាតិណាមួយដែលប្រទេសជា

---

[២២] រូបភាព នៅឧបសម្ព័ន្ធទី១

សមាជិក។ ដូចគ្នាដែរ មាត្រានេះមានវិសាលភាពអនុវត្តចំពោះសញ្ញាទាំងឡាយណាដែលត្រូវបានអនុម័តដោយបណ្តារដ្ឋសមាជិក ឬដោយអង្គការអន្តរជាតិនោះ[២៣]។

### ២.១. ស្ថាប័នរដ្ឋ ឬអង្គការ

#### ❖ រដ្ឋ និងស្ថាប័នសាធារណៈផ្សេងទៀត

ស្លាកសញ្ញាទាំងឡាយណាដែលមានរូប ឬសញ្ញាដូចទៅនឹងស្ថាប័នរដ្ឋ ឬអង្គការនានា គឺត្រូវបានច្បាប់ហាមឃាត់មិនឲ្យចុះបញ្ជីឡើយ។ **ឧទាហរណ៍:** នៅក្នុងប្រទេសកម្ពុជាយើង ស្លាកសញ្ញារបស់ស្ថាប័នមីក្រូហិរញ្ញវត្ថុ ឬធនាគារឯកជនមួយចំនួនត្រូវបានរដ្ឋហាមឃាត់ហើយឲ្យផ្លាស់ប្តូរសារស្លាកសញ្ញាឡើងវិញដោយសារតែមានរូបសញ្ញាដូចទៅនឹងស្ថាប័នរដ្ឋមានដូចជា៖ ធនាគារអេស៊ីលីដាត្រូវផ្លាស់ប្តូរសញ្ញាពីរូបហង្ស ដែលជារូបស្លាកសញ្ញារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាស្ថាប័នរបស់រដ្ឋ ដោយប្តូរដាក់ជំនួសមកវិញនូវឈ្មោះរបស់ធនាគារនេះតែម្តងគឺ **អេស៊ីលីដា ACLEDA**[២៤] រីឯ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ក៏បានផ្លាស់ប្តូរពីនិមិត្តសញ្ញាប្រាក់ "៛" ដែលជានិមិត្តសញ្ញារបស់ធនាគារជាតិនៃកម្ពុជា ហើយដាក់ជំនួសមកវិញនូវឈ្មោះរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នេះតែម្តង គឺ **ប្រាសាក់**[២៥]។

#### ❖ អង្គការអន្តរជាតិ

ស្លាកសញ្ញាដែលពាក់ព័ន្ធទៅនឹងស្លាកអង្គការអន្តរជាតិនានាក៏ត្រូវបានគេហាមឃាត់មិនអនុញ្ញាតឲ្យចុះបញ្ជីឡើយ ពីព្រោះអាចធ្វើឲ្យប៉ះពាល់ស្ថាប័នទាំងនោះ។ ឧទាហរណ៍: ស្លាកសញ្ញារបស់អង្គការអន្តរជាតិ WTO ស្លាកសញ្ញាកាកបាទក្រហមកម្ពុជា ជាដើម...។ល។

### ២.២. សញ្ញានៃស្ថាប័នរដ្ឋ ឬអង្គការ

ក្នុងក្របខ័ណ្ឌអន្តរជាតិ មានបទប្បញ្ញត្តិនៃអនុសញ្ញាមួយចំនួនបានចែងអំពីលក្ខខណ្ឌហាមឃាត់មួយចំនួនក្នុងការចុះបញ្ជីម៉ាកដូចជា៖ ***អនុសញ្ញាទីក្រុងប៉ារីស១៨៨៣ ស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម*** មាត្រា៦ ស្ទួនទី២ (ter) បានហាមឃាត់បណ្តាប្រទេសសមាជិកមិនឲ្យចុះបញ្ជីម៉ាកទាំងឡាយណាដែលមានលក្ខណៈដូចគ្នាទៅនឹងសញ្ញាជាតិ ឬទង់ជាតិនៃរដ្ឋមួយនៃរដ្ឋសមាជិកនៃសហគមន៍អឺរ៉ុប ឬអង្គការអន្តរជាតិណាមួយដែលប្រទេសជាសមាជិក[២៦]។ ***កិច្ចព្រមព្រៀង TRIPS ១៩៩៤***

---

[២៣] Article 6 ter of 1883 Paris Convention on Protection of Industrial Property: "Mark: Prohibition concerning State Emblems Official Hallmarks, and Emblems of Intergovernmental Organizations".

[២៤] រូបភាព នៅឧបសម្ព័ន្ធទី១

[២៥] រូបភាព នៅឧបសម្ព័ន្ធទី១

[២៦] Article 6 ter of 1883 Paris Convention on protection of Industrial Property: "Mark: Prohibition concerning State Emblems, Official Hallmarks, and Emblems of Intergovernmental Organization".

មាត្រា២៣ នៃកិច្ចព្រមព្រៀង TRIPS បានបញ្ញត្តិហាមឃាត់មិនឲ្យចុះបញ្ជីម៉ាកទាំងឡាយណា ដែលមានលក្ខណៈដូចគ្នាទៅនឹងម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និង ***កិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធផ្សេងទៀត*** ដូចជា៖ អនុសញ្ញាទីក្រុង ស្ស៊ីណែវ ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ១៩០៦ មាត្រា២៣ បានចែងអំពីការហាមឃាត់ការចុះបញ្ជីម៉ាកដែលជាពាក្យ និងសញ្ញារបស់កាកបាតក្រហម "**Red Cross**" ។ រីឯអនុសញ្ញា **Naiobi** ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៨១ ក៏បានលើកឡើងអំពីការហាមឃាត់ការចុះបញ្ជីនូវសញ្ញាកង និងសញ្ញាផ្សេងទៀតនៃសញ្ញាកីឡាអូឡាំពិច។ ក្នុងនោះដែរលិខិតរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកមួយចំនួនទៀតដែលបានភ្ជាប់នូវគំរូ ឬសញ្ញា ឬរូបភាពនៃសញ្ញាទង់ជាតិ ឬសញ្ញាជាតិរបស់ប្រទេសដែលជាសមាជិកនានា ក៏ត្រូវបានហាមឃាត់មិនអនុញ្ញាតឲ្យចុះបញ្ជីជាម៉ាកក្នុងបណ្តាប្រទេសសមាជិកនោះផងដែរ។

# ជំពូកទី២

## នីតិវិធីក្នុងការចុះបញ្ជីម៉ាក

# ជំពូកទី២
# នីតិវិធីក្នុងការចុះបញ្ជីម៉ាក

## ផ្នែកទី១៖ ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក

ម៉ាកមួយអាចទទួលបាននូវការពារដោយស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា លុះត្រាតែម៉ាកទាំងនោះជា៖ ម៉ាកសញ្ញា សេវាសញ្ញា ម៉ាកសមូលហភាព ដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា[២៧]។ ដោយអនុវត្តតាមសន្ធិសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិ ឧស្សាហកម្ម ម៉ាក ដែលដាក់ពាក្យចុះបញ្ជីមុននឹងមានអត្ថិភាពជាងគេ។ រីឯនីតិវិធីនៃការចុះបញ្ជីម៉ាកវិញ គឺត្រូវតែអនុវត្តតាមច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងតាមអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ម្ចាស់ម៉ាកអាចដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាករបស់ខ្លួននៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នៃក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា។ ការស្នើសុំចុះបញ្ជីនោះត្រូវបំពេញលក្ខខណ្ឌទាំងឡាយទៅតាមច្បាប់កំណត់ លក្ខខណ្ឌទាំងនោះមានដូចជា៖ លក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់។

### កថាភាគទី១៖ លក្ខខណ្ឌគ្រឹះ

**លក្ខខណ្ឌគ្រឹះ** គឺជាលក្ខខណ្ឌដើម្បីធានាថា: ម៉ាកមួយអាចត្រូវបានមន្ត្រីចុះបញ្ជី អនុញ្ញាតការពារម៉ាកបាន ឬមិនបាន។ គ្រប់ម្ចាស់ម៉ាកមុននឹងយកម៉ាករបស់ខ្លួនទៅដាក់ពាក្យស្នើសុំចុះបញ្ជីដើម្បីការពារម៉ាករបស់ខ្លួនពីការរំលោភដោយប្រការណាមួយពីតតិយជនមកលើម៉ាករបស់ខ្លួននោះ គឺម្ចាស់ម៉ាកត្រូវពិនិត្យឲ្យបានគ្រប់លក្ខណ:សម្បត្តិនៃម៉ាករបស់ខ្លួនជាមុនសិន ថាតើម៉ាករបស់ខ្លួនដែលយកទៅចុះបញ្ជីនោះ ជាម៉ាកស្របច្បាប់ មិនផ្ទុយពីច្បាប់ និងមិនប៉ះពាល់ផលប្រយោជន៍សាធារណ: សីលធម៌ និងទំនៀមទំលាប់ល្អឡើយ ជាពិសេសមិនបំពានទៅនឹងលក្ខខណ្ឌទាំងឡាយដែលបានកំណត់នៅក្នុងមាត្រា៤ នៃច្បាប់ម៉ាក ស្តីអំពី "ម៉ាកដែលមិនអាចចុះបញ្ជីបាន"។ ជាគោលការណ៍ដើម្បីធ្វើការត្រួតពិនិត្យថា: តើម៉ាកមួយទទួលបានការអនុញ្ញាតចុះបញ្ជីបាន ឬអត់នោះមន្ត្រីផ្នែកទទួលត្រួតពិនិត្យចុះបញ្ជីម៉ាកនោះត្រូវធ្វើ ការត្រួតពិនិត្យទៅលើលក្ខខណ្ឌបីដូចជា៖ នីត្យានុកូលភាពនៃម៉ាក លក្ខណ:ខុសគ្នានៃម៉ាក និងភាពទំនេរនៃម៉ាក។

#### ១. នីត្យានុកូលភាពនៃម៉ាក

***ធាតុនីត្យានុកូលនៃម៉ាក*** គឺសំដៅទៅលើបទបញ្ញត្តិទាំងឡាយណាដែលចែងអំពីភាពដែលអាចចុះបញ្ជីបាន និងភាពដែលមិនអាចចុះបញ្ជីបាននៃម៉ាកមួយ។ និយាយរួមមកមានម៉ាកមួយចំនួន

[២៧] មាត្រា៣ នៃច្បាប់ម៉ាក "សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាកត្រូវបានទទួលស្គាល់តាមរយ:ការចុះបញ្ជីដោយអនុលោមតាមបទបញ្ញត្តិទាំងឡាយនៃច្បាប់នេះ"

ត្រូវបានហាមឃាត់ក្រោមច្បាប់ជាតិដោយអនុលោមតាមមាត្រា២ (ក) នៃច្បាប់ម៉ាក ហើយយោងតាមមាត្រានេះដែរ គឺមានតែម៉ាកដែលមើលឃើញទេទើបអាចត្រូវបានទទួលចុះបញ្ជី និងការពារនៅក្នុងប្រទេសកម្ពុជា រីឯម៉ាកដែលមើលមិនឃើញវិញដូចជា៖ ម៉ាកជាសម្លេង ក្លិន ឬរសជាតិ ហើយក៏មានម៉ាកមួយចំនួនត្រូវបានហាមឃាត់ក្រោមប្បញ្ញត្តិអន្តរជាតិ ម៉ាកទាំងនេះមិនអាចអនុញ្ញាតចុះបញ្ជីបានឡើយ។ ក្នុងក្របខ័ណ្ឌអន្តរជាតិក៏មានបទប្បញ្ញត្តិនៃអនុសញ្ញាមួយចំនួនបានចែងអំពីលក្ខខណ្ឌហាមឃាត់មួយចំនួនក្នុងការចុះបញ្ជីម៉ាកដូចជា៖ ***អនុសញ្ញាទីក្រុងប៉ារីស១៨៨៣ ស្តីពីកិច្ចការពារកម្មសិទ្ធិ ឧស្សាហកម្ម*** មាត្រា៦ ស្ទួនទី២ (ter)[២៨] ***កិច្ចព្រមព្រៀង TRIPS ១៩៩៤*** មាត្រា២៣ និង ***កិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធផ្សេងទៀត*** ដូចជា៖ អនុសញ្ញាទីក្រុង ស្សឺណែវ ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ១៩០៦ មាត្រា២៣ បានចែងអំពីការហាមឃាត់ការចុះបញ្ជីម៉ាកដែលជាពាក្យ និងសញ្ញារបស់កាកបាតក្រហម "**Red Cross**" ។ រីឯអនុសញ្ញា **Naiobi** ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៨១ ក៏បានលើកឡើងអំពីការហាមឃាត់ ការចុះបញ្ជីនូវសញ្ញាកង និងសញ្ញាផ្សេងទៀតនៃសញ្ញាកីឡាអូឡាំពិក។

### ២. លក្ខណៈខុសប្លែកគ្នានៃម៉ាក

ម៉ាកទំនិញ ឬសេវារបស់ក្រុមហ៊ុនមួយមិនត្រូវបង្កឲ្យមានលក្ខណៈ *ដូច ឬស្រដៀង ម៉ាក ឬសញ្ញា ក្រុមហ៊ុនមួយផ្សេងទៀតដែលបានចុះបញ្ជីរួចហើយ ដែលនាំឲ្យមានការភ័ន្តច្រឡំនោះទេ។* ចំពោះការដាក់ពាក្យដូចអ្វីដែលបានរៀបរាប់ខាងលើ អាចត្រូវបានបដិសេធមិនអនុញ្ញាតឲ្យចុះបញ្ជីការពារក្នុងប្រទេសកម្ពុជាដោយមន្ត្រីចុះបញ្ជីឡើយ។ ចំពោះម៉ាកល្បីវិញក៏ត្រូវបានការពារដោយស្រប ច្បាប់នៅក្នុងប្រទេសកម្ពុជាយើងផងដែរ ទោះបីជាម៉ាកល្បីនោះត្រូវបានចុះបញ្ជី ឬមិនបានចុះបញ្ជីនៅក្នុងប្រទេសកម្ពុជាយើងក៏ដោយ[២៩]។ ដូច្នេះរាល់ការដាក់ពាក្យស្នើសុំចុះបញ្ជីនូវសញ្ញាដែលមានលក្ខណៈដូច ឬស្រដៀងទៅនឹងម៉ាកល្បី គឺត្រូវបានបដិសេធមិនឲ្យចុះបញ្ជីឡើយ[៣០]។

### ៣. ភាពទំនេរនៃម៉ាក

សញ្ញាដែលអាចប្រើប្រាស់ និងចុះបញ្ជីបានលុះត្រាតែសញ្ញានោះ គឺជាសញ្ញាដែលនៅទំនេរពេលគឺសញ្ញានោះមិនទាន់មានជាកម្មសិទ្ធិរបស់តតិយជនណាមួយនៅឡើយ។ ត្រង់ចំណុចនេះមានន័យថា: សញ្ញាដែលអាចចុះបញ្ជីបាន គឺជាម៉ាកទាំងឡាយណាដែលមានភាពថ្មីតែម្តង។

[២៨] Article 6 ter of 1883 Paris Convention on protection of Industrial Property: “Mark: Prohibition concerning State Emblems, Official Hallmarks, and Emblems of Intergovernmental Organization”.

[២៩] មាត្រា២៦ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

[៣០] មាត្រា៤ ចំណុច "ង" និង "ច" នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

ដើម្បីដឹងថាម៉ាកមួយមានម្ចាស់កម្មសិទ្ធិហើយរឺនៅនោះ ទាល់តែអ្នកដាក់ពាក្យសុំដើម្បីធ្វើការស្រាវជ្រាវលើភាពទំនេរនៃម៉ាកនោះតាមរយៈការសុំយោបលពីមន្ត្រីកាន់កាប់បញ្ជី[៣១]។ បន្ទាប់ពីបានទទួលពាក្យស្នើសុំបញ្ជាក់ពីភាពទំនេរនៃម៉ាករួចមក នាយកដ្ឋានកម្មសិទ្ធិបញ្ញានឹងចេញលិខិតបញ្ជាក់ ថាម៉ាកដែលបានដាក់ពាក្យស្នើសុំនោះ ជាម៉ាកនៅទំនេរ ឬក៏មានម្ចាស់កម្មសិទ្ធិរួចហើយ។

## កថាភាគទី២៖ លក្ខខណ្ឌទម្រង់

ក្រៅពីលក្ខខណ្ឌគ្រឹះនៃម៉ាក ក៏មាននៅលក្ខខណ្ឌទម្រង់មួយទៀតដែលម្ចាស់ម៉ាកត្រូវបំពេញបែបបទក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកដែលត្រូវបានកំណត់ដោយក្រសួងពាណិជ្ជកម្ម។ ការបំពេញទម្រង់នៃពាក្យស្នើសុំចុះបញ្ជីម៉ាកនេះ ត្រូវមានភ្ជាប់នូវសំណុំឯកសារចាំបាច់មួយចំនួនទៀតដូចដែលបានកំណត់លម្អិតនៅក្នុងអនុក្រឹត្យលេខ៦៤ ស្តីពីការអនុវត្តន៍ច្បាប់ម៉ាកដើម្បីឲ្យអាជ្ញាធរមានសមត្ថកិច្ចដែលជាមន្ត្រីមានតួនាទីធ្វើការពិនិត្យពិច័យ និងសម្រេចថាតើគួរគម្បីផ្តល់សិទ្ធិផ្តាច់មុខដល់អ្នកស្នើសុំនោះដែរ ឬយ៉ាងណា?

### ១. ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក

រាល់ម៉ាកដែលមិនបានបញ្ញត្តិនៅក្នុងមាត្រា៤ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ គឺជាម៉ាកដែលអាចចុះបញ្ជីបានទាំងអស់។ ដូចនេះម៉ាកទាំងនោះមានសិទ្ធិក្នុងការសុំចុះបញ្ជីបានការដាក់ពាក្យស្នើសុំត្រូវធ្វើឡើងដោយម្ចាស់ម៉ាក ឬអ្នកតំណាង ដែលម្ចាស់ម៉ាកផ្តល់សិទ្ធឲ្យ ហើយធ្វើតាមរយៈគំរូពាក្យស្នើសុំដូចមានចែងនៅក្នុងប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ដោយក្នុងពាក្យនោះត្រូវចុះហត្ថលេខាដោយម្ចាស់ម៉ាក ឬអ្នកតំណាងស្របច្បាប់។ ពាក្យស្នើសុំមួយអាចស្នើសុំចុះបញ្ជីម៉ាកមួយចំពោះទំនិញ ឬសេវាក្នុងចំណាត់ថ្នាក់តែមួយ ឬច្រើនតាមចំណាត់ថ្នាក់អន្តរជាតិ។ សម្រាប់នីតិវិធីក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីនេះភាពចាំបាច់ គឺត្រូវកំណត់ថាបុគ្គលណាខ្លះដែលអាចមានសិទ្ធិក្នុងការដាក់ពាក្យស្នើសុំមានឯកសារចាំបាច់អ្វីខ្លះ ហើយអាជ្ញាធរណាខ្លះដែលមានសមត្ថកិច្ចក្នុងការទទួលពាក្យស្នើសុំ និងសម្រេចពីការចុះបញ្ជីនេះ។

#### ១.១. ការដាក់ពាក្យស្នើសុំ

ពាក្យសុំចុះបញ្ជីម៉ាកត្រូវបំពេញ និងបញ្ជូនទៅមន្ត្រីកាន់កាប់បញ្ជីម៉ាកនៃក្រសួងពាណិជ្ជកម្ម ដោយម្ចាស់ម៉ាកខ្លួនឯង ឬដោយអ្នកតំណាងម្ចាស់ម៉ាកស្របច្បាប់នៅក្នុងប្រទេសកម្ពុជា។

#### ១.២. ការបំពេញគំរូពាក្យស្នើសុំ

ពាក្យស្នើសុំចុះបញ្ជីម៉ាកត្រូវបានចែកជូនដោយឥតគិតថ្លៃដោយមន្ត្រីកាន់កាប់បញ្ជីម៉ាក[៣២]។

---

[៣១] មាត្រា៣០ នៃអនុក្រឹត្យលេខ៦៤

[៣២] មាត្រា៣ នៃអនុក្រឹត្យលេខ៦៤៖ "គំរូពាក្យស្នើសុំដែលបានបោះពុម្ពរួចត្រូវចែកជូនដល់អ្នកដាក់ពាក្យស្នើសុំដោយឥតគិតថ្លៃ ដោយមន្ត្រីកាន់កាប់បញ្ជី"។

ម្ចាស់ម៉ាកត្រូវបំពេញគំរូពាក្យសុំនូវចំណុចសំខាន់ៗដូចខាងក្រោម៖

ង. ភាសាប្រើប្រាស់ក្នុងឯកសារដាក់ពាក្យស្នើសុំ និងការបកប្រែ: ពាក្យស្នើសុំអាចធ្វើជាភាសាខ្មែរ ឬជាភាសាអង់គ្លេស[៣៣]។ ក្នុងករណីដែលពាក្យស្នើសុំនោះមិនមែនជាភាសាខ្មែរ ឬជាភាសាអង់គ្លេសទេ ពាក្យស្នើសុំទាំងនោះត្រូវប្រែសម្រួលទៅជាភាសាខ្មែរ ឬភាសាអង់គ្លេសជាមុនសិនមុននឹងយកទៅដាក់ជូនមន្ត្រីកាន់កាប់បញ្ជីម៉ាក។

ង. ការបញ្ជាក់អត្តសញ្ញាណរបស់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក: ដើម្បីបញ្ជាក់ពីអត្តសញ្ញាណរបស់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក គឺត្រូវពិនិត្យទៅលើឈ្មោះ អាសយដ្ឋាន សញ្ជាតិ និងវេសដ្ឋាន។

- **ឈ្មោះ៖** អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីអាចជារូបវន្តបុគ្គល និងនីតិបុគ្គល។ បើអ្នកស្នើសុំជារូបវន្តបុគ្គល ឈ្មោះរបស់រូបវន្តបុគ្គលនោះត្រូវមានដាក់នាមត្រកូល និងនាមខ្លួន។ រីឯអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីជានីតិបុគ្គលវិញ គឺត្រូវបញ្ជាក់ឈ្មោះដែលជាឈ្មោះផ្លូវការរបស់នីតិបុគ្គលនោះដូចមានចែងនៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុនដែលបានចុះបញ្ជីនៅក្នុងក្រសួងពាណិជ្ជកម្ម។
- **សញ្ជាតិ៖** សញ្ជាតិត្រូវបញ្ជាក់នូវឈ្មោះរបស់រដ្ឋ ឬប្រទេសដែលបុគ្គលនោះ ជាពលរដ្ឋនៃរដ្ឋ ឬប្រទេសនោះ។ រីឯនីតិបុគ្គលវិញ គឺត្រូវបញ្ជាក់ឈ្មោះរដ្ឋ ឬប្រទេសដែលនីតិបុគ្គលនោះបានបង្កើតឡើងតាមច្បាប់របស់រដ្ឋ ឬប្រទេសនោះព្រមទាំងមានការិយាល័យនៃនីតិបុគ្គលនោះដែលបានចុះបញ្ជីរួច។

## ២. ការត្រួតពិនិត្យលើពាក្យស្នើសុំ

ដំណាក់កាលនៃការពិនិត្យលើពាក្យស្នើសុំ មន្ត្រីកាន់កាប់បញ្ជីនឹងធ្វើការត្រួតពិនិត្យទៅលើលក្ខខណ្ឌនីត្យានុលក្ខណភាពនៃម៉ាកដែលបានដាក់ពាក្យស្នើសុំចុះបញ្ជី ដើម្បីឲ្យដឹងថាតើម៉ាកនោះគោរពទៅតាមលក្ខខណ្ឌដែលច្បាប់បានកំណត់ហើយឬនៅ (លក្ខខណ្ឌនីត្យានុកូលភាពនៃម៉ាកភាពខុសប្លែកគ្នានៃម៉ាក និងភាពទំនេរនៃម៉ាក)។

### ២.១. ការទទួលយកពាក្យស្នើសុំ និង ការចេញលិខិតទទួលស្គាល់ការដាក់ពាក្យ

មួយនៅពេលដែលមន្ត្រីកាន់កាប់បញ្ជីបានពិនិត្យមើលខ្លឹមសារនៃម៉ាកដែលបានដាក់ពាក្យស្នើសុំចុះបញ្ជីរួចហើយ ហើយយល់ព្រមទទួលពាក្យស្នើសុំក្នុងលក្ខខណ្ឌនៃការកែតម្រូវ ការកែសម្រួល ការប្រកាសមិនទាមទារសិទ្ធិលើចំណុចណានៃម៉ាក ឬការកម្រិតសិទ្ធិ ឬលក្ខខណ្ឌផ្សេងទៀតមន្ត្រីកាន់កាប់បញ្ជីនឹងធ្វើការជូនដំណឹងជាលាយល័ក្ខអក្សរទៅឲ្យអ្នកដាក់ពាក្យស្នើសុំនោះ។

[៣៣] មាត្រា៩ នៃអនុក្រឹត្យលេខ៦៩៖ "តាមការតម្រូវរបស់ច្បាប់ ឬអនុក្រឹត្យនេះ ពាក្យស្នើសុំត្រូវធ្វើជាភាសាខ្មែរ ឬជាភាសាអង់គ្លេស។

### ២.២. ការបដិសេធ និងការកែតម្រូវពាក្យស្នើសុំចុះបញ្ជី

ការត្រួតពិនិត្យទៅលើទំរង់នៃការដាក់ពាក្យស្នើសុំចុំបញ្ជីម៉ាកគឺមានគោលដៅដើម្បីពិនិត្យលើរាល់ព័ត៌មានទាំងឡាយដែលមាននៅក្នុងពាក្យស្នើសុំ ដើម្បីឲ្យដឹងថាតើព័ត៌មានទាំងនោះត្រូវបានគេបំពេញបានគ្រប់គ្រាន់ដូចដែលបានកំណត់ក្នុងចំណុច (ក.២) "ការបំពេញគំរូពាក្យស្នើសុំ" ខាងលើដែរឬទេ។

ក្នុងករណីដែលមន្ត្រីកាន់កាប់បញ្ជីយល់ឃើញថាពាក្យស្នើសុំពុំមានព័ត៌មានគ្រប់គ្រាន់ទៅតាមអ្វីដែលច្បាប់បានកំណត់នោះទេ មន្ត្រីកាន់កាប់បញ្ជីនឹងជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការខ្វះខាត និងបង្គាប់ឲ្យម្ចាស់ម៉ាកធ្វើការកែតម្រូវ ឬបំពេញបន្ថែមលើចំណុចដែលខ្វះខាតពាក្យស្នើសុំចុះបញ្ជីនោះ ក្នុងរយៈពេល៩៥ (សែសិបប្រាំ) ថ្ងៃ។ ប្រសិនបើអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកពុំបានធ្វើការឆ្លើយតបក្នុងរយៈពេលដែលបានកំណត់ទេ ចាត់ទុកថាអ្នកដាក់ពាក្យស្នើសុំនោះលះបង់សិទ្ធិក្នុងការស្នើសុំចុះបញ្ជីម៉ាក[៣៤]។

## ផ្នែកទី២៖ ការត្រួតពិនិត្យខ្លឹមសារម៉ាក

### កថាភាគទី១៖ ការត្រួតពិនិត្យខ្លឹមសារដោយជោគជ័យ

នៅពេលដែលមន្ត្រីកាន់កាប់បញ្ជីទទួលពាក្យសុំចុះបញ្ជីនីមួយៗ គេត្រូវកត់ត្រានៅលើសំណុំឯកសារនៃពាក្យស្នើសុំចុះបញ្ជីម៉ាកនីមួយៗនូវកាលបរិច្ឆេទពិតប្រាកដ និងលេខរៀងនៃការដាក់ពាក្យស្នើសុំចុះបញ្ជីនោះ។ លើសពីនេះទៀតមន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យលើពាក្យស្នើសុំរួចហើយ ដោយអនុវត្តតាមមាត្រា៨ ចំនុច (ខ) នៃច្បាប់ស្តីពីម៉ាក មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យមើលនូវព័ត៌មានថា: គ្រប់គ្រាន់ និងត្រឹមត្រូវហើយឬនៅ។ មន្ត្រីកាន់កាប់បញ្ជីត្រូវពិនិត្យនូវចំណុចដូចខាងក្រោម៖

- ឈ្មោះរបស់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក
- អាសយដ្ឋានទំនាក់ទំនង
- គំរូម៉ាកដែលស្នើសុំចុះបញ្ជី
- យថាប្រភេទរបស់ទំនិញ ឬសេវាដែលស្នើសុំចុះបញ្ជីក្នុងចំណាត់ថ្នាក់នីមួយៗ
- កម្រៃនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកដែលតម្រូវសម្រាប់ចំណាត់ថ្នាក់នីមួយៗនៃទំនិញ ឬសេវាដែលស្នើសុំចុះបញ្ជីម៉ាក

### ១. លិខិតទទួលស្គាល់ការចុះបញ្ជីម៉ាក

បន្ទាប់ពីបានត្រួតពិនិត្យពាក្យស្នើសុំចុះបញ្ជីសព្វគ្រប់រួចមក និងយល់ឃើញថាម៉ាកនោះពិតជាត្រឹមត្រូវតាមទំរង់ និងបែបបទខាងលើរួចហើយ មន្ត្រីកាន់កាប់បញ្ជីម៉ាកយល់ព្រមចុះបញ្ជីម៉ាក

[៣៤] មាត្រា១៧ ចំណុច១ នៃអនុក្រឹត្យលេខ ៦៤

នោះហើយ មន្ត្រីកាន់កាប់បញ្ជីត្រូវចុះបញ្ជីម៉ាក និងចេញវិញ្ញាបនបត្រនៃការចុះបញ្ជីម៉ាកជូនអ្នកដែលបានដាក់ពាក្យស្នើសុំចុះបញ្ជី ហើយត្រូវបោះពុម្ពផ្សាយការចុះបញ្ជីម៉ាកនោះ នៅក្នុងព្រឹត្តបត្រផ្លូវការរបស់ក្រសួងពាណិជ្ជកម្ម។

### ២. ភាតព្វកិច្ចបង់ថវិកា

យោងតាមមាត្រា៥ ចំនុច (ខ) នៃច្បាប់ស្តីពីម៉ាកបានចែងថា "ការសុំចុះបញ្ជីម៉ាក ការសុំប្តូរអាសយដ្ឋាននៃម្ចាស់ម៉ាក និងការបញ្ជាក់ឡើងវិញនូវការប្រើប្រាស់ ឬមិនប្រើប្រាស់ម៉ាកត្រូវបង់កម្រៃតាមការកំណត់នៅក្នុងសេចក្តីប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម។" ដូចនេះនៅពេលដែលមានការយល់ព្រមទទួលចុះបញ្ជីពីសំណាក់មន្ត្រីកាន់កាប់បញ្ជីរួចហើយម្ចាស់ម៉ាកត្រូវតែមានកាតព្វកិច្ចបង់ថ្លៃសេវានៃការចុះបញ្ជីម៉ាកនោះនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា។ តម្លៃនៃសេវាដែលត្រូវបង់នោះ គឺត្រូវកំណត់នៅក្នុងប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។

**តារាងស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម (នាយកដ្ឋានកម្មសិទ្ធិបញ្ញា)[៣៥]**

### កថាភាគទី២៖ ការត្រួតពិនិត្យខ្លឹមសារដែលមានបញ្ហា

ប្រសិនបើមន្ត្រីកាន់កាប់បញ្ជីបានពិនិត្យឃើញថាៈ ពាក្យស្នើសុំចុះបញ្ជីមិនទាន់បានបំពេញបានត្រឹមត្រូវនោះទេ ឬក៏មានចំណុចណាមួយដែលមិនសមស្របនឹងមាត្រា៨ ចំណុច (ខ) នៃច្បាប់ស្តីពីម៉ាក ឬក៏មានចំណុចណាមួយដែលត្រូវកែសម្រួលឡើងវិញ មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ម្ចាស់ម៉ាកអំពីមូលហេតុនៃការច្រានចោលនោះដោយភ្ជាប់នូវព័ត៌មានលំអិតទាំងអស់ដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចរបស់ខ្លួន ហើយស្នើឲ្យអ្នកដាក់ពាក្យស្នើសុំនោះធ្វើការកែតម្រូវពាក្យស្នើសុំចុះបញ្ជីរបស់ខ្លួន និងផ្ញើចម្លើយតបទៅមន្ត្រីកាន់កាប់បញ្ជីជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៩៥ថ្ងៃបន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងរបស់មន្ត្រីកាន់កាប់បញ្ជី។

### ១. ការកែតម្រូវ

ម្ចាស់ម៉ាកមានសិទ្ធិក្នុងការកែតម្រូវពាក្យស្នើសុំចុះបញ្ជីម៉ាករបស់ខ្លួនក្នុងរយៈពេល ៩៥ថ្ងៃ ប្រសិនផុតកំណត់រយៈពេល ៩៥ថ្ងៃនេះហើយម្ចាស់ម៉ាកនៅតែមិនព្រមកែតម្រូវពាក្យស្នើសុំរបស់ខ្លួននោះទេ មន្ត្រីកាន់កាប់បញ្ជីមានសិទ្ធិបដិសេធការចុះបញ្ជីម៉ាកនោះ[៣៦]។

ករណីដែលអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីបានឯកភាពគ្នាជាមួយនិងមន្ត្រីកាន់កាប់បញ្ជីរួច

[៣៥] សូមមើលឧបសម្ព័ន្ធទី៥

[៣៦] មាត្រា១០ ចំនុច (ខ) នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

ហើយ អ្នកស្នើសុំត្រូវតែជូនដំណឹងទៅមន្ត្រីកាន់កាប់បញ្ជីវិញជាលាយលក្ខណ៍អក្សរ ហើយធ្វើការកែតម្រូវពាក្យស្នើសុំរបស់ខ្លួនទៅតាមសេចក្តីជូនដំណឹងរបស់មន្ត្រីកាន់កាប់បញ្ជីម៉ាកខាងលើ។ ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីមិនយល់ស្របនឹងសេចក្តីជូនដំណឹងរបស់មន្ត្រីកាន់កាប់បញ្ជី ហើយមិនបានឆ្លើយតបតាមការកំណត់របស់មន្ត្រីកាន់កាប់បញ្ជីនោះអាចសន្មតបានថា: អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីបានបោះបង់ចោលពាក្យស្នើសុំចុះបញ្ជីម៉ាករបស់ខ្លួនហើយ[៣៧]។

### ២. នីតិវិធីដំណាក់កាលសវនាការ

នៅក្នុងករណីមួយទៀតប្រសិនបើអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកមិនយល់ស្រប មិនឯកភាព ឬចង់បដិសេធទៅនឹងសេចក្តីសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជី ម្ចាស់ម៉ាកមានសិទ្ធិដាក់ពាក្យស្នើសុំសវនាការមួយ ឬផ្តល់នូវការយល់ឃើញរបស់ខ្លួនជាលាយលក្ខណ៍អក្សរទៅមន្ត្រីកាន់កាប់បញ្ជីក្នុងរយៈពេល ៦០ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជី។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងរបស់អ្នកដាក់ពាក្យស្នើសុំបើកសវនាការ ហើយមន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកយ៉ាងយូរ ១ខែមុនការបរិច្ឆេទដែលអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកចូលក្នុងសវនាការ។

បន្ទាប់ពីមានសវនាការហើយ មន្ត្រីកាន់កាប់បញ្ជីនៅតែបដិសេធមិនព្រមទទួលចុះបញ្ជីហើយច្រានចោលពាក្យស្នើសុំចុះបញ្ជីនោះទៀត មន្ត្រីកាន់កាប់បញ្ជីត្រូវតែជូនដំណឹងអំពីសេចក្តីបដិសេធរបស់ខ្លួនជាលាយលក្ខណ៍អក្សរទៅអ្នកដាក់ស្នើសុំនោះ។ លើសពីនេះទៅទៀតអ្នកដាក់ពាក្យស្នើសុំមានសិទ្ធិទាមទារឲ្យមន្ត្រីកាន់កាប់បញ្ជីបញ្ជាក់ពីមូលហេតុ និងឯកសារដែលពាក់ព័ន្ធដែលមន្ត្រីកាន់កាប់បញ្ជីសម្រេចមិនព្រមចុះបញ្ជីក្នុងរយៈពេល ១ខែបន្ទាប់ពីទទួលបានសេចក្តីសម្រេច។

### ៣. នីតិវិធីដំណាក់កាលក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា

លើសពីនេះទៀតប្រសិនបើមន្ត្រីកាន់កាប់បញ្ជីនៅតែបដិសេធមិនព្រមទទួលចុះបញ្ជីដដែល អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីនៅតែមិនឯកភាពនឹងសេចក្តីសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជី អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីមានសិទ្ធិប្តឹងទៅក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ាក្នុងរយៈពេល៣ខែ គិតចាប់ពីថ្ងៃដែលគាត់ទទួលបានសេចក្តីសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជី។ ប្រសិនបើក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ានៅតែបដិសេធការចុះបញ្ជីនោះទៀត អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីមានសិទ្ធិប្តឹងតវ៉ានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយ វិវាទនោះ (នៅកម្ពុជាយើងមិនទាន់មានក្រុមប្រឹក្សា

---

[៣៧] មាត្រា១០ ចំនុច (យ) នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

ដោះស្រាយបណ្តឹងតវ៉ានៅឡើយទេ) អាចបន្តប្តឹងទៅតុលាការបន្តទៀត[៣៨]។

### ៤. បណ្តឹងទៅតុលាការមានសមត្ថកិច្ច

ក្រោយពីក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ានៅតែបដិសេធមិនព្រមទទួលចុះបញ្ជីដដែល អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីនៅតែមិនយល់ស្រប ឬមិនឯកភាព ឬចង់បដិសេធទៅនឹងការសម្រេច សេចក្តីរបស់ក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ានោះក្នុងរយៈពេល ៣(បី)ខែ គិតចាប់ពីថ្ងៃដែលចេញ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាបណ្តឹងតវ៉ា អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីមានសិទ្ធិប្តឹងទៅតុលាការ ដែលមានសមត្ថកិច្ចដើម្បីឲ្យតុលាការដោះស្រាយនូវពាក្យបណ្តឹងរបស់ខ្លួន។

## ផ្នែកទី៣៖ ការចេញវិញ្ញាបនបត្រចុះបញ្ជីម៉ាក

ការចេញវិញ្ញាបនបត្រចុះបញ្ជីម៉ាកត្រូវបានធ្វើនៅពេលមន្ត្រីកាន់កាប់បញ្ជីព្រមទទួលចុះបញ្ជី ម៉ាកនេះមានន័យថាៈ រាល់ម៉ាកសុំចុះបញ្ជី ដែលពុំមានការបដិសេធពីមន្ត្រីកាន់កាប់បញ្ជីម៉ាកនោះ គឺ ត្រូវបានចុះបញ្ជី ហើយការចុះបញ្ជីម៉ាកនេះវាមានអត្ថប្រយោជន៍ខ្លាំងណាស់ដល់ម្ចាស់ម៉ាក ជា ពិសេសវាអាចការពារពីការរំលោភបំពានពីសំណាក់អ្នកដទៃ និងការពារកុំឲ្យមានការក្លែងបន្លំ និង ការរំលោភម៉ាកយកមកប្រើប្រាស់ដោយគ្មានការអនុញ្ញាតពីម្ចាស់ម៉ាក។ នៅពេលដែលម៉ាកមួយត្រូវ បានចុះបញ្ជីហើយ ម៉ាកនោះគឺមានសុពលភាពរយៈពេល១០ឆ្នាំ គឺគិតចាប់ពីថ្ងៃដែលបានចុះបញ្ជី[៣៩]។ ប៉ុន្តែប្រសិនបើការចុះបញ្ជីម៉ាកនោះប៉ះពាល់ ឬក៏រំលោភបំពានដល់ផលប្រយោជន៍អ្នកដទៃ ឬផល ប្រយោជន៍ សាធារណៈជនដែលមានការពាក់ព័ន្ធ ដូចនេះគេអាចជូនដំណឹងទៅមន្ត្រីកាន់កាប់បញ្ជី ពីការជំទាស់របស់ខ្លួន ចំពោះការចុះបញ្ជីម៉ាកតាមបែបបទដែលឈរលើមូលដ្ឋាននៃ ការមិនបាន បំពេញតាមលក្ខខណ្ឌណាមួយនៃមាត្រា២ ចំណុច (ខ) មាត្រា៤ និងមាត្រា៥ និងបទបញ្ញាទាំងឡាយ ដែលពាក់ព័ន្ធក្នុងរយៈពេល៩០ថ្ងៃបន្ទាប់ពីមានការបិទផ្សាយក្នុងព្រឹត្តប័ត្រផ្លូវការ[៤០]។

### កថាភាគទី១៖ ការបោះផ្សាយនៅក្នុងព្រឹត្តិបត្រផ្លូវការ

គ្រប់ម៉ាកទាំងឡាយដែលបានចុះបញ្ជីនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា នឹងត្រូវបានផ្សព្វផ្សាយ ក្នុងព្រឹត្តិបត្រប្រចាំខែរបស់ក្រសួងពាណិជ្ជកម្ម។ ការផ្សព្វផ្សាយនេះមានគោលដៅជូនដំណឹងជាសា ធារណៈដល់បុគ្គលដែលពាក់ព័ន្ធអំពីវត្តមាននៃការចុះបញ្ជីម៉ាកនេះនៅកម្ពុជា។ ប្រសិនបើម្ចាស់ម៉ាក

---

[៣៨] មាត្រា៦២ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

[៣៩] មាត្រា១២ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

[៤០] មាត្រា១០ ចំនុច (គ) នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

ដែលបានចុះបញ្ជីរួចហើយ ឬបុគ្គលដែលពាក់ព័ន្ធផ្សេងទៀតយល់ឃើញថា: ម៉ាកដែលមន្ត្រីកាន់កាប់បញ្ជីអនុញ្ញាតចុះបញ្ជីនោះដោយមានលក្ខណៈភ័ន្តច្រឡំទៅនឹងម៉ាករបស់ខ្លួន គឺគាត់អាចដាក់ពាក្យ បណ្ដឹងដើម្បីសុំលុបម៉ាកនោះចេញពីបញ្ជីម៉ាកបាន។

### ១. ទម្រង់នៃព្រឹត្តិបត្រផ្លូវការ

៦ ព្រឹត្តិបត្រផ្លូវការនៃក្រសួងពាណិជ្ជកម្ម ក្រោយពីការសម្រេចទទួលចុះបញ្ជីដល់ម៉ាកដែលបានស្នើសុំចុះបញ្ជីនោះរួចមក ក្រសួងពាណិជ្ជកម្ម (តាមរយៈមន្ត្រីកាន់កាប់បញ្ជីម៉ាក) មានកាតព្វកិច្ចក្នុងការប្រកាសផ្សាយនូវសេចក្ដីសម្រេចរបស់ខ្លួនអំពីការចុះបញ្ជីម៉ាកទៅក្នុងសៀវភៅ ព្រឹត្តិប័ត្រផ្លូវការណ៍របស់ក្រសួង។ នៅក្នុងន័យនេះក្រសួងពាណិជ្ជកម្មត្រូវបោះពុម្ពនៅក្នុងព្រឹត្តិបត្រផ្លូវការណ៍នូវគ្រប់ការចុះបញ្ជីការ ចុះបញ្ជីសាឡើងវិញ ការបដិសេធ ការលុបម៉ាកចេញពីបញ្ជី និងការងារផ្សេងៗទៀតដែលកំណត់ដោយអនុក្រឹត្យ[១]។ ការប្រកាសផ្សាយក្រោយពីការសម្រេចចុះបញ្ជីម៉ាកនេះពុំមែនមានន័យថា: ម៉ាកនោះត្រូវបានចុះបញ្ជី និងមានសុពលភាពនោះឡើយចាប់ពីថ្ងៃប្រកាសនេះឡើយ។ ប៉ុន្តែការប្រកាសផ្សាយ គឺគ្រាន់តែជាផ្នែកមួយនៃនីតិវិធីចុះបញ្ជីប៉ុណ្ណោះ ពោលគឺមានន័យថា: ម៉ាកដែលបានចុះបញ្ជីឲ្យដោយមន្ត្រីកាន់កាប់បញ្ជីត្រូវតែរង់ចាំបញ្ចប់នីតិវិធីប្រកាសផ្សាយនេះទៀតសិនទើបអាចចាត់ទុកថា: បានចុះបញ្ជីម៉ាកចប់សព្វគ្រប់ត្រឹមត្រូវទៅតាមច្បាប់។ ការពិតទៅការប្រកាសផ្សាយជាសាធារណៈនេះ គឺមានគោលបំណងសំខាន់ចង់បើកលទ្ធភាពឲ្យដល់តតិយជនទាំងឡាយដែលផលប្រយោជន៍របស់គាត់អាចនឹងត្រូវបានបំពានដោយសារសុពលភាពនៃអនាគតម៉ាកដែលនឹងត្រូវបានចុះបញ្ជីឲ្យនេះ អាចធ្វើការប្ដឹងប្រឆាំងជំទាស់នឹងការចុះបញ្ជីម៉ាកនោះនៅចំពោះមុខមន្ត្រីកាន់កាប់បញ្ជីម៉ាកនាពេលនោះតែម្ដង។ ហើយនេះក៏ជាយន្តការដ៏មានប្រសិទ្ធិភាពក្នុងការផ្ទៀងផ្ទាត់ភាពទំនេរនៃម៉ាក ដែលបានការពាររួចដោយម្ចាស់ម៉ាកដោយខ្លួនឯងប្រឆាំងទល់នឹងការយកទៅចុះបញ្ជីម្ដងទៀតដោយអ្នកផ្សេងផងដែរ។

### ២. អានុភាពនៃព្រឹត្តិប័ត្រផ្លូវការ

ក្នុងករណីដែលមន្ត្រីកាន់កាប់បញ្ជីរកឃើញថា: ការដាក់ពាក្យស្នើសុំរបស់ម្ចាស់ម៉ាកដែលសុំចុះបញ្ជីម៉ាក បានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌទាំងឡាយ ដែលមានចែងក្នុងមាត្រា៨ និងមាត្រា៩នោះរួចរាល់ហើយ មន្ត្រីកាន់កាប់បញ្ជីត្រូវចុះបញ្ជីម៉ាក និងចេញវិញ្ញាបនបត្រនៃការចុះបញ្ជីជូនអ្នកស្នើ សុំ និងចុះផ្សាយក្នុងប្រត្តិប័ត្រផ្លូវការរបស់ក្រសួងពាណិជ្ជកម្ម[២]។ រីឯមាត្រា១៩ នៃអនុក្រឹត្យស្ដីពី

---

[១] មាត្រា៥៥ នៃច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

[២] មាត្រា១០ ចំណុច "ក" នៃច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

ការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាមា និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់បានចែងផងដែរថា: ការដាក់ពាក្យស្នើសុំរបស់អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកមានលក្ខណ:ត្រឹមត្រូវតាមលក្ខខណ្ឌ ឬតាម កម្រិតណាមួយ ដែលជាលក្ខខណ្ឌរួចរាល់ហើយ នោះមន្ត្រីកាន់កាប់បញ្ជីត្រូវចុះបញ្ជីម៉ាក និងចេញ វិញ្ញាបនបត្រនៃការចុះបញ្ជីម៉ាកជូនអ្នកដាក់ពាក្យស្នើសុំចុះបញ្ជី ហើយត្រូវបោះពុម្ពផ្សាយការចុះបញ្ជី ម៉ាកនោះនៅក្នុងព្រឹត្តិបត្រផ្លូវការរបស់ក្រសួងពាណិជ្ជកម្ម[៤៣]។

## កថាភាគទី២៖ បណ្តឹងជំទាស់ម៉ាកដែលបានចុះបញ្ជីរួចហើយ

### ១. មូលដ្ឋាននៃបណ្តឹងជំទាស់

បណ្តឹងជំទាស់ដើម្បីលុបម៉ាកដែលបានចុះបញ្ជីរួច ត្រូវធ្វើឡើងដោយបុគ្គលពាក់ព័ន្ធក្នុងរយ:ពេល៩០ (កៅសិប)ថ្ងៃ បន្ទាប់ពីថ្ងៃចុះផ្សាយនៅក្នុងប្រត្តិប័ត្រផ្លូវការរបស់ក្រសួងពាណិជ្ជកម្ម[៤៤]។ ក្នុងករណីដែលភាគីពាក់ព័ន្ធពុំបានធ្វើបណ្តឹងលុបម៉ាកក្នុងរយ:ពេលកំណត់ខាងលើទេ ច្បាប់អនុញ្ញាតឲ្យបុគ្គលពាក់ព័ន្ធអាចធ្វើបណ្តឹងលុបម៉ាកដែលបានចុះបញ្ជីរួចដោយមូលហេតុដូចខាងក្រោម៖[៤៥]

➢. អ្នកសុំចុះបញ្ជីមិនបានដាក់ពាក្យស្នើសុំចុះបញ្ជីសាជាថ្មីនូវម៉ាកដែលបានចុះបញ្ជីរួចហើយតាមរយ:ពេលកំណត់[៤៦]។

➢. ប្រសិនបើមានភស្តុតាងបញ្ជាក់ថា: ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចហើយនោះមិនមែនជាម្ចាស់ម៉ាកស្របច្បាប់ ឬប្រសិនបើជឿជាក់ថា: ម៉ាកដែលបានចុះបញ្ជីរួចហើយមានលក្ខណ:ប្រហាក់ប្រហែល ឬដូចគ្នាទៅនឹងម៉ាកល្បីដែលជាកម្មសិទ្ធិរបស់តតិយជន។ ករណីនេះច្រើនកើតមានឡើងនៅពេលម្ចាស់ម៉ាកផ្តល់សិទ្ធិចែកចាយផលិតផលលើទីផ្សារ។ **ឧទាហរណ៍៖** កិច្ចសន្យាចែកចាយផលិតផល។ កិច្ចសន្យាចែកចាយផលិតផល គឺជាកិច្ចសន្យាមួយដែលអ្នកផ្តល់សិទ្ធិចែកចាយ (ម្ចាស់ម៉ាក) ផ្តល់សិទ្ធិឲ្យអ្នកទទួលសិទ្ធិចែកចាយ (តតីយជន) ដើម្បីប្រើប្រាស់ និងចែកចាយទំនិញ ដែលមានម៉ាករបស់ម្ចាស់ម៉ាកលើទីផ្សារនៃដែនដីណាមួយ។ នៅពេលបញ្ចប់កិច្ចសន្យាដោយមូលហេតុណាមួយ អ្នកទទួលសិទ្ធិចែកចាយបានយកម៉ាកដែលខ្លួនធ្លាប់បានចែកចាយទៅចុះបញ្ជីម៉ាកជាមួយមន្ត្រីកាន់កាប់បញ្ជី។ ក្នុងករណីនេះប្រសិនបើមន្ត្រីកាន់កាប់បញ្ជីបានអនុញ្ញាតឲ្យចុះបញ្ជីម៉ាកនោះ អ្នកផ្តល់សិទ្ធិចែកចាយ(ម្ចាស់ម៉ាក) មានសិទ្ធិប្តឹង។

---

[៤៣] មាត្រា១៩ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

[៤៤] មាត្រា១០ ចំណុច "គ" នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភ: ២០០២

[៤៥] មាត្រា១៤ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភ: ២០០២

[៤៦] មាត្រា១២ ចំណុច "ខ" នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភ: ២០០២ និងមាត្រា២២ ចំណុចទី១ នៃអនុក្រឹត្យលេខ៦៤

### ២. នីតិវិធីក្នុងការបណ្ដឹងជំទាស់

បណ្ដឹងជំទាស់អាចត្រូវបានធ្វើឡើងដោយម្ចាស់ម៉ាកដែលបានចុះបញ្ជីមុនគេក្នុងការប្ដឹងតតិយជន ដើម្បីប្រឆាំងជំទាស់នឹងការចុះបញ្ជីម៉ាក។

នីតិវិធីនៃការធ្វើបណ្ដឹងប្រភេទនេះ គឺត្រូវធ្វើឡើងចំពោះមុខមន្ត្រីចុះបញ្ជី ពុំមែនធ្វើនៅតុលាការ មានសមត្ថកិច្ចនោះទេ ហើយនីតិវិធីនេះក៏ត្រូវបានចែងច្បាស់នៅក្នុងមាត្រា១០ នៃច្បាប់ស្ដីពីម៉ាកផងដែរ។ មាត្រា១០ ចំណុច (គ) បានចែងអំពីការបង្កើតនូវអាជ្ញាយុកាល ៩០ថ្ងៃ បន្ទាប់ពីបានចុះផ្សាយក្នុងព្រឹត្តិប័ត្រផ្លូវការរបស់ក្រសួងពាណិជ្ជកម្មរួចមកសម្រាប់បើកលទ្ធភាពដល់បណ្ដឹងជំទាស់នឹងការចុះបញ្ជីម៉ាករបស់ជនទាំងឡាយណាដែលមានការពាក់ព័ន្ធផលប្រយោជន៍ក្នុងការចុះបញ្ជីនេះ។ ផុតរយៈពេល៩០ (កៅសិប) ថ្ងៃនេះ ការចុះបញ្ជីម៉ាកនឹងត្រូវបានចាត់ទុកថាមានសុពលភាព ហើយបណ្ដឹងជំទាស់ណាមួយដើម្បីប្រឆាំងនឹងម៉ាកដែលមានសុពលភាពនេះបានគឺមានតែបណ្ដឹងសុំមោឃភាពម៉ាកនោះចោលតែប៉ុណ្ណោះ។

ក្នុងរយៈពេលកំណត់ ៩០(កៅសិប) ថ្ងៃនេះដែរ កាលបើមាននបណ្ដឹងជំទាស់ មន្ត្រីកាន់កាប់បញ្ជីត្រូវបញ្ជូនបន្ទាន់នូវសេចក្ដីជូនដំណឹងពីបណ្ដឹងនេះទៅអ្នកសុំចុះបញ្ជី ដើម្បីឲ្យអ្នកស្នើសុំចុះបញ្ជីធ្វើការបញ្ជាក់នូវមូលដ្ឋានបង្អែកនៃការចុះបញ្ជីម៉ាករបស់ខ្លួន។ អវត្តមាននៃការឆ្លើយតបរបស់អ្នកស្នើសុំចុះបញ្ជីនឹងត្រូវចាត់ទុកថាៈ បានបោះបង់ការចុះបញ្ជីរបស់ខ្លួនចោលទៅវិញ[៤៧]។

ដោយឡែកនៅក្នុងករណី ដែលអ្នកសុំចុះបញ្ជីបានបញ្ជាក់មូលដ្ឋានស្របច្បាប់របស់ខ្លួនក្នុងការចុះបញ្ជីនេះមន្ត្រីកាន់កាប់បញ្ជីត្រូវផ្ដល់ឲ្យមានសវនាការមួយដើម្បីបានស្ដាប់នូវភាគីទាំងសងខាង និងធ្វើការពិចារណាលើពាក្យតវ៉ានេះ។ ក្នុងករណីនេះតួនាទីមន្ត្រីកាន់កាប់បញ្ជី គឺពុំមែនជាអ្នកសម្របសម្រួលនោះទេ ប៉ុន្តែគឺជាអ្នកមានសិទ្ធិសម្រេចតែម្ដង ថាតើត្រូវរក្សាការចុះបញ្ជីម៉ាកនេះទុក ឬត្រូវបដិសេធការចុះបញ្ជី[៤៨]។

កាលបើម៉ាកនោះត្រូវបានសម្រេចយល់ព្រមចុះបញ្ជីឲ្យដោយមន្ត្រីកាន់កាប់បញ្ជីម៉ាកនៃក្រសួងពាណិជ្ជកម្ម ម៉ាកនោះនឹងត្រូវបានចាត់ទុកថាទទួលបានកិច្ចការពារស្របច្បាប់។ កិច្ចការពារនេះនឹងអនុញ្ញាតឲ្យម្ចាស់ម៉ាក ដែលបានចុះបញ្ជីរួចមានសិទ្ធិផ្ដាច់មុខលើម៉ាកនោះក្នុងកំឡុងពេលកំណត់ណាមួយ។ សិទ្ធិផ្ដាច់មុខនេះដែលជាកម្មវត្ថុនៃការសិក្សាផងដែរ។

---

[៤៧] មាត្រា១០ ចំណុច "ឃ" នៃច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

[៤៨] មាត្រា១០ ចំណុច "ង" នៃច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

## កថាខណ្ឌទី៣៖ រយៈពេលការពារម៉ាកដែលបានចុះបញ្ជីជាស្ថាពរ

### ១. រយៈពេលការពារម៉ាកដែលបានចុះបញ្ជី

ជាទូទៅរយៈពេលនៃកិច្ចការពារម៉ាក ដែលបានចុះបញ្ជីរួចហើយនៅបណ្ដាលប្រទេសទាំងឡាយនៅលើពិភពលោកគឺមានរយៈពេល ១០ឆ្នាំ។ បើយោងតាមបទបញ្ញត្តិខាងលើ មាត្រា១២ នៃច្បាប់ស្តីពីម៉ាក បានកំណត់អំពីរយៈពេលការពារម៉ាកដែលបានចុះបញ្ជីរួចដែលមានរយៈពេលនៃសុពលភាព ១០(ដប់) ឆ្នាំ គឺគិតចាប់ពីការបរិច្ឆេទនៃការទទួលពាក្យស្នើសុំចុះបញ្ជីម៉ាក ហើយអាចចុះបញ្ជីសារជាថ្មីសម្រាប់រយៈពេល ១០(ដប់) ឆ្នាំម្ដងៗ ជាបន្តបន្ទាប់ដោយឥតកំណត់។

រីឯកិច្ចព្រមព្រៀង TRIPS មាត្រា១៨ ក៏តម្រូវឲ្យរដ្ឋសមាជិកនីមួយៗកំនត់នូវរយៈពេលជាក់លាក់នៃកិច្ចការពារម៉ាកនៅក្នុងច្បាប់ជាតិរបស់ខ្លួនដែលមានរយៈពេលយ៉ាងតិច៧ (ប្រាំពីរ)ឆ្នាំ។ បទបញ្ញត្តិនេះមានន័យ រយៈពេលសុពលភាពនៃម៉ាកអាចត្រូវបានកំណត់ដោយច្បាប់ជាតិចាប់ពី ៧ (ប្រាំពីរ) ឆ្នាំឡើងទៅ ហើយក៏អាចចុះបញ្ជីសារជាថ្មីបានដែរ[៤៩]។

### ២. ការសុំចុះបញ្ជីម៉ាកសាជាថ្មី

នៅក្នុងរយៈពេល៦ (ប្រាំមួយ) ខែមុនពេល ឬក្រោយពេលអស់សុពលភាពនៃម៉ាក ម៉ាកដែលបានចុះបញ្ជីរួចអាចត្រូវបានលុបចេញពីបញ្ជីម៉ាក ប្រសិនបើម្ចាស់ម៉ាកមិនបានដាក់ពាក្យស្នើសុំចុះបញ្ជីសាជាថ្មី[៥០]។

ជាគោលការណ៍ពាក្យស្នើសុំចុះបញ្ជីម៉ាកសាជាថ្មីនេះ អាចត្រូវបញ្ជូនទៅឲ្យមន្ត្រីកាន់កាប់បញ្ជីក្នុងរយៈពេល៦(ប្រាំមួយ) ខែមុនពេលផុតកំណត់សុពលភាពនៃម៉ាកដែលបានចុះបញ្ជីរួច។ ច្បាប់ម៉ាកក៏កំណត់អំពីរយៈពេលអនុគ្រោះដល់ម្ចាស់ម៉ាកដែលពុំបានដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកសាជាថ្មីក្នុងរយៈពេល៦ (ប្រាំមួយ) ខែចាប់ពីថ្ងៃអស់សុពលភាពនៃម៉ាក[៥១]។

លើសពីនេះទៅទៀតច្បាប់ម៉ាកនៃប្រទេសកម្ពុជាក៏ចែងអំពីអានុភាពប្រតិសកម្មផងដែរ ដោយអនុញ្ញាតឲ្យធ្វើការចុះបញ្ជីម៉ាកសារឡើងវិញ ដែលបានចុះបញ្ជីមុនពេលច្បាប់ចូលជាធរមាន (មុនឆ្នាំ២០០២)[៥២]។ ក្នុងករណីថ្លោះសិទ្ធិ ការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកសាជាថ្មីត្រូវចាត់ទុកថា: ម្ចាស់ម៉ាកបានបោះបង់សិទ្ធិលើម៉ាករបស់ខ្លួន។ ក្នុងករណីអនុវត្តទូទៅ ម្ចាស់ម៉ាកត្រូវជ្រើសរើសភ្នាក់ងារ

---

[៤៩] Article 18 of TRIPS – Terms of Protection: “Initial registration, and each renewal of registration, of a trademark shall be for a term of no less than seven years. The registration of a trademark shall be renewable indefinitely.”

[៥០] មាត្រា១២ "ខ" និង "ឃ" ,មាត្រា១៨ "ក" នៃច្បាប់ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

[៥១] Article 18 of TRIPS – Terms of Protection: “Initial registration, and each renewal of registration, of a trademark shall be for a term of no less than seven years. The registration of a trademark shall be renewable indefinitely.”

[៥២] មាត្រា១២ ចំណុច "គ" នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

តំណាងក្នុងការចុះបញ្ជីម៉ាកដែលមានគុណភាព និងគុណវឌ្ឍន៍ខ្ពស់ក្នុងការគ្រប់គ្រងទិន្នន័យ និងធ្វើបច្ចុប្បន្នភាពនៃម៉ាក ដែលបានចុះបញ្ជីរួច មកកាន់ម្ចាស់ម៉ាកឲ្យបានទាន់ពេលកំណត់[៥៣]។

[៥៣] ពាក្យស្នើសុំចុះឈ្មោះទទួលស្គាល់ជាផ្លូវការ ជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា និង ជីវប្រវត្តិសង្ខេប

# ជំពូកទី ៣

## សិទ្ធិនៃម្ចាស់ម៉ាក ការរំលោភម៉ាក

## និង

## យន្តការដំណោះស្រាយ

# ជំពូកទី៣
# សិទ្ធិនៃម្ចាស់ម៉ាក ការរំលោភម៉ាក និងយន្តការដំណោះស្រាយ

## ផ្នែកទី១៖ សិទ្ធិទទួលបានពីការចុះបញ្ជីម៉ាក

### កថាភាគទី១៖ ការធ្វើអាជីវកម្ម

#### ១. ការប្រើប្រាស់ម៉ាកត្រូវមានការយល់ព្រមពីម្ចាស់ម៉ាក

ការប្រើប្រាស់ម៉ាក ដែលបានចុះបញ្ជីរួចហើយគឺត្រូវមានការយល់ព្រមពីម្ចាស់ម៉ាកជាមុនសិន[៥៤]។ ជាទូទៅរាល់ការប្រើប្រាស់ម៉ាកដោយពុំមានការអនុញ្ញាតពីម្ចាស់ម៉ាក អាចត្រូវបានគេចាត់ទុកថា: ជាអំពើរំលោភម៉ាក។ អំពើរំលោភសិទ្ធិនៃម្ចាស់ម៉ាកអាចត្រូវបានគេធ្វើឡើងជាច្រើនរូបភាព និងច្រើនសណ្ឋាន ដែលសុទ្ធសឹងត្រូវបានគេហាមឃាត់ និងដាក់ទោសដោយច្បាប់ម៉ាកផងដែរ លើសពីនេះទៅទៀត ច្បាប់ម៉ាកនៃប្រទេសកម្ពុជាបញ្ញត្តិអំពីវិធានការសម្របសម្រួលមួយចំនួនដែលម្ចាស់ អាចធ្វើបានដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្លួន។

ក្នុងន័យទូទៅ អំពើរំលោភបំពានសិទ្ធិលើម៉ាកត្រូវបានកំណត់ថាជាការប្រើប្រាស់ម៉ាកគ្រប់រូបភាពដោយពុំមានការអនុញ្ញាតជាមុនពីម្ចាស់ម៉ាក។ នៅក្នុងក្របខណ្ឌនៃការអនុវត្តច្បាប់ម៉ាក អំពើរំលោភបំពានម៉ាកអាចកើតមានឡើងតាមបីរូបភាពដូចជា៖ ការក្លែងបន្លំម៉ាក ការធ្វើត្រាប់តាមម៉ាក និងការប្រើប្រាស់ម៉ាកគេដោយគ្មានការអនុញ្ញាត។ ផលិតផលដែលកើតចេញពីអំពើខាងលើនេះត្រូវបានគេចាត់ទុកថាជាទំនិញដែលពាក់ម៉ាកក្លែងក្លាយ។

#### ២. សិទ្ធិប្តឹងទៅតុលាការ

ច្បាប់ម៉ាកកំណត់អំពីវិធានការសម្របសម្រួលមួយចំនួនដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសរំលោភម៉ាក។ វិធានការទាំងនោះរួមមាន៖ វិធានការតាមមាត់ច្រកព្រំដែន និងវិធានការបណ្តោះអាសន្ន។ ក្នុងករណីនេះម្ចាស់ម៉ាក ឬអ្នកទទួលសិទ្ធិស្របច្បាប់ពីម្ចាស់ម៉ាកអាចធ្វើពាក្យបណ្តឹងទៅរដ្ឋបាលគយ និងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ។

ប្រសិនបើពិនិត្យឃើញថា ទំនិញដែលត្រូវបានហាមឃាត់នោះជាទំនិញ ដែលជាទំនិញមានការរំលោភទៅលើម្ចាស់សិទ្ធិលើម៉ាក និងមានភស្តុតាងគ្រប់គ្រាន់ រដ្ឋបាលគយ និងរដ្ឋាករត្រូវកសាងសំណុំរឿងទៅតុលាការ។ លើសពីនោះទៀត អាជ្ញាធររដ្ឋបាលគយ និងរដ្ឋាករមានសិទ្ធិបំផ្លាញទំនិញទាំងនោះតាមរយៈសេចក្តីសម្រេចរបស់តុលាការ[៥៥]។

---

[៥៤] មាត្រា១១ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

[៥៥] មាត្រា៦៩ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

## កថាភាគទី២៖ ការផ្តល់អាជ្ញាប័ណ្ណចំពោះម៉ាក

### ១. កិច្ចសន្យាទូទៅ (កិច្ចសន្យាអនុប្បទាន) និង កិច្ចសន្យាអាជ្ញាប័ណ្ណ

#### ១.១. កិច្ចសន្យាទូទៅ (កិច្ចសន្យាអនុប្បទាន)

កិច្ចសន្យាអនុប្បទាន ជាកិច្ចសន្យាផ្ទេរសិទ្ធិកម្មសិទ្ធិលើវត្ថុអរូបិយ (សិទ្ធិ) រវាងអនុប្បទានី (ម្ចាស់សិទ្ធិ) និងអនុប្បទានិក (អ្នកទទួលសិទ្ធិ)។ សញ្ញាណនៃកិច្ចសន្យាអនុប្បទានពុំត្រូវបានកំណត់នៅក្នុងច្បាប់ម៉ាកទេ ប៉ុន្តែប្រសិនបើមើលទៅលើប្រតិបត្តិការនៃកិច្ចសន្យាអនុប្បទាន វាពុំមានចរិតលក្ខណៈខុសពីកិច្ចសន្យាទិញលក់ឡើយ។

ការផ្ទេរម៉ាកអាចត្រូវបានធ្វើឡើងដោយការផ្ទេរជាមួយសហគ្រាស ជាមួយមូលនិធិពាណិជ្ជកម្ម ឬដាច់ដោយឡែក។ ជាគោលការណ៍ម៉ាកអាចបញ្ជាក់អំពីគុណភាពនៃទំនិញ ឬសេវានៃសហគ្រាស ប៉ុន្តែក្រោមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន ការផ្ទេរម៉ាកមិនមែនមានន័យថា: អនុប្បទាយីមានកាតព្វកិច្ចធានាគុណភាពទំនិញរបស់អនុប្បទានិកឡើយ។ ដូចគ្នាដែរការផ្ទេរម៉ាកដែលត្រូវបានធ្វើឡើងជាមួយនឹងការផ្ទេរសហគ្រាស អនុប្បទាយីពុំមានកាតព្វកិច្ចធានាលើគុណភាពនៃទំនិញរបស់អនុប្បទានិកដែលប្រើប្រាស់ម៉ាកនោះឡើយ។ ដូច្នេះគូភាគីកំណត់ឲ្យបានជាក់លាក់នូវលក្ខខណ្ឌក្នុងកិច្ចសន្យាទាក់ទងនឹងសិទ្ធិ និងកាតព្វកិច្ចរបស់គូភាគីនៅក្នុងការអនុវត្តកិច្ចសន្យាអនុប្បទាននេះ។

ជាគោលការណ៍ កិច្ចសន្យាអាចធ្វើឡើងដោយកិច្ចព្រមព្រៀងរវាងគូភាគីដែលអាចត្រូវបានធ្វើឡើងក្នុងទម្រង់ជាលាយល័ក្ខអក្សរ ឬដោយផ្ទាល់មាត់។ យោងតាមមាត្រា៥៨ នៃច្បាប់ម៉ាកកិច្ចសន្យាអនុប្បទានត្រូវតម្រូវឲ្យធ្វើជាលាយល័ក្ខអក្សរដើម្បីទទួលបាននូវអានុភាពតតាំងជាមួយតតិយជន កិច្ចសន្យានេះត្រូវចុះបញ្ជីជាមួយមន្ត្រីកាន់កាប់បញ្ជីម៉ាក។ ការខកខានពុំបានចុះបញ្ជីកិច្ចសន្យាអនុប្បទាននៃម៉ាកពុំបណ្តាលឲ្យកិច្ចសន្យានេះមោឃៈទេ ប៉ុន្តែវាពុំអាចមានអានុភាពចំពោះតតិយជនឡើយ។ កិច្ចសន្យាអនុប្បទានម៉ាក នឹងត្រូវចាត់ទុកជាមោឃៈ ប្រសិនបើកិច្ចសន្យាអនុប្បទាននោះត្រូវបានធ្វើឡើងដោយមានវិការៈ (លក្ខណៈបោកបញ្ឆោត ឬបណ្តាលឲ្យមានការភ័ន្តច្រឡំ) ជាពិសេសចំពោះប្រភេទប្រភពដើម ដំណើរការផលិតកម្ម ចរិតលក្ខណៈ ភាពសមស្របនៃទំនិញ ឬសេវានៃម៉ាកនោះកំពុងប្រើប្រាស់ ឬបម្រុងនឹងប្រើប្រាស់[៥១]។

អនុប្បទានិកមានកាតព្វកិច្ចធានាមិនឲ្យមានការទាមទារសិទ្ធិលើម៉ាក ពីសំណាក់តតិយជន និងការប្រើប្រាស់ម៉ាកដែលមានលក្ខណៈដូច ឬស្រដៀងដែលធ្វើឲ្យមានការភ័ន្តច្រឡំដោយអនុប្បទាយីឡើយ។ ការហាមឃាត់នេះត្រូវកំណត់ក្នុងកិច្ចសន្យាអនុប្បទានខ្លួនឯង។ ម្យ៉ាងវិញទៀតអនុប្ប

---

[៥១] មាត្រា៥១នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

ទាយី ត្រូវហាមឃាត់ការអនុវត្តន៍នូវអំពើផ្សេងៗ ដែលអាចបណ្តាលឲ្យបាត់បង់ ឬកាត់តម្លៃនៃម៉ាក ដែលជាកម្មវត្ថុនៃកិច្ចសន្យា។ លើសពីនេះទៅទៀតកិច្ចសន្យាក៏ត្រូវកំណត់ផងដែរនូវកាតព្វកិច្ចរបស់អនុប្បទាយី មិនឲ្យធ្វើការប្រកួតប្រជែងជាមួយអនុប្បទានិក ក្នុងទីតាំងដែនដី ឬក្នុងពេលវេលាណាមួយជាក់លាក់ដើម្បីការពារផលប្រយោជន៍របស់ភាគីទទួលសិទ្ធិ។ ក្នុងលក្ខខណ្ឌបែបនេះ គឺអនុប្បទានអាចធ្វើអ្វីទៅតាមដែលកិច្ចសន្យាបានចែងនៅក្នុងកិច្ចសន្យាអនុប្បទាន។ ក្នុងលក្ខខណ្ឌដែលគូភាគីធ្វើខុសទៅនិងគោលការណ៍ដែលបានចែងគឺមានន័យថា: គូភាគីរំលោភទៅនិងកិច្ចសន្យា។ ហេតុនេះហើយបើមានការរំលោភកិច្ចសន្យាដែលស្តីពីម៉ាកនោះ គឺអ្នករំលោភកិច្ចសន្យានោះក៏កំពុងតែព្យាយាមធ្វើការរំលោភទៅលើម៉ាកដែរ។ ឧទាហរណ៍: ក្រុមហ៊ុនផលិតកុំព្យូទ័រម៉ាក Dell បានលក់សិទ្ធិឲ្យភាគីម្ខាងទៀតដើម្បីធ្វើការចរាចរណ៍នូវកុំព្យូទ័រម៉ាកនេះ។ ប្រសិនបើក្នុងកិច្ចសន្យាអនុប្បទានផ្តល់ឲ្យទៅភាគីមួយដែលធ្វើការលក់នូវផលិតផលផ្តាច់មុខត្រឹមតែមួយរយៈពេល (រយៈពេលមួយដែលបានកំណត់ក្នុងកិច្ចសន្យា)។ ដូច្នេះប្រសិនបើក្នុងករណីមួយដែលមានអ្នកនាំយកនូវទំនិញដូចគ្នាទៅនិងក្រុមហ៊ុនមួយនេះ ដែលបានទទួលសិទ្ធិផ្តាច់មុខក្នុងការនាំចូលផលិតផលរបស់ខ្លួនដែលមានលក្ខណៈដូចគ្នាទៅនឹងម៉ាកដែលទទួលសិទ្ធិផ្តាចមុខនោះ គេហៅថាការរំលោភសិទ្ធិផ្តាច់មុខ។ អាចនិយាយថាជនដែលនាំចូលលក់ ប្រកាសលក់ ឬមានបំណងដោយចេតនានូវទំនិញដែលមានម៉ាកត្រាប់ត្រាប់តាមគេត្រូវផ្តន្ទាទោស និងពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ដល់ ១ (មួយ) ឆ្នាំ ឬទោសណាមួយនៃទោសទាំងពីរនេះ[៥៧]។ បើច្បាប់ចែងថា: ការប្រើប្រាស់ដែលទាក់ទងទៅនិងទំនិញដែលប្រហាក់ប្រហែលគ្នា វាជាការរំលោភម៉ាក ដូច្នេះការនាំចូលនូវទំនិញដែលម៉ាកត្រាប់គេ គឺជាការរំលោភសិទ្ធិផ្តាច់មុខ ក៏ដូចជាការរំលោភម៉ាកផងដែរ។ ក្នុងលក្ខខណ្ឌបែបនេះមានន័យថា: ការប្រើប្រាស់នូវម៉ាកប្រហាក់ប្រហែល ឬការប្រើប្រាស់នូវម៉ាកដែលក្លែងក្លាយវាជាអំពើរំលោភម៉ាក។

### ១.២. កិច្ចសន្យាអាជ្ញាប័ណ្ណ

នៅក្នុងវិស័យពាណិជ្ជកម្ម អាជ្ញាប័ណ្ណលើម៉ាកត្រូវបានគេប្រើប្រាស់ជាច្រើនក្នុងកិច្ចន្យា។ កិច្ចសន្យាអាជ្ញាប័ណ្ណ គឺជាកិច្ចសន្យាមួយដែលម្ចាស់ម៉ាក (អ្នកផ្តល់អាជ្ញាប័ណ្ណ) បានយល់ព្រមប្រគល់សិទ្ធិធ្វើអាជីវកម្មមួយផ្នែក ឬទាំងមូលនៃម៉ាកទៅឲ្យតតិយជន (អ្នកទទួលអាជ្ញាប័ណ្ណ) ដោយទទួលបានមកវិញនូវតម្លៃតបស្នងសមមូលទៅនឹងការអនុវត្តសិទ្ធិរបស់តតិយជនលើម៉ាក។ អ្នកទទួលអាជ្ញាប័ណ្ណមានសិទ្ធិផ្តល់អាជ្ញាប័ណ្ណបាន លុះត្រាតែអ្នកទទួលអាជ្ញាប័ណ្ណត្រូវបានអនុញ្ញាតិដោយអ្នកផ្តល់

---

[៥៧] មាត្រា៦៦នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

អាជ្ញាប័ណ្ណនៅក្នុងកិច្ចសន្យាអាជ្ញាប័ណ្ណ។ កិច្ចសន្យាអាជ្ញាប័ណ្ណនេះមានដូចជា៖ កិច្ចសន្យាខ្វីយីហោ (Franchise Agreement) និងកិច្ចសន្យាជួញដូរម៉ាក។

### ១.២.១. កិច្ចសន្យាខ្វីយីហោ (Franchise Agreement)

កិច្ចសន្យាខ្វីយីហោ គឺជាបច្ចេកទេសក្នុងការផ្ទេរព័ត៌មាន ដែលទាក់ទងនឹងបច្ចេកវិទ្យាផ្ទេរចំណេះធ្វើវិស័យឧស្សាហកម្មរបស់ម្ចាស់សិទ្ធិទៅឲ្យអ្នកទទួលសិទ្ធិដើម្បីប្រើប្រាស់នូវព័ត៌មាន និងឧបករណ៍ទាំងនោះ ឬផលិតផលដាក់ក្នុងដីជាកំណត់មួយជាក់លាក់ ជាពិសេសទាក់ទងទៅនឹងផ្នែកចំណីអាហារ និងភេសជ្ជៈ។ ដូច្នេះយើងអាចឲ្យនិយមន័យនៃកិច្ចសន្យាខ្វីយីហោបានថា: ជាកិច្ចសន្យាមួយដែលម្ចាស់ម៉ាក (ម្ចាស់សិទ្ធិ) មានជំនាញធ្វើទាក់ទងនឹងផលិតផលដែលប្រើប្រាស់ម៉ាកនោះ ហើយយល់ព្រមផ្ទេរសិទ្ធិក្នុងការប្រើប្រាស់ម៉ាក និងយល់ព្រមផ្តល់នូវចំណេះធ្វើរបស់ខ្លួនដូចជា៖ ការប្រឹក្សាយោបល និងជំនួយផ្នែកពាណិជ្ជកម្មទៅឲ្យតតិយជន (អ្នកទទួលសិទ្ធិ) ដើម្បីធ្វើអាជីវកម្មលើម៉ាកនោះ និងទទួលបានមកវិញនូវផលចំណេញសមាមាត្រនឹងចំណូលដែលកើតចេញពីប្រតិបត្តិការពាណិជ្ជកម្មនៃម៉ាកនោះ នៅក្នុងទឹកដីណាមួយកំណត់។ ក្នុងកិច្ចសន្យាខ្វីយីហោនេះព័ត៌មាន ដែលទាក់ទងនឹងចំណេះដឹងនៃ ការប្រើប្រាស់ម៉ាកជាកម្មវត្ថុសំខាន់នៅក្នុងកិច្ចសន្យា។ កម្ពុជាពុំមានច្បាប់ពិសេសដែលកំណត់អំពីរបបគតិយុត្តគ្រប់គ្រងលើកិច្ចសន្យាខ្វីយីហោនេះទេ។ ដើម្បីការពារសិទ្ធិស្របច្បាប់របស់ខ្លួន ម្ចាស់ម៉ាកត្រូវកំណត់អំពីលក្ខខណ្ឌ និងវិសាលភាពនៃការអនុវត្តន៍សិទ្ធិរបស់អ្នកទទួលសិទ្ធិនៃម៉ាកឲ្យបានច្បាស់លាស់ក្នុងកិច្ចសន្យា។

#### ក. គោលបំណងនៃកិច្ចសន្យាខ្វីយីហោ

គោលដៅចំបងនៃកិច្ចសន្យាខ្វីយីហោ គឺដើម្បីអនុញ្ញាតឲ្យម្ចាស់ម៉ាកអាចបង្កើននូវអានុភាព និងសក្តានុពលនៃការប្រើប្រាស់ម៉ាករបស់ខ្លួនដល់អតិថិជនលើពិភពលោក និងបង្កើនអាជីវកម្មគំរូមួយក្នុងប្រទេសណាមួយជាក់លាក់ ដែលជាគោលដៅផ្នែកពាណិជ្ជកម្មរបស់ខ្លួន។ ចំពោះម៉ាកក្នុងការបង្កើតទីតាំងអាជីវកម្មថ្មីតាមរយៈការផ្តល់សិទ្ធិឲ្យតតិយជនប្រើប្រាស់ម៉ាក គឺជាមធ្យោបាយមួយដ៏ប្រសើរបំផុតក្នុងការពង្រីកអាជីវកម្មតាមតំបន់ភូមិសាស្ត្រដែលមានសក្តានុពលភាពផ្នែកសេដ្ឋកិច្ច ដោយពុំចាំបាច់មានដើមទុនច្រើន និងទទួលហានិភ័យខ្ពស់ចំពោះការបើកទីតាំងថ្មីនោះ។ ចំពោះអ្នកទទួលសិទ្ធិវិញគេអាចទទួលផលប្រយោជន៍ដែលមានស្រាប់ពីម្ចាស់ម៉ាក ដូចជាកេរ្តិ៍ឈ្មោះនៃម៉ាក បទពិសោធន៍ពីម្ចាស់ម៉ាក ចំណេះធ្វើ និងជំនាញការរបស់ម្ចាស់ម៉ាក។

#### ខ. ផលប្រយោជន៍នៃកិច្ចសន្យាខ្វីយីហោ

កិច្ចសន្យាខ្វីយីហោនេះផ្តល់ផលប្រយោជន៍ដែលមិនអាចស្មានទុកជាមុនដល់ម្ចាស់ម៉ាក និងអ្នកទទួលសិទ្ធិពីម្ចាស់ម៉ាក។

### ៦. ផលប្រយោជន៍ចំពោះម្ចាស់ម៉ាក

គួរកត់សម្គាល់ថានៅក្នុងកិច្ចសន្យាខ្ចីយីហោនេះពុំខុសពីអត្ថន័យនៃកិច្ចសន្យាខ្ចីប្រើទូទៅនោះទេ ពោលគឺថាៈ ម្ចាស់ម៉ាកនៅតែជាកម្មសិទ្ធិករលើម៉ាកនោះដដែល។ ក្រៅពីនេះម្ចាស់ម៉ាកអាចទទួលបាននូវផលប្រយោជន៍ផ្សេងៗទៀតពីកិច្ចសន្យាខ្ចីយីហោដូចតទៅៈ

➢ ការពង្រីកវិសាលភាពទីផ្សារផលិតលផល និងម៉ាកដោយពុំទទួលបាននូវហានិភ័យដែលអាចនឹងកើតមាននៅពេលចូលក្នុងទីផ្សារនៃទឹកដីណាមួយ។

➢ សិទ្ធិក្នុងការគ្រប់គ្រងប្រតិបត្តិការពាណិជ្ជកម្មពាក់ព័ន្ធនឹងការប្រើប្រាស់ម៉ាកដូចជាការគ្រប់គ្រងលើការហ្វឹកហ្វឺនបុគ្គលិក និងគុណភាពនៃផលិតផល ឬសេវារបស់អ្នកទទួលសិទ្ធិ។

➢ ពង្រីកវិសាលភាពនៃកេរ្តិ៍ឈ្មោះ ភាពល្បីល្បាញ និងសក្តានុពលភាពនៃម៉ាក (Brand)។

➢ ពុំមានការប៉ះពាល់ដល់ទំនុកចិត្តរបស់អ្នកប្រើប្រាស់ (សាធារណៈជន)។

➢ នៅតែជាកម្មសិទ្ធិករនៃម៉ាក និងសិទ្ធិលើកម្មសិទ្ធិបញ្ញាដែលពាក់ព័ន្ធ និងការប្រើប្រាស់សិទ្ធិនៃម៉ាក។

### ៦. ផលប្រយោជន៍ចំពោះអ្នកទទួលសិទ្ធិនៃកិច្ចសន្យាឲ្យខ្ចីយីហោ

អ្នកទទួលសិទ្ធិអាចទទួលបានផលប្រយោជន៍សេដ្ឋកិច្ចយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យាខ្ចីយីហោនេះ តាមរយៈការប្រើប្រាស់ម៉ាកក្នុងវិស័យពាណិជ្ជកម្មរបស់ខ្លួន។

➢ កាត់បន្ថយហានិភ័យនៃការបរាជ័យក្នុងការធ្វើពាណិជ្ជកម្មដោយហេតុថាៈ ការប្រើប្រាស់ម៉ាកដែលត្រូវបានអតិថិជនស្គាល់ស្រាប់ជាភស្តុតាងបញ្ជាក់ថាៈ អ្នកទទួលសិទ្ធិអាចទទួលបាននូវផលប្រយោជន៍ ផលចំណេញ សេដ្ឋកិច្ច និងភាពជោគជ័យពីការប្រើប្រាស់ម៉ាកនោះរួចហើយ។

➢ ទាញផលប្រយោជន៍ពីម៉ាកដែលល្បី ឬម៉ាកដែលសាធារណៈជនបានស្គាល់ស្រាប់។

➢ មានភាពងាយស្រួលក្នុងការទទួលបាននូវធនធាន និងជំនាញពីម្ចាស់ម៉ាក ឬម្ចាស់សិទ្ធិ។

➢ ទទួលបាននូវការហ្វឹកហ្វឺន និងជំនួយឧបត្ថមពីម្ចាស់ម៉ាក ឬម្ចាស់សិទ្ធិ។

➢ ទទួលបាននូវវិសាលភាពនៃកំលាំងសេដ្ឋកិច្ចតាមរយៈការទិញនូវសិទ្ធិទាំងមូលនៃម៉ាក។

## គ. កាតព្វកិច្ចចំបងៗនៅក្នុងកិច្ចសន្យាខ្ចីយីហោ

ក្នុងកិច្ចសន្យាខ្ចីយីហោ គូភាគីត្រូវកំណត់ឲ្យបានច្បាស់លាស់នូវសិទ្ធិ និងកាតព្វកិច្ចរបស់គូភាគី ជាពិសេសត្រូវកំណត់នូវចំណុចដូចខាងក្រោម។

***ចំពោះម្ចាស់ម៉ាក ឬអ្នកផ្តល់សិទ្ធិត្រូវមានកាតព្វកិច្ចដូចតទៅៈ***

➢ ផ្តល់នូវចំណេះដឹងផ្នែកពាណិជ្ជកម្មដល់អ្នកទទួលសិទ្ធិ ពិសេសព័ត៌មានទាក់ទងនឹងកម្មវត្ថុនៃកិច្ចសន្យា (ម៉ាក)។

- ផ្តល់នូវការណែនាំ ជំនួយការ និងវគ្គបណ្តុះបណ្តាលដល់អ្នកទទួលសិទ្ធិ។
- ផ្គត់ផ្គង់សំភារៈដែលទាក់ទងនិងផលិតផល ឬសេវាដល់អ្នកទទួលសិទ្ធិ។
- ផ្តល់សិទ្ធិផ្តាច់មុខដល់អ្នកទទួលសិទ្ធិដោយបញ្ជាក់អំពីវិសាលភាពនៃតំបន់ធ្វើពាណិជ្ជកម្ម រយៈពេលធ្វើពាណិជ្ជកម្ម និងបរិមាណនៃការធ្វើពាណិជ្ជកម្មលើម៉ាកនោះ។

***ចំពោះអ្នកទទួលសិទ្ធិត្រូវមានកាតព្វកិច្ចដូចតទៅ៖***

- បង់ថ្លៃសិទ្ធិដែលទទួលបានពីម្ចាស់សិទ្ធិ មធ្យោបាយនៃការបង់អាចត្រូវបានកំណត់ដោយគូភាគីនៃកិច្ចសន្យា។
- អនុវត្តតាមការណែនាំ ឬមគ្គុទេសរបស់ម្ចាស់សិទ្ធិ។
- ខិតខំធ្វើការផ្សព្វផ្សាយ និងអភិវឌ្ឍម៉ាកឲ្យកាន់តែល្បីបន្ថែមទៀត។

### ១.២.២. កិច្ចសន្យាជួញដូរម៉ាក

កិច្ចសន្យាជួញដូរម៉ាក គឺជាកិច្ចព្រមព្រៀងមួយដែលម្ចាស់ម៉ាកអនុញ្ញាតឲ្យតតិយជនប្រើប្រាស់ម៉ាក ឬសញ្ញាលើទំនិញ ឬសេវាកម្មជាក់លាក់។ ការប្រើប្រាស់នូវចរិតលក្ខណៈនៃ រូបសញ្ញា រូបភាព ឬចរិតលក្ខណៈថ្លៃប្រឌិតរូបភាពនោះនៅលើផលិតផល ឬសេវា។ ភាគច្រើនរូបភាពដែលយកមកចេញ ពីគំនូរខ្សែភាពយន្ត សៀវភៅរឿងព្រេង សៀវភៅគំនូរជីវចល ឬល្បែងកុំព្យូទ័រដែលមានចរិតលក្ខណៈ ពិសេស និងត្រូវបានគេស្គាល់ច្រើនដោយអ្នកប្រើប្រាស់ទូទៅ។

ក្រៅពីនេះយើងឃើញមានការអនុញ្ញាតឲ្យប្រើប្រាស់ម៉ាកនៅក្នុងកម្មវិធីផ្សព្វផ្សាយផ្សេងៗដូចជា៖ កម្មវិធីកីឡា ឬការប្រគុំតន្ត្រីផ្សេងៗ។ល។ ដើម្បីងាយស្រួលយល់ យើងអាចពិនិត្យមើលនៅក្នុងកម្មវិធីប្រកួតបាល់ទាត់ FIFA អូឡាំពិក ឬ FORMULA1 ដែលយើងឃើញមានម៉ាក និងរូបសញ្ញានៃផលិតផលជាច្រើនត្រូវបានដាក់តាំងដើម្បីបង្ហាញពីសក្តានុពលភាពនៃអាជីវកម្មរបស់ខ្លួន។

កិច្ចសន្យាជួញដូរម៉ាកមានផលប្រយោជន៍សម្រាប់ម្ចាស់ម៉ាកដូចតទៅ៖

- ជួយឲ្យអ្នកប្រើប្រាស់កាន់តែស្គាល់ម៉ាកតាមរយៈការដាក់តាំង និងផ្សព្វផ្សាយ។
- ជាឧបករណ៍ផ្សព្វផ្សាយទីផ្សារដែលមានប្រសិទ្ធភាពខ្ពស់។
- ពង្រីកវិសាលភាពនៅក្នុងទីផ្សារផលិតផល ឬសេវាពាក់ព័ន្ធផ្សេងទៀត។
- ទទួលផលប្រយោជន៍ច្រើន និងកាត់បន្ថយហានិភ័យទាប។
- កម្រិតនៃការទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចខ្ពស់នាពេលខាងមុខ។

ចំណុចចម្បងក្នុងកិច្ចសន្យាជួញដូរម៉ាកនេះ គឺពាក់ព័ន្ធនឹងការផ្សព្វផ្សាយនិងវិសាលភាពនៃការផ្សព្វផ្សាយ និងប្រើប្រាស់ចរិតលក្ខណៈនៃរូបភាពម៉ាកលើផលិតផលផ្សេងទៀតដែលជាគោលដៅនៃការធ្វើអាជីវកម្ម។

### ២. លក្ខណៈពិសេសនៃកិច្ចសន្យាអាជ្ញាប័ណ្ណចំពោះម៉ាក

#### ២.១. ការត្រួតពិនិត្យដោយមានប្រសិទ្ធភាព

ការផ្តល់អាជ្ញាប័ណ្ណចំពោះម៉ាក គឺត្រូវបានកំណត់ថាកិច្ចសន្យាអាជ្ញាប័ណ្ណណាមួយអំពីការចុះបញ្ជីម៉ាក ឬពាក្យស្នើសុំទទួលស្គាល់កិច្ចសន្យាអាជ្ញាប័ណ្ណនោះត្រូវចែងអំពីការត្រួតពិនិត្យដោយមានប្រសិទ្ធភាពពីសំណាក់អ្នកប្រគល់អាជ្ញាប័ណ្ណចំពោះគុណភាពទំនិញ ឬសេវារបស់អ្នកទទួលអាជ្ញាប័ណ្ណ ដែលម៉ាកនោះត្រូវបានប្រើប្រាស់។ ប្រសិនកិច្ចសន្យអាជ្ញាប័ណ្ណមិនបានចែងអំពីការត្រួតពិនិត្យគុណភាពនោះ មិនត្រូវបានអនុវត្តដោយមានប្រសិទ្ធភាពទេ កិច្ចសន្យាអាជ្ញាប័ណ្ណនោះនឹងត្រូវចាត់ទុកថាមិនបានការ[៥៨]។ ដូចនេះបើសិនជាមិនគោរពទៅតាមគោលការណ៍ខាងលើនោះទេនឹងត្រូវចាត់ទុកថា: ជាការរំលោភសិទ្ធិផ្តាច់មុខ។

#### ២.២. លក្ខណៈផ្សេងទៀតនៃកិច្ចសន្យាអាជ្ញាប័ណ្ណ

កិច្ចសន្យាអាជ្ញាប័ណ្ណមានលក្ខណៈពិសេសបីយ៉ាងគឺ៖ (ទី១) មានការកំណត់រយៈពេល (ទី២) កំណត់អំពីទីកន្លែង និង (ទី៣) កំណត់អំពីតម្លៃ។ កិច្ចសន្យានេះអាចរំលាយបានគ្រប់ពេលវេលា ប្រសិនបើវាគឺជាការប្រកួតប្រជែងមិនស្មោះត្រង់។ សកម្មភាពនៃការផ្តល់អាជ្ញាប័ណ្ណក៏អាចជះឥទ្ធិពលឲ្យមាននូវការប្រកួតប្រជែងផងដែរ។ ចំពោះករណីម៉ាកស្ថិតនៅដំណាក់កាលចុះបញ្ជីនាំឲ្យគាត់ធ្វើការផ្ទេរតាមរយៈកិច្ចសន្យាអាជ្ញាប័ណ្ណ។ សាធារណៈជនអាចនឹងត្រូវបានធ្វើឲ្យមានការភ័ន្តច្រឡំដោយសារតែទទួលស្គាល់ ឬអាជ្ញាប័ណ្ណរបស់ផលិតផល ឬសេវា ដោយបុគ្គលម្នាក់ ឬដោយអង្គការមួយ។ ក្នុងមាត្រា៦៦ ក៏បានចែងផងដែរថា: ជនណាដែលនាំចូល លក់ ប្រកាសលក់ ឬមានបំណងលក់ដោយចេតនានូវទំនិញដែលមានម៉ាកក្លែងបន្លំ ឬមានចេតនាផ្តល់សេវាចំពោះសេវាសញ្ញា ម៉ាកសមូហភាព ឬពាណិជ្ជនាមក្លែងបន្លំ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ដល់ ២០.០០០.០០០ (ម្ភៃលាន) រៀល និងត្រូវបានផ្តន្ទាទោស ដាក់ពន្ធធនាគារពី ១ (មួយ) ឆ្នាំដល់ ៥ (ប្រាំ) ឆ្នាំ ឬ ទោសណាមួយនៃទោសទាំងពីរ[៥៩]។

## ផ្នែកទី២៖ ការរំលោភលើម៉ាក និងយន្តការដោះស្រាយ

### កថាភាគទី១៖ ការរំលោភលើម៉ាក

ដោយប្រទេសកម្ពុជាយើងបានចូលជាសមាជិកនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ក៏ដូចជាអនុសញ្ញាទីក្រុងប៉ារីស កិច្ចព្រមព្រៀង Trips ជាដើម។ នៅក្នុងអនុសញ្ញាទីក្រុងប៉ារីស មាត្រា១០ ស្ទួន

[៥៨] មាត្រា១៩ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

[៥៩] មាត្រា៦៦ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

ចំណុច៣ បានកំណត់កាតព្វកិច្ចចំពោះរដ្ឋជាសមាជិកទាំងឡាយឲ្យធ្វើការហាមឃាត់រាល់សកម្មភាពទាំងអស់ដែលមានដូចជា៖ សកម្មភាពដែលបង្កើតឲ្យមានការភ័ន្តច្រឡំ ទោះបីជាបានបង្កើតដោយរបៀបណាក៏ដោយ ដែលកើតឡើងពីសកម្មភាពពាណិជ្ជកម្ម ឧស្សាហកម្មនៃអ្នកប្រកួតប្រជែង។ ដើម្បីខិតខំធ្វើទៅតាមសេចក្ដីបញ្ញត្តិរបស់កិច្ចព្រមព្រៀងទាំងឡាយដែលបានចែង កម្ពុជាក៏បានប្រឹងប្រែងយ៉ាងពេញទំហឹងក្នុងការអនុវត្តន៍វិស័យកម្មសិទ្ធិបញ្ញាឲ្យមានភាពរលូន ប្រទេសកម្ពុជាក៏បានបង្កើតឲ្យមានច្បាប់មួយចំនួនដើម្បីធ្វើការគ្រប់គ្រងទៅលើវិស័យនេះ ដែលច្បាប់ទាំងនោះរួមមាន៖ ច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ជាដើម ហើយជាក់ស្ដែងនៅក្នុងច្បាប់នេះក៏បានចែងអំពីការរំលោភបំពាន និងវិធានការនៃការដោះស្រាយវិវាទ ក្នុងករណីដែលមានការរំលោភម៉ាកកើតឡើងផងដែរ។ ដូច្នេះនៅពេលដែលមានការរំលោភម៉ាកកើតមានឡើងនៅក្នុងប្រទេសកម្ពុជា កម្ពុជាយើងដោះស្រាយវិវាទនោះ និងអនុវត្តទៅតាមវិធានការផ្សេងៗដែលមានចែងក្នុងច្បាប់កម្ពុជាដើម្បីបង្ការ និងបង្ក្រាបនូវអំពើរំលោភម៉ាកនៅកម្ពុជា។

### ១. ការប្រើប្រាស់ម៉ាកដោយគ្មានការយល់ព្រមពីម្ចាស់ម៉ាក

ការប្រើប្រាស់ម៉ាកដែលបានចុះបញ្ជីរួចត្រូវមានការយល់ព្រមពីម្ចាស់ម៉ាកជាមុនសិន[៦០]។ ការប្រើប្រាស់ម៉ាកគ្រប់រូបភាពដោយគ្មានការអនុញ្ញាតពីម្ចាស់ម៉ាកត្រូវបានគេចាត់ទុកថាៈ ជាអំពើរំលោភម៉ាក។ ការរំលោភសិទ្ធិនៃម្ចាស់ម៉ាកអាចត្រូវបានគេធ្វើឡើងច្រើនរូបភាព និងច្រើនសណ្ឋានសុទ្ធសឹងត្រូវបានហាមឃាត់ដូចជាតាមរយៈការនាំចូល ការលក់ ការប្រកាសលក់ ឬមានបំណងលក់[៦១] ហើយច្បាប់ម៉ាកនៃប្រទេសកម្ពុជាក៏បានបញ្ញត្តិអំពីវិធានការសមស្របមួយចំនួនដែលមានផ្នែកព្រហ្មទណ្ឌ និង/ឬ រដ្ឋប្បវេណីចំពោះអំពីការផ្សព្វផ្សាយពាណិជ្ជកម្មទំនិញដោយបញ្ញត្តិអំពើនៃប្រកាសលក់ត្រូវផ្ដន្ទាទោសតាមមាត្រា៦៦ នៃច្បាប់ម៉ាក។ ក្នុងន័យនេះការប្រកាសលក់អាចត្រូវបានធ្វើឡើងតាមរយៈមធ្យោបាយនៃការផ្សព្វផ្សាយគ្រប់ប្រភេទ។ ប៉ុន្តែចំពោះការប្រើប្រាស់ម៉ាកដោយពុំមានការអនុញ្ញាតពីម្ចាស់ម៉ាកក្នុងគោលដៅបម្រើផលប្រយោជន៍ផ្ទាល់ខ្លួន ពុំត្រូវចាត់ទុកថាជាអំពើរំលោភម៉ាកឡើយ។ ដូច្នេះការប្រើប្រាស់ផលិតផលជាលក្ខណៈឯកជន ការនាំចូលទំនិញដែលមិនមានលក្ខណៈពាណិជ្ជកម្ម ដែលដាក់នៅក្នុងអីវ៉ាន់ផ្ទាល់ខ្លួននៃអ្នកដំណើរ មិនត្រូវបានចាត់ទុកថាជាអំពើរំលោភម៉ាកទេ[៦២]។

---

[៦០] មាត្រា១១ នៃច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

[៦១] មាត្រា៦៦ នៃច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

[៦២] មាត្រា៤៧ នៃច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

### ២. ការក្លែងបន្លំម៉ាក

អំពើក្លែងបន្លំម៉ាក គឺជាប្រភេទមួយនៃអំពើរំលោភសិទ្ធិលើម៉ាកមួយដែលត្រូវហាមឃាត់ដោយច្បាប់ម៉ាក។ មាត្រា៦៤ នៃច្បាប់ម៉ាកពុំបានកំណត់អំពីនិយមន័យនៃការក្លែងបន្លំម៉ាកឡើយ ពោលគឺ ចែងតែអំពីទោសព្រហ្មទណ្ឌ និងទោសពិន័យលើអំពើក្លែងបន្លំម៉ាកតែប៉ុណ្ណោះ។ ជាទូទៅការក្លែងបន្លំម៉ាកអាចត្រូវបានធ្វើឡើងតាមពីររូបភាពដូចជា៖ ការផលិតឡើងវិញ និងការធ្វើត្រាប់តាមម៉ាកដែលបានចុះបញ្ជីរួចឡើងវិញ។

#### ២.១. ការផលិតឡើងវិញនៃម៉ាក

ការផលិតឡើងវិញនៃម៉ាក គឺសំដៅទៅលើការចម្លងដូចទាំងស្រុងទៅនឹងម៉ាកដែលត្រូវបានគេចុះបញ្ជីរួចហើយបានប្រើប្រាស់ ឬមានគោលដៅនៃការប្រើប្រាស់ ឬមានគោលដៅនៃការប្រើប្រាស់លើប្រភេទនៃទំនិញ ឬសេវាដូចគ្នា។ ការក្លែងបន្លំម៉ាកតាមរយៈការផលិតឡើងវិញត្រូវមានលក្ខខណ្ឌពីរគឺ៖ **(ទី១)** ម៉ាកដែលផលិតឡើងវិញនោះត្រូវបានប្រើប្រាស់លើប្រភេទទំនិញ ឬសេវាដូចគ្នាទៅនឹងប្រភេទទំនិញ ឬសេវានៃម៉ាក។ លក្ខខណ្ឌនេះងាយស្រួលក្នុងការពិចារណាដោយពិនិត្យទៅលើប្រភេទនៃទំនិញ ឬសេវានៃម៉ាកដែលបានចុះបញ្ជីរួចលើវិញ្ញាបនបត្រចុះបញ្ជីម៉ាក។ **(ទី២)** ចំពោះម៉ាកល្បី ការផលិតឡើងវិញនូវម៉ាកដែលបានចុះបញ្ជីរួចហើយប្រើប្រាស់លើប្រភេទទំនិញ ឬសេវាដូចគ្នា ឬប្រហាក់ប្រហែលគ្នា ឬដែលពាក់ព័ន្ធគ្នាក៏ដោយ ក៏អាចចាត់ទុកថាជាអំពើក្លែងបន្លំម៉ាកបានដែរ។ ក្នុងករណីនេះ ទោះបីជាចំណុចណាមួយនៃម៉ាកល្បីក៏អាចត្រូវបានចាត់ទុកថាជាការបន្លំដោយផ្នែកនៃម៉ាកល្បីដែរ។ ជាទូទៅករណីនេះច្រើនកើតមានចំពោះម៉ាកដែលជាបង្គុំនៃសញ្ញា ឬរូបភាព។

#### ២.២. ការធ្វើត្រាប់តាមម៉ាក

ការធ្វើត្រាប់តាមម៉ាកដែលបានចុះបញ្ជីរួច ជាអំពើរំលោភម៉ាកដែលត្រូវបានដាក់ទោសតាមមាត្រា៦៥ នៃច្បាប់ម៉ាក ប៉ុន្តែបញ្ញត្តិនេះមិនកំណត់អំពីនិយមន័យនៃការធ្វើត្រាប់តាមម៉ាកឡើយ។ ការធ្វើត្រាប់តាមម៉ាក គឺជាការផលិតឡើងវិញនូវម៉ាកដែលមានលក្ខណៈដូច ឬប្រហាក់ប្រហែលដែលធ្វើឲ្យមានការភ័ន្តច្រឡំដល់សាធារណៈជន។ ច្បាប់ម៉ាកពុំបានបញ្ជាក់ច្បាស់លាស់អំពីភាពខុសគ្នានៃការផលិតឡើងវិញ និងការធ្វើត្រាប់តាមម៉ាកឡើយ។

នៅក្នុងនីតិកម្មសិទ្ធិបញ្ញាបារាំង តុលាការបានធ្វើការបែងចែកភាពខុសគ្នារវាងសញ្ញាទាំងពីរតាមរយៈសេចក្តីសម្រេចដោយសង្កត់ធ្ងន់ទៅលើលក្ខណៈនៃម៉ាកដែលធ្វើឲ្យមានការភ័ន្តច្រឡំដល់សាធារណៈជនជាចំបង។ ដូច្នេះភាពស្រដៀងគ្នាដែលធ្វើឲ្យមានការភ័ន្តច្រឡំដល់សាធារណៈជនជាកត្តាចម្បងដើម្បីវិនិច្ឆ័យអំពីអំពើធ្វើត្រាប់តាមម៉ាក។ លក្ខណៈវិនិច្ឆ័យបែបនឹងត្រូវយកមកពិចារណា

លើគ្រប់ថ្នាក់នៃផលិតផល និងសេវាចំពោះការធ្វើត្រាប់តាមម៉ាកល្បី។

### ៣. ការច្រកផលិតផល

ការច្រកផលិតផល គឺសំដៅទៅលើការយកសំបកវេចខ្ចប់ដែលមានម៉ាកដែលបានចុះបញ្ជីរួចទៅច្រកដាក់ផលិតផលថ្មីដែលពុំមែនជាផលិតផលនៃម្ចាស់ម៉ាក។

ចំណុចនេះពុំត្រូវបានកំណត់នៅក្នុងច្បាប់ម៉ាករបស់ប្រទេសកម្ពុជាទេ ប៉ុន្តែនៅក្នុងការបកស្រាយនៃមាត្រា១១ នៃច្បាប់ម៉ាកក្នុងន័យទូលាយ អំពើនេះក៏អាចចាត់ទុកថាជាអំពើរំលោភម៉ាកផងដែរ។

## កថាភាគទី២៖ យន្តការដំណោះស្រាយ

### ១. វិធានការរដ្ឋបាល

#### ១.១. វិធានការតាមមាត់ច្រកព្រំដែន

ជាវិធានដែលអនុញ្ញាតឲ្យម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចហើយអាចធ្វើពាក្យបណ្ដឹងទៅរដ្ឋបាល គយ និងវដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធ ឬតុលាការឲ្យព្យួរទុកនូវការធ្វើបែបបទទំនិញណាដែលសង្ស័យថាមានម៉ាកក្លែងក្លាយដោយគ្រាន់តែបង្ហាញនូវភស្តុតាងច្បាស់លាស់ថា: គាត់ជាម្ចាស់នៃម៉ាកដែលបានចុះបញ្ជី[៦៣]។ វិធាននេះអនុញ្ញាតសម្រាប់តែម៉ាកដែលបានចុះបញ្ជីតែប៉ុណ្ណោះ នេះមានន័យថា: ប្រសិនបើម៉ាកនោះមិនបានចុះបញ្ជីទេ គឺមិនអាចធ្វើពាក្យបណ្ដឹងតាមវិធាននេះបាន ឡើយ។ ក្រៅពីម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចហើយក៏នៅមានបុគ្គលមួយចំនួនទៀតដែលអាចធ្វើ បណ្ដឹងបានផងដែរដូចជា៖ អ្នកដែលទទួលអាជ្ញាប័ណ្ណ ឬភ្នាក់ងារតំណាងស្របច្បាប់ដោយបង្ហាញនូវភស្តុតាងច្បាស់លាស់ថា: គាត់ជាម្ចាស់នៃម៉ាកដែលបានចុះបញ្ជី[៦៤]។

##### ១.១.១. សមត្ថកិច្ចតាមច្រកព្រំដែន

យោងតាមមាត្រា៣៥ នៃច្បាប់ស្ដីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់លេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី០៧ កុម្ភៈ ២០០២ បុគ្គលដែលជាអ្នកសមត្ថកិច្ចក្នុងការអនុវត្តនូវវិធានការតាមមាត់ច្រកព្រំដែនរួមមាន៖ រដ្ឋបាលគយ និងវដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចឬតុលាការ។ អាជ្ញាធរមានសមត្ថកិច្ចនៅទីនេះផ្អែកតាមមាត្រា៣៦ នៃអនុក្រឹត្យស្ដីពីការអនុវត្តន៍ច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ៦៤ អនក្រ/បក ចុះថ្ងៃទី២៩

---

[៦៣] មាត្រា៣៥ នៃច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

[៦៤] អនុក្រឹតស្ដីពីការអនុវត្តន៍ច្បាប់ស្ដីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ៦៤អនក្រ/បក, ២៩សីហា ២០០៧, មាត្រា៣៨, កថាខ័ណ្ឌទី១

សីហា ២០០៧ អាជ្ញាធរមានសមត្ថកិច្ចរួមមាន៖ អង្គភាពគយ និងរដ្ឋាករ នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហ័រណ អាហ័រណ និងបង្ក្រាបការក្លែងបន្លំដែលហៅកាត់ថា: កាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម និងនគរបាលមានសមត្ថកិច្ចនៃក្រសួងមហាផ្ទៃ។

### ១.១.២. ពាក្យបណ្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច

ពាក្យបណ្តឹងដែលបានលើកឡើងខាងលើនេះត្រូវធ្វើជាលាយល័ក្ខអក្សរ និងត្រូវភ្ជាប់មកជាមួយនូវ[៦៥] ៖

✍. វិញ្ញាបនប័ត្រចុះបញ្ជីម៉ាក។

✍. សេចក្តីថ្លែងពីមូលហេតុនៃការប្តឹង និងជាពិសេសភស្តុតាងដំបូងដែលបង្ហាញថា: ទំនិញនោះពិតជាពាក់ម៉ាកក្លែងក្លាយមែន។

✍. ពាក្យរៀបរាប់ដ៏ល្អិតល្អន់អំពីទំនិញដែលម៉ាករបស់វាត្រូវបានប្រើប្រាស់ ព្រមទាំងគំរូនៃផលិតផលពិតប្រាកដផងប្រសិនបើមានសំណូមពរ។

✍. ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង និងតំណាងរបស់គេដែលត្រូវរៀបរាប់ឲ្យបានសព្វគ្រប់តាមការកំណត់។

✍. លិខិតអនុញ្ញាតពីម្ចាស់ម៉ាកដែលបានចុះបញ្ជីប្រសិនបើពាក្យបណ្តឹនោះត្រូវបានដាក់ដោយតំណាងដែលទទួលសិទ្ធិ។

✍. កម្រៃរដ្ឋបាលតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ពាក្យបណ្តឹងនោះមានសុពលភាព៦០ (ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យបណ្តឹង។ បើផុតសុពលភាពនេះ អ្នកដាក់ពាក្យត្រូវធ្វើពាក្យបណ្តឹងឡើងវិញ បើសំណូមពរនៃការឃាត់ និងត្រួតពិនិត្យទំនិញនៅមាននៅឡើយ[៦៦]។

### ១.១.៣. ចំណាត់ការរបស់សមត្ថកិច្ចតាមច្រកព្រំដែន

#### ក. ការព្យួរទុកនូវបែបបទទំនិញ

##### ក.១.ការជូនដំណឹងអំពីការព្យួរទុក

ក្នុងរយៈពេល១០ ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលនូវពាក្យបណ្តឹង (របស់ម្ចាស់ម៉ាកដែលបានចុះរួចហើយ) រដ្ឋបាលគយ និងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងទៅអ្នកប្តឹងថា: ពាក្យបណ្តឹងរបស់ខ្លួនត្រូវបានទទួលស្គាល់ថា: ត្រឹមត្រូវ ឬបដិសេធ ឬមួយរក្សាទុកសម្រាប់ពិចារណា

---

[៦៥] មាត្រា៣៦ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

[៦៦] មាត្រា៣៦ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២,

នៅពេលក្រោយ[៦៧]។ រដ្ឋបាល និងរដ្ឋាករត្រូវជូនព័ត៌មានភ្លាមឲ្យម្ចាស់សិទ្ធិអំពីទីកន្លែង និងថ្ងៃដែលព្យួរទុកនូវការធ្វើបែបបទរបស់គយ និងរដ្ឋបាលគយ និងរដ្ឋាករ ក៏អាចស្នើឲ្យម្ចាស់សិទ្ធិផ្តល់នូវព័ត៌មានទាំង ឡាយណាដែលអាចធ្វើជាជំនួយក្នុងការអនុវត្តន៍នូវអំណាចរបស់ខ្លួនផងដែរ[៦៨]។

### ក.២. រយៈពេលនៃការព្យួរទុក

ក្នុងរយៈពេលយល់ព្រមតាមកម្មវត្ថុនៃពាក្យបណ្តឹងខាងលើនេះ រដ្ឋបាលគយ និងរដ្ឋាករត្រូវព្យួរ ទុកនូវការធ្វើបែបបទទំនិញដែលមានទាក់ទងទៅនឹងពាក្យបណ្តឹង។ ការព្យួរទុកនេះត្រូវនៅជាធរមានក្នុងរយៈពេលដំបូង និងក្នុងរយៈពេលដែលបានពន្យាមិនលើសពី ១០ (ដប់)ថ្ងៃនៃថ្ងៃធ្វើការ[៦៩]។ បន្ទាប់មករដ្ឋបាលគយ និងរដ្ឋាករត្រូវជូនព័ត៌មានភ្លាមទៅអ្នកនាំចូល និងអ្នកប្តឹងអំពីការព្យួរទុកនូវការធ្វើបែបបទទំនិញដោយបញ្ជាក់ពីមូលហេតុនៃការព្យួរទុក ទន្ទឹមជាមួយគ្នានោះដែររដ្ឋបាលគយ និងរដ្ឋាករ ត្រូវបញ្ជាក់នូវឈ្មោះ និងអាសយដ្ឋាននៃអ្នកប្តឹងដល់អ្នកនាំចូលផងដែរ។

ក្រោយពីទទួលបានដំណឹងអំពីការព្យួរទុកនូវការធ្វើបែបបទទំនិញ អ្នកប្តឹងមានរយៈពេល ១០ (ដប់) ថ្ងៃនៃថ្ងៃធ្វើការដើម្បីផ្តួចផ្តើមបន្តចំណាត់ការដែលឈានទៅដល់ការសម្រេចនូវអង្គសេចក្តីនៃករណីនេះ។ ក្នុងករណីសមស្របរយៈពេលនេះអាចត្រូវបានពន្យាពេល១០ថ្ងៃទៀតនៃថ្ងៃធ្វើការ[៧០]។ កាលបើក្នុងរយៈពេលដូចដែលបានកំណត់នេះ រដ្ឋបាលគយ និងរដ្ឋាករបានទទួលនូវព័ត៌មានថាៈ ចំណាត់ការដែលនាំដល់ការសម្រេចនូវអង្គសេចក្តីនៃករណីនេះមិនត្រូវបានផ្តួចផ្តើមឡើងដោយភាគីមួយទៀត ផ្សេងពីចុងចម្លើយ ឬថាអាជ្ញាធរដែលបានប្រគល់សិទ្ធិត្រឹមត្រូវ មិនអនុវត្តនូវវិធានការបណ្តោះអាសន្នដើម្បីពន្យាការដោះលែងទំនិញទេ ទំនិញនោះនឹងត្រូវដោះលែងតែក្នុងករណីដែលលក្ខខណ្ឌផ្សេងៗទៀតសម្រាប់ការនាំចូល ឬនាំចេញត្រូវបានគោរព។ ផ្ទុយទៅវិញប្រសិនបើចំណាត់ការដែលនាំឲ្យមានការសម្រេចនូវអង្គសេចក្តីនៃករណីត្រូវបានផ្តួចផ្តើមឡើង ការពិនិត្យឡើងវិញមានទាំងការធ្វើសវនាការផង ដែលត្រូវបានរៀបចំឡើងតាមការស្នើសុំពីសំណាក់ចុងចម្លើយ ដើម្បីសម្រេចក្នុងរយៈពេលមួយសមស្របថាតើវិធាននេះត្រូវតម្កល់កែតម្រូវ ឬលុបចោល។

---

[៦៧] មាត្រា៣៧ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/ ០០៦,០៧ កុម្ភៈ ២០០២,

[៦៨] មាត្រា៥៤ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

[៦៩] មាត្រា៣៩ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

[៧០] មាត្រា៤០ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

### ក.៣. សិទ្ធិត្រួតពិនិត្យ និងសិទ្ធិទទួលព័ត៌មាន

រដ្ឋបាលគយ និងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀតអាចអនុញ្ញាតឲ្យម្ចាស់សិទ្ធិ អ្នកនាំចូល ឬអ្នកនាំចេញពិនិត្យនូវទំនិញដែលបានឃុំទុកតាមបែបបទគយ និងដកហូតនូវគម្រូដើម្បីពិនិត្យសាកល្បង និងវិភាគក្នុងគោលបំណងបញ្ជាក់ឲ្យដឹងថាៈ ទំនិញនោះពាក់ម៉ាកក្លែងក្លាយ ឬមិនក្លែងក្លាយ។ ក្រោយពេលដែលពិនិត្យទំនិញ ហើយដឹងថាជាទំនិញពាក់ម៉ាកក្លែងក្លាយ រដ្ឋបាលគយ និងរដ្ឋាករ អាចជូនព័ត៌មានទៅម្ចាស់សិទ្ធិនូវឈ្មោះ និងអាសយដ្ឋាននៃអ្នកនាំចេញ អ្នកនាំចូល អ្នកទទួល និងបរិមាណទំនិញដោយមិនធ្វើឲ្យប៉ះពាល់ដល់ការការពារនូវព័ត៌សម្ងាត់ រដ្ឋបាលគយ និងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀត អាចផ្តល់ទៅឲ្យម្ចាស់សិទ្ធិនូវច្បាប់ចម្លងនូវឯកសារទំនិញទាំងនោះ ឬនូវព័ត៌មានដែលមាន ឬឯកសារដែលទាក់ទងនឹងការនាំចូល និងការនាំចេញនូវទំនិញប្រហាក់ ប្រហែលពីមុនដោយអ្នកនាំចូល ឬអ្នកនាំចេញដដែលនេះតាមសំណូមពររបស់ម្ចាស់សិទ្ធិ[៧១]។ អាជ្ញាធរសាធារណៈ និងមន្ត្រីទទួលបន្ទុកត្រូវបានលើកលែងពីការទទួលខុសត្រូវចំពោះវិធានការដោះស្រាយ ដោយសមស្របនៅពេលដែលសកម្មភាពទាំងនោះត្រូវបានធ្វើ ឬមានបំណងនឹងធ្វើដោយស្មោះត្រង់[៧២]។

### ក.៤.សំណងចំពោះអ្នកនាំចូល និងចំពោះម្ចាស់ទំនិញ

អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធមានសិទ្ធិសម្រេចឲ្យអ្នក ដែលប្តឹងសងទៅម្ចាស់អ្នកនាំចូល អ្នកនាំចេញ និងអ្នកទទួលទំនិញនូវបំណងសមស្របចំពោះការខូចខាតរបស់គេដែលបណ្តាលមកពីការឃាត់ទំនិញដោយមិនត្រឹមត្រូវ ឬការឃាត់ទុកទំនិញដែលបានដោះលែង។ ក្នុងករណីភាគីណាមួយ មិនយល់ព្រមតាមការកំណត់សេចក្តីសម្រេចនេះ ភាគីនោះមានសិទ្ធិប្តឹងទៅតុលាការ[៧៣]។

## ខ.ការបំផ្លាញនូវទំនិញដែលពាក់ម៉ាកក្លែងក្លាយ

ដោយមានសេចក្តីសម្រេចពីតុលាការ រដ្ឋបាលគយ និងរដ្ឋាករ និងអាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិបំផ្លាញចោលនូវទំនិញដែលពាក់ម៉ាកក្លែងក្លាយទាំងនោះ។ រដ្ឋបាលគយ និងរដ្ឋាករមិនត្រូវអនុញ្ញាតិឲ្យធ្វើការណែនាំចេញបន្តនូវទំនិញដែលម៉ាកក្លែងក្លាយ ឬដាក់ទំនិញនេះឲ្យនៅក្រោមនីតិ

---

[៧១] មាត្រា៤២ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

[៧២] មាត្រា៤៥ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

[៧៣] មាត្រា៤៦ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៧ កុម្ភៈ ២០០២

វិធីផ្សេងទៀតរបស់គេឡើយ[៧៤]។

### ១.២. យន្តការផ្ទៃក្នុងនៃក្រសួងពាណិជ្ជកម្ម

#### ១.២.១. ការិយាល័យដោះស្រាយវិវាទ

##### ក. ការិយាល័យចុះបញ្ជីម៉ាកពាណិជ្ជកម្ម

ការិយាល័យចុះបញ្ជីម៉ាកពាណិជ្ជកម្មក្រៅពីមានតួនាទីចុះបញ្ជីម៉ាកក៏មានតួនាទីដោះស្រាយវិវាទម៉ាកដូចដែលបានរៀបរាប់ខាងលើ។ ការិយាល័យនេះទទួលនឹងដោះស្រាយបណ្តឹងតវ៉ា និងបណ្តឹងជំទាស់មុនពេលម៉ាកត្រូវបានចុះបញ្ជី។ យោងតាមឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៧ បានឲ្យនិយមន័យ បណ្តឹងតវ៉ា គឺជាការប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចចុងក្រោយរបស់មន្ត្រីកាន់កាប់បញ្ជី ឬសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា។ ឧបសម្ព័ន្ធដដែលក៏បានឲ្យនិយមន័យនៃបណ្តឹងជំទាស់ថា: គឺជាបណ្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចរបស់មន្ត្រីកាន់ កាប់បញ្ជីក្នុងរយ:ពេល ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីការចុះបញ្ជីម៉ាកមួយត្រូវបានបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការ យោងតាមនិយមន័យនេះ ការិយាល័យវិវាទមានតួនាទីដោះស្រាយចំពោះតែបណ្តឹងជំទាស់ និងបណ្តឹងតវ៉ាមុនពេលដែលម៉ាកនោះត្រូវបានចុះបញ្ជីតែប៉ុណ្ណោះ។

##### ខ. ការិយាល័យវិវាទ

ការិយាល័យវិវាទ គឺជាការិយាល័យមួយចំណុះឲ្យនាយកដ្ឋានកម្មសិទ្ធិបញ្ញា[៧៥]។ ការិយាល័យនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីសម្របសម្រួល និងដោះស្រាយវិវាទកម្មសិទ្ធិបញ្ញាដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងពាណិជ្ជកម្មតាមនីតិវិធីរដ្ឋបាល។ យោងតាមប្រការ៧ នៃប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តិរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា, លេខ ២១១ MOC/SM, ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៧ បានកំណត់តួនាទីរបស់ការិយាល័យវិវាទដូចតទៅ៖

- ពិនិត្យ និងដោះស្រាយបណ្តឹងតវ៉ាក្នុងការលុបម៉ាក ការចុះបញ្ជីទំនិញដែលមានលក្ខណ:សម្គាល់ភូមិសាស្ត្រ និងការទទួលសិទ្ធិផ្តាច់មុខ
- ចេញលិខិតណែនាំតាមនីតិវិធីរដ្ឋបាល ចំពោះការរំលោភបំពានកម្មសិទ្ធិបញ្ញាដែលនាយកដ្ឋានទទួលបន្ទុក
- ពិនិត្យ និងដោះស្រាយវិវាទនៃការរំលោភបំពានម៉ាកទំនិញ ឬសេវាទំនិញដែលមានលក្ខណ:សម្គាល់ភូមិសាស្ត្រ ការទទួលស្គាល់សិទ្ធិផ្តាច់មុខ ការផ្តល់អាជ្ញាប័ណ្ណ និងសិទ្ធិធ្វើអាជីវកម្ម

---

[៧៤] ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា, លេខ២១១ MOC, SM ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៧, ប្រកាស៣។

[៧៥] ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា, លេខ ២១១ MOC, SM ចុះថ្ងៃទី១៨ ខកញ្ញា ឆ្នាំ២០០៧, ប្រការ៣

ជាពិសេស ព័ត៌មានសម្ងាត់ និងការសម្ងាត់ពាណិជ្ជកម្ម តាមនីតិវិធីរដ្ឋបាល

- សហការជាមួយអង្គភាពពាក់ព័ន្ធ មន្ទីរពាណិជ្ជកម្មខេត្ត ក្រុង ពិនិត្យធ្វើការអង្កេត និង បញ្ឈប់ការក្លែងបន្លំម៉ាក ទំនិញ ឬសេវា និងទំនិញដែលមានលក្ខណៈសម្គាល់ភូមិសាស្ត្រដែលមានទំនាស់នៅលើទីផ្សារ

- សហការជាមួយអង្គការពាក់ព័ន្ធ មន្ទីរពាណិជ្ជកម្មខេត្ត ក្រុង ពិនិត្យ និងដោះស្រាយវិវាទព័ត៌មានសម្ងាត់ ការសម្ងាត់ពាណិជ្ជកម្ម ការផ្តល់អាជ្ញាប័ណ្ណ និងសិទ្ធិធ្វើអាជីវកកម្មពិសេស

- សហការជាមួយអង្គការពាក់ព័ន្ធ មន្ទីរពាណិជ្ជកម្មខេត្ត ក្រុង ពិនិត្យ និងដោះស្រាយវិវាទផ្សេងៗទៀតដូចជា៖ ចំណេះដឹងប្រពៃណី ការបង្ហាញដែលមានលក្ខណៈវប្បធម៌ប្រពៃណី និងប្រភពធនធានបន្តពូជធម្មជាតិ

- រៀបចំបណ្តឹងឧទ្ធរណ៍ នៃករណីវិវាទកម្មសិទ្ធិបញ្ញា ដែលនាយកដ្ឋានគ្រប់គ្រង បញ្ជូន ទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា ឬតុលាការ

- ចូលរួមបំភ្លឺករណីវិវាទកម្មសិទ្ធិបញ្ញាដែលនាយកដ្ឋានគ្រប់គ្រងនៅតុលាការតាមការស្នើសុំពីចៅក្រម

- រៀបចំឯកសារផ្សព្វផ្សាយ និងកម្មវិធីផ្សេងៗស្តីពីការរំលោភបំពានកម្មសិទ្ធិបញ្ញាដើម្បីបង្កើនការយល់ដឹងជាសាធារណៈ និងកាត់បន្ថយការរំលោភបំពាន

- រៀបចំកត់ត្រា និងចងក្រងទិន្នន័យនៃវិវាទកម្មសិទ្ធិបញ្ញាទុកសិក្សាស្រាវជ្រាវវាយតម្លៃ និងដាក់ចេញគោលនយោបាយកម្មសិទ្ធិបញ្ញាថ្មី និងកាត់បន្ថយការរំលោភបំពានកម្មសិទ្ធិបញ្ញា

### ១.២.២. នីតិវិធីដោះស្រាយ

#### ក. ការដាក់ពាក្យបណ្តឹង

ការដាក់ពាក្យបណ្តឹងអំពីការប្តឹងជំទាស់ទៅនឹងម៉ាកដែលបានដាក់ពាក្យសុំចុះបញ្ជីប្តឹងជំទាស់នឹងម៉ាកដែលបានចុះបញ្ជីរួចហើយ ប្តឹងមោឃភាពដល់ការចុះបញ្ជីម៉ាក និងប្តឹងពីបទរំលោភ បំពានពាណិជ្ជសញ្ញា គឺត្រូវធ្វើទៅតាមដំណាក់កាលនៃនីតិវិធី ហើយពាក្យបណ្តឹង[៧៦] នេះត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ។

#### ក.១. ប្តឹងជំទាស់នឹងម៉ាកដែលបានដាក់ពាក្យសុំចុះបញ្ជី

ក្នុងពេលដែលមានពាក្យស្នើសុំចុះបញ្ជីច្រើនទាក់ទងនឹងម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែលគ្នាហើយត្រូវបានប្រើចំពោះទំនិញ ឬសេវាដូច ឬប្រហាក់ប្រហែលគ្នា ហើយបានដាក់ពាក្យស្នើសុំចុះបញ្ជីតាមពេលវេលាខុសគ្នា ឬក្នុងពេលជាមួយ ពេលនោះវិវាទមុខតែកើតមានឡើងដោយសារតែ

[៧៦] គំរូនៃពាក្យបណ្តឹងដែលមាននៅក្នុងឧបសម្ព័ន្ធទី៣

ពួកគេកាន់ជំហរចង់ចុះបញ្ជីម៉ាកនោះដូចគ្នា។ ក្នុងករណីនេះ យោងតាមប្រការ៩ នៃប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ការដោះស្រាយបណ្តឹងនៃវិវាទខាងលើ គឺជាសមត្ថកិច្ចរបស់ការិយាល័យចុះបញ្ជីម៉ាកពាណិជ្ជកម្ម។

### ក.២. ប្តឹងទាស់នឹងម៉ាកដែលបានចុះបញ្ជីរួច

យោងតាមមាត្រា១០ ចំណុច(គ) នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ចែងថា៖ "ក្នុងរង្វង់ ៩០ (កៅសិប)ថ្ងៃ បន្ទាប់បានចុះផ្សាយក្នុងប្រត្តិប័ត្រផ្លូវការ ហើយជនណា ដែលមានការពាក់ព័ន្ធអាចជូនដំណឹងទៅមន្ត្រីកាន់កាប់បញ្ជីពីការជំទាស់របស់ខ្លួនចំពោះការចុះបញ្ជីម៉ាកតាមបែបបទ ដែលបានកំណត់ដោយឈរលើមូលដ្ឋាននៃការមិនបានបំពេញតាមលក្ខខណ្ឌនៃមាត្រា២ ចំណុច(ក) មាត្រា៤ និងមាត្រា៥ និងបទបញ្ញាទាំងឡាយដែលពាក់ព័ន្ធ។" ក្នុងករណីនេះ យោងតាមមាត្រា៩ នៃប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ការដោះស្រាយបណ្តឹងនៃវិវាទខាងលើ គឺជាសមត្ថកិច្ចរបស់ការិយាល័យចុះបញ្ជីម៉ាកពាណិជ្ជកម្ម។

### ក.៣. ប្តឹងមោឃភាពដល់ការចុះបញ្ជីម៉ាក

យោងតាមមាត្រា១៣ (ក) នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ចែងថា៖ "ជនណា ដែលមានការពាក់ព័ន្ធអាចស្នើសុំមកក្រសួងពាណិជ្ជកម្មឲ្យផ្តល់មោឃភាពដល់ការចុះបញ្ជីម៉ាកបាន"។ ពាក្យស្នើសុំនេះអាចធ្វើបាន ទោះផុតរយៈពេល ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីការបោះពុម្ពផ្សាយក្នុងព្រឹត្តិបត្រផ្លូវការក៏ដោយ[៧៧]។

### ក.៤. ប្តឹងពីបទរំលោភបំពានពាណិជ្ជ ឬសេវាសញ្ញា

បើយោងតាមមាត្រា១១ ចំណុច (ខ) នៃច្បាប់ស្តីពីម៉ាកចែងថា៖ "ម្ចាស់ដើមនៃម៉ាកមានសិទ្ធិប្តឹងទៅតុលាការប្រឆាំងនឹងជនណាម្នាក់ដែលប្រើប្រាស់ដោយរំលោភនូវម៉ាករបស់ខ្លួនដោយគ្មានការយល់ព្រមពីម្ចាស់ដើម។ ម្ចាស់ដើមក៏មានសិទ្ធិក្នុងការប្តឹងផងដែរចំពោះតតិយជនដែលបានប្រើប្រាស់នូវសញ្ញាដែលប្រហាក់ប្រហែលទៅនឹងម៉ាកដែលខ្លួនបានចុះបញ្ជីរួចហើយនោះ ឬការប្រើប្រាស់ម៉ាកដែលទាក់ទិនទៅនឹងទំនិញ និងសេវាដែលប្រហាក់ប្រហែលទៅនឹងទំនិញ ឬសេវានៃម៉ាកដែលបានចុះបញ្ជីរួចហើយនោះដែលអាចបណ្តាល់ឲ្យមានការភ័ន្តច្រឡំជាសាធារណៈ។" ក្នុងករណីនេះសមត្ថកិច្ចដែលត្រូវដោះស្រាយនោះ គឺជាសមត្ថកិច្ចដោះស្រាយរបស់ការិយាល័យវិវាទ។

ដើម្បីចោទប្រកាន់ទង្វើមួយជាការរំលោភបំពានម៉ាកត្រូវបង្ហាញឲ្យឃើញនូវចំណុចដូចខាង

---

[៧៧] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ លេខ៦៩អនក្រ/បក, ២៩ សីហា ២០០៧, មាត្រា២៩, កថាខ័ណ្ឌទី១

ក្រោមនេះ៖

១. ចុងចោទបានចរាចរដោយចេតនា ឬបានប៉ុនប៉ងធ្វើចរាចរទំនិញ (សេវា ឬស្លាកសញ្ញាឯកសារ ឬសំបកវិចខ្ចប់សម្រាប់ទំនិញ ឬសេវា)។

២. ចុងចោទបានប្រើប្រាស់ម៉ាកក្លែងក្លាយនៅលើ ឬមានទំនាក់ទំនងទៅនឹងទំនិញ ឬសេវាទាំងនោះ (ឬម៉ាកក្លែងក្លាយត្រូវបានបិទលើស្លាកសញ្ញា ឯកសារ ឬសំបកវិចខ្ចប់ទំនិញ ឬសេវា ទាំងនោះ) ដូចជា៖

- ម៉ាកក្លែងក្លាយជាម៉ាកមិនបរិសុទ្ធ ឬមិនត្រឹមត្រូវតាមច្បាប់។
- ម៉ាកក្លែងក្លាយ គឺជាម៉ាកមានលក្ខណៈដូចទៅ នឹង/ឬ ដែលមិនអាចញែកដាច់ពីម៉ាកបរិសុទ្ធ ដែលអ្នកផ្សេងទៀតបានធ្វើជាម្ចាស់ដើមរួចហើយ។
- ម៉ាកបរិសុទ្ធ គឺត្រូវបានគេចុះបញ្ជីក្នុងបញ្ជីដើមនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញាក្រសួងពាណិជ្ជកម្ម។
- ម៉ាកបរិសុទ្ធត្រូវបានកំពុងប្រើប្រាស់ដោយម្ចាស់ម៉ាក ឬអ្នកទទួលអាជ្ញាប័ណ្ណនៃម៉ាក។
- ម៉ាកក្លែងក្លាយត្រូវបានប្រើប្រាស់ទៅលើ ឬមានទំនាក់ទំនងទៅនឹងទំនិញ ឬសេវារបស់ចុងចោទ ម៉ាកក្លែងក្លាយត្រូវបានបិទលើ ឬប្រើប្រាស់ក្នុងទំនាក់ទំនងនឹងទំនិញ ឬសេវា ឬត្រូវបានបិទលើ ឬមាននៅក្នុងស្លាកសញ្ញា ឯកសារ ឬសំបកវិចខ្ចប់នៃប្រភេទ ឬចរិកលក្ខណៈណាមួយ។
- ម៉ាកក្លែងក្លាយត្រូវបានប្រើប្រាស់ក្នុងទំនាក់ទំនងទៅនឹងប្រភេទនៃទំនិញ ឬសេវាសម្រាប់ម៉ាកដែលបានចុះបញ្ជីការពារ ឬស្លាកសញ្ញាឯកសារ ឬសំបកវិចខ្ចប់ក្លែងក្លាយត្រូវបានរចនាឡើង ចរាចរ ឬបើមិនដូច្នេះទេមានចេតនាយកទៅប្រើប្រាស់លើ ឬក្នុងទំនាក់ទំនងទៅនឹងទំនិញ ឬសេវាសម្រាប់ម៉ាកដែលបានចុះបញ្ជីរួច។
- ម៉ាកក្លែងក្លាយត្រូវបានប្រើប្រាស់ក្នុងរបៀបមួយដែលទំនងជាបណ្តាលឲ្យមាន ការភ័ន្តច្រឡំបណ្តាលឲ្យមានកំហុស ឬក៏បំភ័ន្ត។

### ខ. ការពិនិត្យពាក្យបណ្តឹងជំទាស់ក្រោយចុះបញ្ជី

ការពិនិត្យពាក្យបណ្តឹងជំទាស់ក្រោយពេលចុះបញ្ជីគឺ ជាការពិនិត្យទៅលើ៖ ឈ្មោះអ្នកប្តឹងជំទាស់ ឬភ្នាក់ងារតំណាង អាសយដ្ឋានទំនាក់ទំនង ជំពូកទំនិញ ម៉ាក កាលបរិច្ឆេទដាក់ពាក្យ លេខដាក់ពាក្យ និងលេខចុះបញ្ជី។

### គ. ការជូនដំណឹងអំពីពាក្យបណ្តឹង

បន្ទាប់ពីបានទទួលពាក្យបណ្តឹងពីម្ចាស់ដើមនៃម៉ាក ការិយាល័យវិវាទត្រូវជូនដំណឹងពីការប្តឹង នេះទៅគូវិវាទ។ ស្របពេលជាមួយគ្នានេះដែរការិយាល័យតំរូវឲ្យភាគីទាំងសងខាងផ្តល់ឯកសារ

គាំទ្រ (Counter-statement) ដោយទុកឲ្យរយៈពេល៩៥ (សែសិបប្រាំ) ថ្ងៃ និងអាចពន្យាពេលថែម ៩៥ (សែសិប) ថ្ងៃបន្ថែមទៀត[៧៨]។

### ឃ. ការស្នើសុំបើកសវនាការ

មន្ត្រីកាន់កាប់បញ្ជីត្រូវចាត់ចែងឲ្យមានសវនាការ បើភាគីណាមួយ ឬភាគីទាំងពីរនៃជម្លោះស្នើសុំជាលាយលក្ខណ៍អក្សរឲ្យមានសវនាការមុនពេលចេញសេចក្តីសម្រេចណាមួយ ពាក្យស្នើសុំសវនាការនេះត្រូវធ្វើឡើងនៅមុនពេល ឬក្រោយពេល ០១ (មួយ) ខែ បន្ទាប់ពីថ្ងៃដាក់ពាក្យបណ្តឹង ឬឯកសារគាំទ្ររបស់ខ្លួនមកមន្ត្រីកាន់កាប់បញ្ជី។ ក្នុងករណីគ្មានពាក្យស្នើសុំសវនាការជាផ្លូវការតាមការកំណត់ខាងលើ តាមឆន្ទានុសិទ្ធិដែលផ្តល់ដោយមន្ត្រីកាន់កាប់បញ្ជីអាចចេញសេចក្តីសម្រេចរបស់ខ្លួនដោយគ្មានសវនាការ ឬបើយល់ឃើញថាចាំបាច់ត្រូវអញ្ជើញភាគីនៃជម្លោះទាំងសងខាងមកធ្វើសវនាការ[៧៩]។

នៅពេលទទួលបានសំណើសុំធ្វើសវនាការរួចហើយ មន្ត្រីកាន់កាប់បញ្ជីត្រូវជូនដំណឹងជាលាយលក្ខណ៍ អក្សរអំពីកាលបរិច្ឆេទនៃការបើសវនាការយ៉ាងតិច ០៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ មុនពេលបើកសវនាការទៅបុគ្គលដែលបានដាក់ពាក្យស្នើសុំធ្វើសវនាការ និងបុគ្គលដែលពាក់ព័ន្ធដទៃទៀត[៨០]។

### ១.២.៣. អានុភាពនៃសេចក្តីសម្រេច

ក្រោយពីមានសេចក្តីសម្រេចរបស់មន្ត្រីកាន់កាប់បញ្ជី អំពីការផ្តល់មោឃភាពនៃការចុះបញ្ជី ឬការរក្សាទុកការចុះបញ្ជី ឬមួយសេចក្តីសម្រេចឲ្យកែតម្រូវម៉ាកដែលបានចុះបញ្ជី បើភាគីណាមួយមិនយល់ព្រមនឹងសេចក្តីសម្រេចនោះ អាចប្តឹងតវ៉ាទៅក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ា [៨១] របស់ក្រសួងពាណិជ្ជកម្ម ឬប្តឹងទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល ០៣(បី) ខែ បន្ទាប់ពីចេញសេចក្តីសម្រេច[៨២]។ អនុលោមតាមមាត្រា៦២ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ភាគីមានផលប្រយោជន៍មានសិទ្ធិប្តឹងតវ៉ាអំពីសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដោះ

---

[៧៨] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/ ០២០២/០០៦,០៧ កុម្ភៈ ២០០២,មាត្រា ១០

[៧៩] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ៦៩អនក្រ/បក, ២៩ សីហា ២០០៧ ,មាត្រា៣២, កថាខ័ណ្ឌទី១

[៨០] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ៦៩អនក្រ/បក, ២៩ សីហា ២០០៧ ,មាត្រា៣២, កថាខ័ណ្ឌទី២

[៨១] ក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ាមិនទាន់មាននៅឡើយទេនៅកម្ពុជា។ យោងតាមអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ៦៩អនក្រ/បក, ២៩ សីហា ២០០៧, មាត្រា២៥, កថាខ័ណ្ឌទី៩

[៨២] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ៦៩អនក្រ/បក, ២៩ សីហា ២០០៧ ,មាត្រា២៥, កថាខ័ណ្ឌទី៧

ស្រាយបណ្តឹងតវ៉ារបស់ក្រសួងពាណិជ្ជកម្មទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល ០៣(បី) ខែ បន្ទាប់ពីថ្ងៃចេញសេចក្តីសម្រេច[៨៣]។ អនុលោមតាមមាត្រា៦២ ដដែលនេះនៅពេលដែលតុលាការសម្រេចលើបណ្តឹងតវ៉ាតម្រូវឲ្យលុបម៉ាកចេញពីបញ្ជី ឬរក្សាទុក ឬកែតម្រូវម៉ាកមន្ត្រីកាន់កាប់បញ្ជីត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ[៨៤]។

## ២. ដំណោះស្រាយតាមផ្លូវតុលាការ

### ២.១. វិធានការបណ្តោះអាសន្ន

ជាវិធានការបន្ទាន់ និងមានប្រសិទ្ធិភាពដែលចេញដោយតុលាការតាមសំណើរបស់អ្នកប្តឹងដែលបានប្តឹងទៅតុលាការរបស់ម្ចាស់ម៉ាក ឬអ្នកដែលទទួលសិទ្ធិស្របច្បាប់របស់ម្ចាស់ម៉ាកដើម្បីៈ

**ក. ទប់ស្កាត់ការរំលោភបំពានសិទ្ធិកម្មសិទ្ធិបញ្ញា** ដែលកំពុងតែកើតមាន ឬការរំលោភបំពាន ដែលបម្រុងនឹងកើតមានឡើង ហើយដើម្បីទប់ស្កាត់ការហូរចូលទំនិញក្នុងបណ្តាញពាណិជ្ជកម្ម ដែលមានស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនរួមទាំងទំនិញនាំចូលបន្ទាប់ពីការត្រួតពិនិត្យរបស់គេ[៨៥]។

**ខ. រក្សាទុកភស្តុតាងដែលពាក់ព័ន្ធចំពោះការរំលោភបំពានជាក់ស្តែង**[៨៦] ក្រោយពីធ្វើការឃាត់ទុកនូវភស្តុតាងទាំងឡាយហើយ និងធ្វើការរឹបអូសជាបណ្តោះអាសន្ននូវទំនិញនានាដើម្បីជានាមានការទូទាត់ត្រឹមត្រូវ[៨៧]។ ការរឹបអូស និងការឃាត់ទុកនេះក្នុងគោលដៅដើម្បីរក្សាឲ្យបាននូវផលប្រយោជន៍ម្ចាស់ដើមនៃម៉ាក ព្រោះក្នុងករណីនេះជាលក្ខខណ្ឌដ៏ល្អមួយដើម្បីឲ្យជឿជាក់ថាៈ រាល់ទំនិញដែលក្លែងបន្លំ និងការរំលោភម៉ាកនឹងមិនកើតឡើងក្នុងករណីដែលមានការត្រួតពិនិត្យ និងស្រាវជ្រាវបានច្បាស់លាស់។ នេះជាការពន្យាពេលដើម្បីធ្វើការសិក្សាស្រាវជ្រាវដើម្បីកុំឲ្យមានការរំលោភម៉ាកកើតឡើង។

### គ. ការពារព្យសនៈកម្មដែលមិនអាចជួសជុលបានចំពោះម្ចាស់ម៉ាក

#### គ.១. លក្ខខណ្ឌក្នុងចេញវិធានការបណ្តោះអាសន្ន

តាមសំណើរបស់អ្នកប្តឹងតុលាការមានអំណាចដាក់ចេញនូវវិធានការបណ្តោះអាសន្នជា

---

[៨៣] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ៦៩អនក្រ/បក, ២៩ សីហា ២០០៧, មាត្រា២៤, កថាខ័ណ្ឌទី៨

[៨៤] អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ៦៩អនក្រ/បក, ២៩ សីហា ២០០៧, មាត្រា២៤, កថាខ័ណ្ឌទី១០

[៨៥] កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា(TRIPS),១៩៩៤, មាត្រា ៥០, កថាខណ្ឌទី១(ក)

[៨៦] កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា(TRIPS),១៩៩៤, មាត្រា ៥០, កថាខណ្ឌទី១(ខ)

[៨៧] សៀវភៅកម្មសិទ្ធិបញ្ញា និងការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច ចំណុច (ខ) ទំព័រ ៧៨

បន្ទាន់ និងមានប្រសិទ្ធិភាពដើម្បីទប់ស្កាត់ការរំលោភ ការរំលោភដែលប្រុងនឹងកើតមាន ឬរក្សាទុកនូវភស្តុតាងដែលពាក់ពន្ធ[៤៨]។ អនុលោមតាមមាត្រា ៣០ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់នៅពេលចាំបាច់ជាពិសេសនៅពេលការយឺតយ៉ាវអាចបណ្តាលឱ្យមានភាពអន្តរាយដែលមិនអាចជួសជុលបានចំពោះម្ចាស់សិទ្ធិ ឬនៅពេលដែលមានភស្តុតាងអាចនឹងត្រូវបំផ្លាញតុលាការអាចដាក់ចេញនូវវិធានការបណ្តោះអាសន្ន ប្រសិនបើដើមចោទផ្តល់នូវៈ

- ភស្តុតាងត្រឹមត្រូវដែលមាន ដែលអាចធ្វើឱ្យតុលាការយល់ស្របក្នុងកម្រិតមួយគ្រប់គ្រាន់សម្រាប់សន្និដ្ឋានបញ្ជាក់ថាៈ ដើមចោទ គឺជាម្ចាស់ពិតប្រាកដហើយសិទ្ធិរបស់អ្នកប្តឹងកំពុងត្រូវបានគេរំលោភ ឬការរំលោភនោះអាចនឹងកើតមានឡើងក្នុងពេលឆាប់ៗ។

- ប្រាក់កក់ធានាដែលតម្រូវ ឬការធានាដែលមានតម្លៃស្មើនៃប្រាក់កក់គ្រប់គ្រាន់ក្នុងការការពារចុងចម្លើយ និងទប់ស្កាត់មិនឱ្យមានការរំលោភបំពាន។ ប្រាក់កក់ធានានេះ ត្រូវស្ថិតនៅក្រោមការកំណត់របស់តុលាការ ។

នៅពេលដែលវិធានការបណ្តោះអាសន្នត្រូវបានដាក់ចេញ តុលាការត្រូវជូនដំណឹងដល់ចុងចម្លើយអំពីសេចក្តីសម្រេចស្តីពីវិធានការបណ្តោះអាសន្ននោះ។ ក្នុងករណីនេះ ចុងចម្លើយអាចដាក់ពាក្យបណ្តឹងទៅកាន់តុលាការស្នើសុំឱ្យពិនិត្យវិធានការនោះឡើងវិញក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ[៤៩]។ តុលាការត្រូវផ្តល់នូវឱកាសសវនាការឱ្យដល់ភាគីដែលពាក់ពន្ធ័ ហើយត្រូវត្រួតពិនិត្យវិធានការនោះឡើងវិញ និងតម្កល់ កែតម្រូវ ឬលុបចោលនូវសេចក្តីសម្រេចរបស់ខ្លួនក្នុងរយៈពេលមួយសមស្របតាមច្បាប់កំណត់។

### គ.២. អានុភាពនៃវិធានការបណ្តោះអាសន្ន

នៅក្នុងរយៈពេល២០(ម្ភៃ)ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលដំណឹងអំពីការចេញនូវវិធានការបណ្តោះអាសន្ន ឬនៅក្នុងរយៈពេលមួយសមស្រប ដែលកំណត់ដោយតុលាការ នៅក្នុងសេចក្តីសម្រេចអំពីអង្គសេចក្តីនៃករណីតុលាការត្រូវលុបចោលនូវវិធានការបណ្តោះអាសន្ននោះចោលវិញដោយផ្អែកតាមសំណើររបស់ចុងចម្លើយ[៥០]។

---

[៤៨] មាត្រា ២៩ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនសោះត្រង់, លេខ នស/រកម/០២០២/ ០០៦,០៧ កុម្ភះ ២០០២

[៤៩] មាត្រា៣២ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនសោះត្រង់, លេខ នស/រកម/០២០២/ ០០៦,០៧ កុម្ភះ ២០០២

[៥០] មាត្រា៣៤ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនសោះត្រង់, លេខ នស/រកម/០២០២/ ០០៦,០៧ កុម្ភះ ២០០២

## ២.២. តុលាការមានសមត្ថកិច្ច និងទោសបញ្ញត្តិនៃការរំលោភម៉ាក

### ២.២.១. តុលាការពាណិជ្ជកម្ម

តុលាការពាណិជ្ជកម្មមានសមត្ថកិច្ចផ្តាច់មុខដើម្បីធ្វើសវនាការ និងសម្រេចដំបូងលើបណ្តឹង និងការជម្រះទៅលើបញ្ហាជាច្រើន ហើយនៅក្នុងនោះដែរ តុលាការពាណិជ្ជកម្មក៏មានការដោះស្រាយនូវបញ្ហានៃការប្រកួតប្រជែងមិនស្មោះត្រង់ និងការកំណត់ថ្លៃផងដែរ។

តុលាការពាណិជ្ជកម្មមានសមត្ថកិច្ចផ្តាច់មុខដើម្បីជំនុំជម្រះ និងសម្រេចជាលើកដំបូងដើម្បីទទួលស្គាល់ និងបង្ខំឲ្យអនុវត្តដីការតុលាការ។ ដីការបង្គាប់របស់តុលាការនោះរាប់បញ្ចូលដីការទាំងឡាយដែលបានផ្តល់ដោយតុលាការបរទេសទៅជនណាម្នាក់ និងអាចសំដៅដល់ដីការ សាលក្រម សេចក្តីសម្រេច ក្រឹត្យ សេចក្តីវិនិច្ឆ័យ ឬសេចក្តីសម្រេចស្តីពីចំណាយរបស់តុលាការ (មាត្រា២៥ នៃច្បាប់ស្តីពីតុលាការពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧)។

### ២.២.២. តុលាការនីតិរូម

ដោយតុលាការនីតិរូមនៃប្រទេសកម្ពុជាដោះស្រាយគ្រប់រឿងក្តីទាំងអស់ លើកលែងតែបទល្មើសយោធា ដូច្នេះវិវាទម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់បានផ្តល់ឱ្យនូវម្ចាស់ដើមនៃម៉ាកមានសិទ្ធិប្តឹងទៅតុលាការប្រឆាំងនឹងជនណាម្នាក់ ដែលប្រើប្រាស់ដោយរំលោភនូវម៉ាករបស់ខ្លួនដោយគ្មានការយល់ព្រមពីម្ចាស់ដើម។ ម្ចាស់ដើមក៏មានសិទ្ធិផងដែរចំពោះការប្រើប្រាស់នូវសញ្ញាដែលប្រហាក់ប្រហែលនឹងម៉ាកដែលខ្លួនបានចុះបញ្ជីរួចហើយ និងការប្រើប្រាស់ម៉ាកដែលទាក់ទិនទៅនឹងទំនេញ និងសេវាដែលប្រហាក់ប្រហែលទៅនឹងទំនិញ ឬសេវានៃម៉ាកដែលចុះបញ្ជីរួចហើយ នោះហើយដែលអាចបណ្តាលឱ្យមានការភន្តច្រឡំជាសាធារណៈ។ ដូច្នេះតុលាការនៃនីតិរូមមានសមត្ថកិច្ចដោះស្រាយរឿងក្តីនៃម៉ាកដូចគ្នាទៅនឹងរឿងក្តីទាំងឡាយ ដែលមិនមែនជាបទល្មើសយោធាយ៉ាងនោះដែរ។ ការធ្វើបណ្តឹងទៅតុលាការនេះ គឺរួមមានទាំងបណ្តឹងរដ្ឋប្បវេណី និងបណ្តឹងព្រហ្មទណ្ឌ។ ម្ចាស់ម៉ាកអាចធ្វើបណ្តឹងរដ្ឋប្បវេណីប្រសិនបើគាត់យល់ថាប្តឹងទាមទារត្រឹមតែសំណង។ តែបើគាត់យល់ថា: ចង់ផ្តន្ទាទោសជនប្រព្រឹត្តបទល្មើស គឺគាត់អាចធ្វើបណ្តឹងព្រហ្មទណ្ឌ រួចហើយគាត់អាចធ្វើបណ្តឹងរដ្ឋវេប្បវេណីតាមក្រោយក៏បាន។

យោងតាមមាត្រា៦២ នៃច្បាប់ដដែល រាល់សេចក្តីសម្រេចរបស់ក្រសួងពាណិជ្ជកម្មអាចជាកម្មវត្ថុនៃប្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចបាន ដោយភាគីជំទាស់ណាមួយ ហើយបណ្តឹងតវ៉ានេះត្រូវធ្វើក្នុងរយៈពេល ៣(បី) ខែ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច។ ផ្អែកតាមគោលការណ៍នៃមាត្រានេះក្នុងរយៈពេល៣(បី) ខែ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច ប្រសិនបើភាគីណាមួយមិនសុខចិត្តគាត់អាចធ្វើបណ្តឹងតវ៉ាទៅតុលាការបាន ។

**ឧទាហរណ៍៖** ដាក់ស្តែងសេចក្តីសម្រេចចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៩របស់នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម ស្តីពីការលុបចោលការចុះបញ្ជីលេខ ២៨៤១ សម្រាប់ម៉ាក Budweiser-Budvar ជំពូក៣១, ការចុះបញ្ជីលេខ :២៨៤២ សម្រាប់ម៉ាក Budweiser-Budvar ជំពូក ៣២, ការចុះបញ្ជីលេខ: ២៨៤៣ សម្រាប់ម៉ាក Budvar & Device ជំពូក៣២ និងការចុះបញ្ជីលេខ: ៥០៨៧សម្រាប់ម៉ាក Budweiser-Budvar& Device ជំពូក៣២ និងការចុះបញ្ជីលេខ:៩៧១៧ សម្រាប់ម៉ាកBudejovicky Budvar& Device របស់ក្រុមហ៊ុន National Budejovicky Budvar Corporation (BBNC) មានទីតាំងស្ថិតនៅ KarolinySvetle 4, 37021 Ceske Budejovice, Czech Republic ដែលក្នុងនោះភាគីម្ខាងទៀត ដែលជាអ្នកដាក់ពាក្យស្នើសុំលុប គឺក្រុមហ៊ុន Anheuser-Bush Incorprated (ABI) ។

សេចក្តីសម្រេចនេះត្រូវបានក្រុមហ៊ុន BBNC ដាក់ពាក្យប្តឹងសុំបដិសេធនូវសេចក្តីសម្រេចរបស់នាយកកដ្ឋានកម្មសិទ្ធិបញ្ញា ដែលបានលុបចោលស្លាកសញ្ញាចំនួន ០៥ ដូចដែលបានរៀបរាប់ពីខាងលើ។ ទាក់ទងនឹងករណីនេះឃើញថា: មានការប្តឹងជំទាស់រហូតដល់តុលាការកំពូល។ ចំពោះសាលក្រមលេខ:៥១ ″ធ″ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០០ របស់សាលាដំបូងរាជធានីភ្នំពេញបានសម្រេចតម្កល់សេចក្តីសម្រេច ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៩របស់នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជម្ម ស្តីពីពាណិជ្ជកម្ម ស្តីពីការលុបចោលការចុះបញ្ជី។ រីឯសាលដីការលេខ: ១៩១ "ឈ" ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍បានសម្រេចបដិសេធសាលក្រមលេខ ៥១ ″ធ″ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០០ របស់សាលាដំបូងរាជធានីភ្នំពេញ រួមទាំងសេចក្តីសម្រេចចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ១៩៩៩ របស់នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជកម្មស្តីពីការលុបចោលការចុះបញ្ជី។ ចំណែកឯ សាលាដីកាលេខ: ៥៨ចុះថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០០៥ របស់តុលាការកំពូលបានសម្រេចតម្កល់សាលាដីការដ្ឋវេណី: ១៩១ "ឈ" ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ទុកជាបានការទាំងមូល។

### ២.២.៣. ទោសបញ្ញតិនៃអំពើរំលោភម៉ាក

គ្រប់សកម្មភាពនៃការរំលោភម៉ាកដែលបានរៀបរាប់ខាងលើនេះ ត្រូវបានគេចាត់ទុកថាជាបទល្មើស ហើយបទល្មើសនេះមានទាំងផ្នែកព្រហ្មទណ្ឌ និងផ្នែករដ្ឋប្បវេណី។ ម្ចាស់ម៉ាកដែលបានចុះបញ្ជីនោះមានសិទ្ធិប្តឹងទាមទារសំណងរដ្ឋប្បវេណីផងដែរ។

#### ក. ទោសព្រហ្មទណ្ឌ

ការរំលោភម៉ាកគឺជាកម្មវត្ថុនៃទណ្ឌកម្មផ្នែកព្រហ្មទណ្ឌដែលត្រូវបានផ្តន្ទាទោសចំពោះអ្នក

ប្រព្រឹត្តបទល្មើសដូចជាពិន័យជាប្រាក់ផងដែរ។ យោងតាមមាត្រា៦៤ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើប្រកួតប្រជែងមិនស្មោះត្រង់បានចែងថា: ជនណាដែលក្លែងបន្លំពាណិជ្ជសញ្ញា សេវា សញ្ញាម៉ាកសមូហភាព ឬពាណិជ្ជនាមរបស់សហគ្រាសមួយផ្សេងទៀតដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជាដូចមានចែងនៅមាត្រា១១ នៃចំណុច (ខ) ពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ដល់ ២០.០០០.០០០ (ម្ភៃលាន) រៀល និងផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់៥ (ប្រាំ) ឆ្នាំ ឬទោសណាមួយនៃទោសទាំងពីនេះ[៦១]។ នេះមានន័យថា: ការរំលោភបំពានម៉ាកត្រូវស្ថិតនៅក្រោមការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌទៅតាមច្បាប់នេះ (មាត្រា៦៣ ដល់មាត្រា៦៨)។ ប៉ុន្តែក្នុងករណីការរំលោភម៉ាក ឬការរំលោភកម្មសិទ្ធិបញ្ញាភាគច្រើនត្រូវបានគេយកនូវដំណោះស្រាយជានីតិវិធីរដ្ឋប្បវេណីទៅវិញ បើទោះបីជាមានច្បាប់ចែងយ៉ាងជាក់លាក់ក៏ដោយ។ ករណីបទល្មើសព្រហ្មទណ្ឌអាចផ្តន្ទាទោសបានដោយការពិន័យជាប្រាក់រហូតដល់ ២៥ (ម្ភៃប្រាំ) លានរៀល ឬផ្តន្ទាទោសដាក់ពន្ធធនាគារពី ០១ (មួយ) ខែ ដល់ ០៦ (ប្រាំមួយ) ខែ។ ក្នុងករណីមិនរាងចាលហើយបានប្រព្រឹត្តបទល្មើសក្នុងរយៈពេល៥ឆ្នាំរាប់ចាប់ពីកាលបរិច្ឆេទនៃការផ្តន្ទាទោសលើកទី១មក ការផ្តន្ទាទោសនេះអាចកើតឡើងមួយជាពីរ។

### ខ. ទោសរដ្ឋប្បវេណី

សេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណី និងសេចក្តីព្រាងច្បាប់ស្តីពីកម្មសិទ្ធិបញ្ញាមួយចំនួនដែលបច្ចុប្បន្នកំពុងស្ថិតនៅក្នុងការរៀបចំ។ ក្រមរដ្ឋប្បវេណីមានដាក់បញ្ចូលនូវនីតិវិធីដែលទាក់ទិននឹងការវិនិច្ឆ័យរដ្ឋប្បវេណីការប្រតិបត្តិ និងវិធានការបណ្តោះអាសន្ននានា ហើយច្បាប់ស្តីពីកម្មសិទ្ធិនឹងមានចែងនូវបទបញ្ញត្តិនានាឧបាស្រ័យ និងវិធានការដោះស្រាយជាបណ្តោះអាសន្ន។ បើយោងតាមបទបញ្ញាថ្មី តុលាការរាប់ទាំងតុលាការខេត្ត ក្រុង មានសិទ្ធិអំណាចដោះស្រាយនូវរាល់ការរំបំពានម៉ាក និងការរំលោភកម្មសិទ្ធិផ្នែកកម្មសិទ្ធិបញ្ញា។ ហើយម្យ៉ាងទៀតរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីបានចែងអំពីការប្រគល់សិទ្ធិអំណាចតាមផ្លូវច្បាប់ឲ្យតុលាការដើម្បីចេញសេចក្តីសម្រេចសងការខូចខាតសម្រេចផ្តល់នូវចំនួនទឹកប្រាក់ជម្ងឺចិត្តចំពោះការខូតខាត និងវិធានការដោះស្រាយផ្សេងៗទោះជាគ្មានបទបញ្ញត្តិលំអិតក៏ដោយ។ ការទាមទារសំណងផ្នែករដ្ឋប្បវេណីគឺជាសិទ្ធិរបស់ម្ចាស់ម៉ាក ពីព្រោះច្បាប់ម៉ាកពុំបានចែងអំពីរូបមន្តដើម្បីកំណត់អំពីការទាមទារសំណងនោះឡើយ ហើយច្បាប់ក៏ពុំបានបិទសិទ្ធិរបស់ម្ចាស់ម៉ាកក្នុងការទាមទារសំណងលើការខូចខាតដែលកើតចេញពីអំពើរំលោភបំពានសិទ្ធិរបស់ម្ចាស់ម៉ាកដែរ។ ការទាមទារសំណងអាចត្រូវបានធ្វើឡើងដោយម្ចាស់ម៉ាកស្រប

[៦១] មាត្រា៦៤ នៃច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនសោះត្រង់, លេខ នស/រកម/០២០២/០០៦,០៧ កុម្ភៈ ២០០២

ច្បាប់ដោយផ្អែកទៅលើទំហំនៃព្យសនៈកម្ម និងភស្តុតាងបញ្ជាក់អំពីទំហំនៃព្យសនៈកម្មនោះ។

### ៦. ព្យសនៈកម្មចំពោះម្ចាស់ម៉ាកដែលកើតចេញពីការរំលោភម៉ាក

ម្ចាស់ម៉ាកដែលបានរំលោភលើម្ចាស់ម៉ាកដើមដែលបានចុះបញ្ជីរួចហើយ ម្ចាស់ម៉ាកដើមអាចទាមទារសំណងផ្នែករដ្ឋប្បវេណី ហើយសំណងនោះអាចត្រូវបានទូទាត់ដោយផ្អែកទៅលើការខូចខាតក្នុងបីតំណាក់កាលដូចជា៖ សំណងលើព្យសនៈកម្មជាក់ស្តែងនាពេលបច្ចុប្បន្ន សំណងលើព្យសនៈកម្មនាពេលអនាគត និងសំណងព្យសនៈកម្មគិតរាប់ចាប់ពីពេលដែលអំពើរំលោភបំពានកើតមានឡើង។ សំណងទាំងបីតំណាក់កាលនេះអាចទាមទារក្នុងពេលតែមួយតាមរយៈបណ្តឹងរបស់ម្ចាស់ម៉ាកទៅតុលាការ។

### ៦. សំណងលើព្យសនៈកម្មជាក់ស្តែងនាពេលបច្ចុប្បន្ន

អំពើរំលោភម៉ាកដែលត្រូវបានប្រព្រឹត្តិឡើងដោយជនរំលោភបំពាន ហើយបានបង្កឲ្យមានផលប៉ះពាល់ដល់ផលប្រយោជន៍របស់ម្ចាស់ម៉ាកដែលកំពុងធ្វើអាជីវកម្មលើទីផ្សារ។ មិនត្រឹមតែប៉ុណ្ណោះអំពើរំលោភម៉ាកបានធ្វើឲ្យម្ចាស់ម៉ាកស្របច្បាប់នោះ បានបាត់បង់នូវលទ្ធភាពនៃការប្រកួតប្រជែងលើទីផ្សារ ដោយអតិថិជនរបស់ខ្លួនបានបង្វែទិសដៅទៅប្រើប្រាស់ទំនិញក្លែងក្លាយ ដែលមានតម្លៃថោកជាងទំនិញរបស់ម្ចាស់ម៉ាកដើម។ ក្នុងករណីនេះម្ចាស់ម៉ាកដើមមានសិទ្ធិក្នុងការទាមទារសំណងទៅលើការខូចខាតដែលកំពុងតែកើតមានឡើង ដែលបណ្តាលមកពីការក្លែងបន្លំរបស់អ្នករំលោភបំពាននោះ។

### ៦. សំណងលើព្យសនៈកម្មនាពេលអនាគត

អំពើរំលោភបំពានលើម្ចាស់ម៉ាកស្របច្បាប់ មិនត្រឹមតែបង្កឲ្យមានព្យសនៈកម្មក្នុងអំឡុងពេលនៃការរកឃើញអំពើរំលោភបំពាននោះទេថែមទាំងបង្កឲ្យមានព្យសនៈកម្មនាពេលអនាគតផងដែរ។ ម៉ាកមានគោលដៅដើម្បីទាក់ទាញអតិថិជន និងទំនុកចិត្តរបស់អ្នកប្រើប្រាស់មកលើផលិតផលរបស់សហគ្រាស ឬបុគ្គលដែលជាម្ចាស់ម៉ាកនោះ។ កាលណាមានផលិតផលក្លែងបន្លំ ផលិតផលក្លែងបន្លំនោះ មិនត្រឹមតែធ្វើឲ្យម្ចាស់ម៉ាកដើមខាតបង់នូវរបរអាជីវកម្ម (ក្ស៊យធន) របស់ខ្លួនប៉ុណ្ណោះទេ គឺថែមទាំងបាត់បង់នូវទំនុកចិត្តអ្នកប្រើប្រាស់ទូទៅដែលកើតចេញពីការក្លែងបន្លំម៉ាករបស់អ្នករំលោភបំពាននោះ។

ការខាតបង់ទាំងនោះរួមមានដូចជា៖ ផ្នែកសេដ្ឋកិច្ច សំភារៈ និងជាពិសេសគឺទំនុកចិត្តរបស់អ្នកប្រើប្រាស់អាចត្រូវអូសបន្លាយដល់ទៅរាប់សិបឆ្នាំនាពេលអនាគតក៏មាន។ ក្នុងករណីនេះការខូចខាតដែលអាចកើតមាន និងអាចទូទាត់បាននាពេលអនាគតដែលជាកម្មវត្ថុនៃការទាមទារសំណងពីអ្នករំលោភបំពានដោយម្ចាស់ម៉ាកដើម។

### ៦. សំណងព្យសនៈកម្មគិតរាប់ចាប់ពីពេលដែលអំពើរំលោភបំពានកើតមានឡើង

ដូចគ្នានេះដែរប្រសិនបើអំពើរំលោភបំពាននោះត្រូវបានគេអនុវត្តអស់មួយរយៈពេលណាមួយនោះរហូតដល់ម្ចាស់ម៉ាកដើមបានដឹងអំពីអំពើនៃការរំលោភបំពាននោះ ម្ចាស់ម៉ាក គឺមានសិទ្ធិទាមទារសំណងទៅលើការខូចខាតសមមូលទាំងឡាយ ដោយគិតរាប់ចាប់ពីចំនុចចាប់ផ្តើមនៃអំពើរំលោភសិទ្ធិរហូតដល់ពេលដែលម្ចាស់សិទ្ធិស្របច្បាប់បានដឹង និងចាត់វិធានការរាំងខ្ទប់អំពើរំលោភសិទ្ធិនោះ។

### ៦. ភស្តុតាងបញ្ជាក់អំពីទំហំនៃព្យសនៈកម្មដែលកើតចេញពីអំពើរំលោភសិទ្ធិ

រាល់ការទាមទារសំណងលើព្យសនៈកម្មដូចដែលបានរៀបរាប់ខាងលើរួចមក គឺត្រូវធ្វើឡើងដោយម្ចាស់ម៉ាកតាមរយៈដាក់ពាក្យបណ្តឹងទៅតុលាការមានសមត្ថកិច្ច។ សេចក្តីសម្រេចរបស់តុលាការទៅលើការទាមទារសំណងនេះ គឺជាឆន្ទានុសិទ្ធិរបស់ចៅក្រមដោយផ្អែកទៅលើភស្តុតាងដែលបញ្ជាក់អំពីការខូចខាត ដែលជាកម្មវត្ថុនៃការទាមទាររបស់ម្ចាស់ម៉ាកដើម។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះក៏ជាដូចបានរៀបរាប់យ៉ាងក្បោះក្បាយពីខាងលើរួចមក អាចឲ្យយើងសន្និដ្ឋានបានថាៈ កិច្ចការពារម៉ាកពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ម្ចាស់សិទ្ធិនៃម៉ាកដែលបានចុះបញ្ជីរួចហើយនោះ ប្រសិនបើពុំមានកិច្ចការពារម៉ាកនោះទេ ម្ចាស់សិទ្ធិនឹងបាត់បង់ផលប្រយោជន៍ជាច្រើនដែលកើតចេញពីស្នាដៃរបស់ខ្លួនដែលខំប្រឹងប្រើប្រាជ្ញាស្មារតីដើម្បីច្នៃប្រឌិតឲ្យចេញជាផលិតផល ឬម៉ាកមួយរបស់ខ្លួនផ្ទាល់នោះ។ ដោយសារតែមានការរំលោភបំពានលើម៉ាករបស់ខ្លួន ទន្ទឹមនឹងនោះដែរក៏មានយន្តការដោះស្រាយអំពើរំលោភបំពាននៃម៉ាកនៅកម្ពុជាផងដែរ យន្តការដោះស្រាយវិវាទនេះពិតជាមានសារៈសំខាន់ណាស់សម្រាប់ការពារសិទ្ធិរបស់ម្ចាស់ម៉ាកដែលបានចុះបញ្ជី ឬមិនបានចុះបញ្ជី (សម្រាប់ម៉ាកល្បី) ហើយយន្តការដោះស្រាយវិវាទនេះមានដូចជាៈ ការបង្ក្រាបតាមរយៈវិធានការរបស់ក្រសួងដែលពាក់ព័ន្ធ និងតាមវិធានការតុលាការតែប៉ុណ្ណោះ។ នៅក្នុងយន្តការនៃកិច្ចការពារនេះ គឺក្រសួងពាណិជ្ជកម្មមិនអនុញ្ញាតឲ្យធ្វើការចុះបញ្ជីចំពោះម៉ាកទាំងឡាយណាដែលធ្វើឲ្យមានការភ័ន្តច្រឡំ ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សីលធម៌ និងប្រពៃណីដ៏ល្អរបស់ជាតិ ប៉ះពាល់ដល់សញ្ញានៃស្ថាប័នជាតិ និងអន្តរជាតិ (អញ្ញត្តិកម្មប្រសិនបើមានការយល់ព្រម)។ តាមរយៈនៃការហាមឃាត់នេះវាមិនត្រឹមតែការពារបាននូវសិទ្ធិរបស់ម្ចាស់ម៉ាកតែមួយប៉ុណ្ណោះទេ វាថែមទាំងការពារដល់អ្នកប្រើប្រាស់ និងសេចក្តីថ្លៃថ្នូររបស់ប្រទេសជាតិយើងផងដែរ។ ទន្ទឹមនឹងនេះដែរច្បាប់ក៏បានផ្តល់សិទ្ធិទៅឲ្យម្ចាស់ម៉ាកដែលបានចុះបញ្ជី (អញ្ញត្តិកម្មចំពោះម៉ាកល្បី) រួចហើយក្នុងការធ្វើពាក្យបណ្តឹងប្រឆាំងទៅនឹងបុគ្គលដែលបានយកម៉ាកទៅប្រើប្រាស់ដោយគ្មានការអនុញ្ញាតពីម្ចាស់ម៉ាកផងដែរ។ មាននីតិវិធីជាច្រើនដែលម្ចាស់ម៉ាកអាចរកដំណោះស្រាយបានដូចជាៈ វិធានការតាមមាត់ច្រកព្រំដែន យន្តការផ្ទៃក្នុងនៃក្រសួងពាណិជ្ជកម្ម ដំណោះស្រាយក្រៅប្រព័ន្ធតុលាការ និងដំណោះស្រាយ តាមផ្លូវតុលាការ។

ស្របពេលដែលកំណើនសេដ្ឋកិច្ច ដែលចូលរួមចំណែកដោយចំណេះដឹងផ្នែកកម្មសិទ្ធិបញ្ញាចំពោះម៉ាក គឺជាការពិចារណាដ៏សំខាន់ក្នុងការសម្រេចចិត្តផ្នែកពាណិជ្ជកម្ម។ ផលិតផលម៉ាក និងការច្នៃប្រឌិតថ្មីៗជាច្រើន ដែលមានវត្តមាននៅលើទីផ្សារជារៀងរាល់ថ្ងៃ គឺជាលទ្ធផលនៃការបន្ត ច្នៃប្រឌិត និងបង្កើតថ្មីរបស់មនុស្សជាតិ។ សហគ្រាសធុនតូច និងមធ្យមជាកម្លាំងចលករនៅពីក្រោយការបង្កើតថ្មីនេះ។ ការបង្កើតថ្មី និងការច្នៃប្រឌិត ជួនកាលមិនត្រូវបានធ្វើអាជីវកម្មឲ្យបានពេញលេញនោះទេ ដោយសារតែសហគ្រាសធុនតូច និងមធ្យមភាគច្រើនមិនទាន់យល់ច្បាស់អំពីប្រព័ន្ធកម្មសិទ្ធិបញ្ញា ឬផលប្រយោជន៍នៃការការពារកម្មសិទ្ធិបញ្ញាចំពោះតក្កកម្មម៉ាក និងគំនូរឧស្សាហកម្មរបស់ខ្លួន។ ប្រសិនបើកម្មសិទ្ធិបញ្ញាទាំងនោះមិនត្រូវបានការពារដោយច្បាប់នោះទេ តក្កកម្មនឹងបាត់បង់ទៅលើ

គូប្រកួតប្រជែងធំៗ ដែលមានភាពប្រកួតប្រជែងក្នុងការធ្វើអាជីវកម្មលើផលិតផល ឬសេវាក្នុងតម្លៃទាប ដែលធ្វើឲ្យតក្កករ ឬម្ចាស់ដើមមិនបានទទួលអត្ថប្រយោជន៍ ឬតម្លៃតបស្នងពីការបង្កើតថ្មីរបស់ខ្លួននោះទេ។

កិច្ចការពារកម្មសិទ្ធិបញ្ញាសមស្របរបស់ក្រុមហ៊ុន ជាជំហានដ៏សំខាន់ក្នុងការកំណត់អំពីការរំលោភបំពាន និងការប្រែក្លាយគំនិតទៅជាទ្រព្យនៃអាជីវកម្មដែលមានតម្លៃ។ ការទាញយកផលប្រយោជន៍ពេញលេញពីប្រព័ន្ធការពារកម្មសិទ្ធិបញ្ញាអាចធ្វើឲ្យក្រុមហ៊ុនទទួលបានចំណូលពីការបង្កើតថ្មី និងការច្នៃប្រឌិតរបស់ខ្លួន ដែលជាការលើកទឹកចិត្ត និងបង្កើនមូលធនដល់ការស្រាវជ្រាវ និងការអភិវឌ្ឍន៍។ មានផលិតផល ឬសេវាថ្មីៗជាច្រើន ដែលបានការពារក្រោមប្រភេទផ្សេងៗគ្នានៃកម្មសិទ្ធិបញ្ញា។ កិច្ចការពារម៉ាក និងយន្តការនៃការដោះស្រាយវិវាទម៉ាកនេះក៏ដោយ ក៏យើងសង្កេតឃើញថាៈ បច្ចុប្បន្ននៅលើទីផ្សារនៅតែមានការលួចបន្លំម៉ាក និងមានម៉ាកមួយចំនួនមានលក្ខណៈប្រហាក់ប្រហែលគ្នា ឬស្ទើរតែដូចគ្នាទាំងស្រុង ដែលធ្វើឲ្យមជ្ឈដ្ឋានពាណិជ្ជកម្ម ឬសាធារណៈជនមានការភ័ន្តច្រឡំ។ បញ្ហាទាំងនេះវាបង្កឲ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់សុខភាព ប្រាក់កាក់របស់អ្នកប្រើប្រាស់ នៅពេលដែលពួកគេទិញចំផលិតផលក្លែងក្លាយ។ ទាំងនេះជាការបញ្ជាក់ឲ្យឃើញថាៈ ច្បាប់មានក៏ពិតមែន ក៏ប៉ុន្តែការអនុវត្តជាក់ស្តែង គឺពុំទាន់មានលក្ខណៈល្អប្រសើរនៅឡើយទេ។ ហេតុនេះហើយទើបសហ គ្រាសមួយចំនួនតែងតែជួបប្រទះនូវបញ្ហាប្រឈម ក្នុងការទាញយកតម្លៃពីស្នាដៃរបស់ខ្លួនដែលខំប្រឹង ប្រែងបង្កើតឡើង។ ដូច្នេះក្រុមហ៊ុននីមួយៗ ដែលបានចំណាយធនធាន និងពេលវេលាក្នុងបង្កើតស្នាដៃរបស់ខ្លួន ហើយដើម្បីការពារកម្មសិទ្ធិបញ្ញារបស់ខ្លួន គឺត្រូវតែទៅចុះបញ្ជីម៉ាករបស់ខ្លួនដែលខំប្រឹងបង្កើត នៅស្ថាប័នពាក់ព័ន្ធឲ្យបានឆាប់ រហ័សដើម្បីទប់ស្កាត់នៃការប្រកួតប្រជែងមិនស្មោះត្រង់ដូចជាៈ

- ☞ បង្ការគូប្រកួតប្រជែងក្នុងការចម្លង ឬធ្វើត្រាប់តាមផលិតផលរបស់ខ្លួន
- ☞ ជៀសវាងលើការចំណាយថវិកាខ្ជះខ្ជាយក្នុងស្រាវជ្រាវ និងការផ្សព្វផ្សាយនៅទីផ្សារ
- ☞ បង្កើតអត្តសញ្ញាណសហគ្រាសតាមរយៈម៉ាករបស់ខ្លួន

ជារួមមកកិច្ចការការពារម៉ាក និងយន្តការនៃការដោះស្រាយវិវាទម៉ាកនៅកម្ពុជាពិតជាមានសារៈសំខាន់ណាស់សម្រាប់សង្គមជាតិយើងទាំងមូល។

ប្រសិនបើកម្មសិទ្ធិបញ្ញាទាំងនោះមិនត្រូវបានការពារដោយច្បាប់នោះទេ តក្កកម្មនឹងបាត់បង់ទៅគូប្រកួតប្រជែងធំៗ ដែលមានភាពប្រកួតប្រជែងក្នុងការធ្វើអាជីវកម្មលើផលិតផល ឬសេវាក្នុងតម្លៃទាប ដែលធ្វើឲ្យតក្កករ ឬម្ចាស់ដើម មិនបានទទួលអត្ថប្រយោជន៍ ឬតម្លៃតបស្នងពីការបង្កើតថ្មីរបស់ខ្លួននោះទេ។

កិច្ចការពារកម្មសិទ្ធិបញ្ញាសមស្របរបស់ក្រុមហ៊ុន ជាជំហានដ៏សំខាន់ក្នុងការកំណត់អំពីការរំលោភបំពាន និងការប្រែក្លាយគំនិតទៅជាទ្រព្យនៃអាជីវកម្ម ដែលមានតម្លៃ។ ការទាញយកផលប្រយោជន៍ពេញលេញពីប្រព័ន្ធការពារកម្មសិទ្ធិបញ្ញាអាចធ្វើឲ្យក្រុមហ៊ុនទទួលបានចំណូលពីការបង្កើតថ្មី និងការ ច្នៃប្រឌិតរបស់ខ្លួន ដែលជាការលើកទឹកចិត្ត និងបង្កើនមូលធនដល់ការស្រាវជ្រាវ និងការអភិវឌ្ឍន៍។ មានផលិតផល ឬសេវាថ្មីៗជាច្រើន ដែលបានការពារក្រោមប្រភេទផ្សេងៗគ្នានៃកម្មសិទ្ធិបញ្ញា។ កិច្ចការពារម៉ាក និងយន្តការនៃការដោះស្រាយវិវាទម៉ាកនេះ យើងក៏សង្កេតឃើញថាៈ បច្ចុប្បន្ននៅលើទីផ្សារនៅតែមានការលួចបន្លំម៉ាក និងមានម៉ាកមួយចំនួនមាន លក្ខណៈប្រហាក់ប្រហែលគ្នា ឬស្ទើរតែដូចគ្នាទាំងស្រុង ដែលធ្វើឲ្យមជ្ឈដ្ឋានពាណិជ្ជកម្ម ឬសាធារណៈជនមានការភ័ន្តច្រឡំ។ បញ្ហាទាំងនេះវាបង្កឲ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់សុខភាព ប្រាក់កាក់របស់អ្នកប្រើប្រាស់ នៅពេលដែលពួកគេទិញចំផលិតផលក្លែងក្លាយ។ ទាំងនេះជាការបញ្ជាក់ឲ្យឃើញថាៈ ច្បាប់មានក៏ពិតមែន ក៏ប៉ុន្តែការអនុវត្តជាក់ស្តែង គឺពុំទាន់មានលក្ខណៈល្អប្រសើរនៅឡើយទេ។ ហេតុនេះហើយទើបសហគ្រាសមួយចំនួនតែងតែជួបប្រទះនូវបញ្ហាប្រឈម ក្នុងការទាញយកតម្លៃពីស្នាដៃរបស់ខ្លួនដែលខំប្រឹង ប្រែងបង្កើតឡើង។ ដូច្នេះក្រុមហ៊ុននីមួយៗ ដែលបានចំណាយធនធាន និងពេលវេលាក្នុងបង្កើតស្នាដៃរបស់ខ្លួន ហើយដើម្បីការពារកម្មសិទ្ធិបញ្ញារបស់ខ្លួនគឺតែទៅចុះបញ្ជីម៉ាករបស់ខ្លួនដែលខំប្រឹងបង្កើត នៅស្ថាប័នពាក់ព័ន្ធឲ្យបានឆាប់ រហ័សដើម្បីទប់ស្កាត់នៃការប្រកួតប្រជែងមិនស្មោះត្រង់ដូចជាៈ

- ☞ បង្ការគូប្រកួតប្រជែងក្នុងការចម្លង ឬធ្វើត្រាប់តាមផលិតផលរបស់ខ្លួន
- ☞ ជៀសវាងលើការចំណាយថវិកាខ្ជះខ្ជាយក្នុងស្រាវជ្រាវ និងការផ្សព្វផ្សាយនៅទីផ្សារ
- ☞ បង្កើតអត្តសញ្ញាណសហគ្រាសតាមរយៈម៉ាករបស់ខ្លួន

ជារួមមកកិច្ចការការពារម៉ាក និងយន្តការនៃការដោះស្រាយវិវាទម៉ាកនៅកម្ពុជាពិតជាមានសារៈសំខាន់ណាស់សម្រាប់សង្គមជាតិយើងទាំងមូល។

# អនុសាសន៍

# អនុសាសន៍

នាពេលបច្ចុប្បន្ននេះនៅលើទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា គឺមានការប្រកួតប្រជែងយ៉ាងខ្លាំង ដោយសារមានផលិតផលជាច្រើនបានប្រកួតប្រជែងគ្នា ប៉ុន្តែក៏មានផលិតផលក្លែងបន្លំម៉ាក និងមានម៉ាកមួយចំនួនមានលក្ខណៈប្រហាក់ប្រហែលគ្នា ឬស្ទើតែដូចគ្នាទាំងស្រុង ដែលជាហេតុធ្វើឲ្យមជ្ឈដ្ឋានពាណិជ្ជកម្ម ឬសាធារណៈជនមានការភ័ន្តច្រឡំ និងជាពិសេសអាចបង្កឲ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពរបស់អ្នកប្រើប្រាស់នៅដែលពួកគេបានទិញចំផលិតផលក្លែងក្លាយ ដូច្នេះដើម្បីជៀសវាងកុំឲ្យមានផលិតផលក្លែងបន្លំម៉ាក និងដើម្បីការពារដល់ម្ចាស់ម៉ាកគម្បីះ

១. ម្ចាស់ម៉ាក ដែលបានបង្កើតបានជាស្នាដៃរួចហើយត្រូវយកម៉ាករបស់ខ្លួនទៅចុះបញ្ជីនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញាដើម្បីឲ្យច្បាប់ការពារម៉ាកនោះ។

២. ត្រូវធ្វើការផ្សព្វ និងអប់រំដល់សាធារណៈជនពីផលប្រយោជន៍ដែលទទួលបានពីការចុះបញ្ជីនៃម៉ាករបស់ខ្លួន។

៣. បណ្តុះបណ្តាលមន្ត្រីពាក់ដែលពាក់ព័ន្ធ ឲ្យមានជំនាញផ្នែកម៉ាកឲ្យកាន់តែច្រើនបន្ថែមទៀត និងបង្កើននូវកិច្ចសហប្រតិបត្តិការជាមួយប្រទេសនានាដែលជាសមាជិកនៃសន្ធិសញ្ញាក្នុងការអនុវត្តសិទ្ធិស្តីពីម៉ាក ឬកម្មសិទ្ធិបញ្ញា។

៤. ពង្រឹងនូវសមត្ថភាពរបស់មន្ត្រីដែលមានសមត្ថកិច្ចដូចជាៈ រដ្ឋាបាលគយ រដ្ឋាករ មន្ត្រីកាំកុងត្រូល និងមន្ត្រីប៉ូលីសសេដ្ឋកិច្ច ក្នុងការអនុវត្តន៍ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងទប់ស្កាត់ការនាំចេញ នាំចូលនូវទំនិញពាក់ម៉ាកក្លាយ ឬខុសច្បាប់។

៥. គួរតែបង្កើតឲ្យមានក្រុមប្រឹក្សាដោះស្រាយវិវាទម៉ាកឲ្យបានកាន់តែឆាប់រហ័ស ដើម្បីងាយស្រួលក្នុងការដោះស្រាយវិវាទម៉ាក និងបង្កើតឲ្យមានតុលាការជំនាញទាក់ទងទៅនឹងកម្មសិទ្ធិបញ្ញាដើម្បីដោះស្រាយវិវាទម៉ាក។

៦. ផ្តន្ទាទោសបុគ្គល ដែលបានលួចក្លែងបន្លំម៉ាកឲ្យបានធ្ងន់ធ្ងរ៕

# ឯកសារយោង

# ឯកសារយោង

១. រដ្ឋធម្មនុញ្ញ ប្រកាសឲ្យប្រើនៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣

២. ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/ រកម/ ០៧០៦/ ០២១, ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ ២០០៤

៣. ព្រះរាជក្រមលេខ នស/ រកម/ ០២០២/ ០០៦ ចុះថ្ងៃទី ០៧ កម្ភៈ ឆ្នាំ ២០០២ ប្រកាសឲ្យប្រើច្បាប់ ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។

៤. ច្បាប់ស្តីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/ រកម/ ០៥០៦/ ០១០, ០៩ ឧសភា ២០០៦

៥. អនុក្រឹត្យ លេខ២៦៤ អនក្រ/ បក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០០៧ ស្តីពីការអនុវត្តន៍ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់។

៦. ប្រកាសស្តីពីការរៀបចំ នឹង ការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា, លេខ ២១១ MOC, SM, ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៧

៧. កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIP), ១៩៩៥

៨. អនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្ម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៨៨៣

៩. http://www.cambodiaip.gov.kh/

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

## តារាងឧបសម្ព័ន្ធ

| ល.រ | ឧបសម្ព័ន្ធ |
|---|---|
| ១ | រូបភាព និងស្លាកសញ្ញាផ្សេងៗ |
| ២ | ព្រះរាជក្រមស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ |
| ៣ | អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ |
| ៤ | ផ្សេងៗ<br>- ពាក្យស្នើសុំចុះបញ្ជីម៉ាក<br>- ពាក្យស្នើសុំកែសម្រួលម៉ាកដែលបានចុះបញ្ជីរួច (ទម្រង់លេខ: ០០៧)<br>- ពាក្យស្នើសុំកែតម្រូវមុខទំនិញ ឬសេវាដែលបានចុះបញ្ជីរួច (ទម្រង់លេខ: ០០៩)<br>- ពាក្យស្នើសុំកត់ត្រាការប្តូរឈ្មោះម្ចាស់ម៉ាកបន្ទាប់ពីការរួមបញ្ចូលគ្នា (ទម្រង់លេខ: ០១៣)<br>- កិច្ចសន្យាផ្ទេរកម្មសិទ្ធិកាន់កាប់ម៉ាកមួយផ្នែក (ទម្រង់លេខ: ០២៤)<br>- សេចក្តីប្រកាសអំពីការប្តូរអាសយដ្ឋានរបស់ម្ចាស់ម៉ាក (ទម្រង់លេខ: ០១៨)<br>- ពាក្យស្នើសុំទុតិយតាលើវិញ្ញាបនបត្រចុះបញ្ជីម៉ាក (ទម្រង់លេខ: ០២២)<br>- ពាក្យស្នើសុំចុះបញ្ជីសាជាថ្មី (ទម្រង់លេខ: ០១៩)<br>- ពាក្យស្នើសុំធ្វើសេចក្តីប្រកាសអំពីការប្រើប្រាស់ ឬមិនប្រាស់ម៉ាក (ទម្រង់លេខ: ០២១)<br>- ពាក្យស្នើសុំចុះឈ្មោះទទួលស្គាល់ជាផ្លូវការ ជាភ្នាក់ងារតំណាងស្របច្បាប់នៃម្ចាស់ម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា និងជីវប្រវត្តិសង្ខេប<br>- លិខិតប្រគល់សិទ្ធិ (ទម្រង់លេខ: ០០២)<br>- ប្រកាសរួមស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម |

# ឧបសម្ព័ន្ធ ១

**ឧទាហរណ៍:** ក្លិនទឹក អប់ម៉ាក Chanel [៣]




**ឧទាហរណ៍:** ទឹកក្រូច Coca Cola និងទូរស័ព្ទដៃ Samsung [៤]







**ឧទហរណ៍:** ថ្មពិល( 555) និង អាគុយ(3K) [៥]






**ឧទហរណ៍:** ក្រុមហ៊ុន Cellcard និង Smart [៦]

**ឧទហរណ៍:** Logo Text Here [៧]

**ឧទាហរណ៍:** ធុរេនកំពត  ម្រេចកំពត ធុរេនកំពង់ចាម...[៨]



**ឧទាហរណ៍:** ការបិទ 502 [៩]







**ឧទាហរណ៍:** ហាងសាច់មាន់លោក, តូបលក់សាច់កម្ពុជា [១០]







**ឧទាហរណ៍:** និមិត្តសញ្ញាចាស់ ប្តូរទៅជា និមិត្តសញ្ញាថ្មី [១១]

និមិត្តសញ្ញាចាស់ និមិត្តសញ្ញាថ្មី

ប្តូរទៅជា

# ឧបសម្ព័ន្ធ ២

# ច្បាប់
# ស្តីពី
# ម៉ាក ពាណិជ្ជនាម និងអំពើ
# នៃការប្រកួតប្រជែងមិនស្មោះត្រង់

# ព្រះរាជក្រម

នស/រកម/០២០២/០០៦

## យើង
## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស ឧភតោសុជាត
## វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស /រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គ លើកទី ៧ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ០៨ខែមករា ឆ្នាំ ២០០២ នាសម័យប្រជុំពេញអង្គ លើកទី ៦ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅៈ

# ច្បាប់
# ស្តីពី
# ម៉ាក ពាណិជ្ជនាម និងអំពើ
# នៃការប្រកួតប្រជែងមិនស្មោះត្រង់

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងការពារម៉ាក ពាណិជ្ជនាម ដែលបានចុះបញ្ជីក្នុងបញ្ជីម៉ាក នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងប្រឆាំងការប្រកួតប្រជែងមិនស្មោះត្រង់ លើការបង្កើត ការប្រើប្រាស់ម៉ាក និងពាណិជ្ជនាម ។

**មាត្រា ២.-**

ក- ម៉ាក គឺជាសញ្ញាដែលមើលឃើញ ហើយអាចសំគាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវានៃសហគ្រាសនីមួយៗ ។ ម៉ាកដែលប្រើប្រាស់សំរាប់ទំនិញហៅថាពាណិជ្ជសញ្ញា ហើយម៉ាកដែលប្រើប្រាស់ សំរាប់សេវាហៅថា សេវាសញ្ញា ។

ខ- ម៉ាកសមូហភាព គឺជាសញ្ញាដែលមើលឃើញ សំដៅប្រើក្នុងការដាក់ពាក្យសុំចុះបញ្ជី ហើយអាចសំគាល់នូវប្រភពដើមនៃទំនិញឬសេវា ឬសំគាល់នូវចរិតលក្ខណៈរួមដទៃទៀត គិតទាំងគុណភាពនៃទំនិញ ឬសេវា របស់សហគ្រាសផ្សេងៗគ្នា ដែលប្រើសញ្ញានោះ ក្រោមការគ្រប់គ្រងរបស់ម្ចាស់ម៉ាកសមូហភាពដែលបានចុះបញ្ជី ។

គ- ពាណិជ្ជនាម គឺជាឈ្មោះ ឬសញ្ញាសំគាល់ ឬជាឈ្មោះ និងសញ្ញាសំគាល់ សំរាប់បញ្ជាក់ និងសំគាល់លក្ខណៈខុសៗគ្នានៃសហគ្រាសនីមួយៗ ។

**មាត្រា ៣.-**

សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ត្រូវបានទទួលស្គាល់តាមរយៈការចុះបញ្ជី ដោយអនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ។

**មាត្រា ៤.-**

ម៉ាកដែលមិនអាចចុះបញ្ជីបានមានដូចតទៅ :

ក- ម៉ាកដែលមិនអាចសំគាល់លក្ខណៈខុសគ្នានៃទំនិញ ឬសេវា របស់សហគ្រាសមួយទៅនឹងសហគ្រាសមួយផ្សេងទៀត ។

ខ- ម៉ាកដែលបណ្តាលឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សីលធម៌ ឬប្រពៃណីល្អរបស់ជាតិ ។

គ- ម៉ាកដែលអាចនាំឱ្យសាធារណជន ឬមជ្ឈដ្ឋាន ពាណិជ្ជកម្មភ័ន្តច្រឡំទៅនឹងប្រភពភូមិសាស្ត្រនៃទំនិញ ឬសេវាពាក់ព័ន្ធ ឬធាតុដើម ឬលក្ខណៈខាងក្រៅរបស់ទំនិញ ឬសេវានោះ ។

ឃ- ម៉ាកដែលដូចគ្នានិង/ឬត្រាប់តាម ឬមានចំណុចណាមួយដូច សញ្ញាជាតិ ទង់ជាតិ និងនិមិត្តរូបផ្សេងៗ ឈ្មោះ ឬឈ្មោះសង្ខេប ឬអក្សរកាត់នៃឈ្មោះ ឬសញ្ញា ឬត្រាជាផ្លូវការ ដែលអនុម័តដោយរដ្ឋណាមួយ អង្គការអន្តររដ្ឋាភិបាល ឬអង្គការដែលបង្កើតដោយអនុសញ្ញាអន្តរជាតិមួយ លើកលែងតែមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច នៃរដ្ឋនោះ ឬអង្គការនោះ ។

ង- ម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែល ដែលនាំឱ្យច្រឡំគ្នានឹងម៉ាក ឬពាណិជ្ជនាមមួយដែលល្បីក្នុងព្រះរាជាណាចក្រកម្ពុជា ឬបង្កើតពីការបកប្រែនៃម៉ាក ឬពាណិជ្ជនាមដែលល្បីនោះ សំរាប់ទំនិញ ឬសេវាដូចគ្នា ឬប្រហាក់ប្រហែលគ្នានៃសហគ្រាសមួយទៀត ។

ច- ម៉ាកដែលដូចគ្នា ឬប្រហាក់ប្រហែល ដែលនាំឱ្យច្រឡំគ្នានឹងម៉ាក ឬពាណិជ្ជនាមមួយដែលល្បី ឬបង្កើតពីការបកប្រែនៃម៉ាក ឬពាណិជ្ជនាមដែលល្បីនោះ ហើយដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ទំនិញ ឬសេវាដែលមិនដូចគ្នា ឬមិនប្រហាក់ប្រហែលគ្នា ដោយការប្រើប្រាស់ម៉ាកនោះធ្វើឱ្យខូចប្រយោជន៍របស់ម្ចាស់នៃម៉ាកល្បី ។

ឆ- ម៉ាកដែលដូចគ្នា ឬស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងម៉ាក ដែលជាកម្មសិទ្ធិរបស់ម្ចាស់ផ្សេង ដែលបានចុះបញ្ជីរួចហើយ ឬបានដាក់ពាក្យស្នើសុំចុះបញ្ជីមុន ឬបានទទួលអាទិភាពចុះបញ្ជីមុន នៅឯបរទេស ចំពោះទំនិញ ឬសេវាដូចគ្នា ឬទំនិញ ឬសេវា ដែលពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធ ។

## ជំពូកទី ២
## ការចុះបញ្ជី និងសិទ្ធិដែលកើតឡើងពីការចុះបញ្ជីម៉ាក

**មាត្រា ៥.-**

បែបបទនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ការសុំប្តូរអាស័យដ្ឋាននៃម្ចាស់ម៉ាក និងការបញ្ជាក់ឡើងវិញនូវការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក ត្រូវបានកំណត់ដូចខាងក្រោម :

ក- ការស្នើសុំចុះបញ្ជីម៉ាក ការសុំប្តូរអាស័យដ្ឋាននៃម្ចាស់ម៉ាក និងការបញ្ជាក់ឡើងវិញនូវការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក ត្រូវធ្វើនៅក្រសួងពាណិជ្ជកម្ម ។

ពាក្យស្នើសុំត្រូវភ្ជាប់ :

- គំរូម៉ាក
- បញ្ជីទំនិញ ឬសេវាដែលត្រូវចុះបញ្ជី ដោយរាយលំអិត តាមក្រុមមុខទំនិញ ទៅតាមចំណាត់ថ្នាក់អន្តរជាតិ ដូចមានក្នុងឧបសម្ព័ន្ធ ។

ខ- ការសុំចុះបញ្ជីម៉ាក ការសុំប្តូរអាស័យដ្ឋាននៃម្ចាស់ម៉ាក និងការបញ្ជាក់ឡើងវិញនូវការប្រើប្រាស់ ឬមិនបានប្រើប្រាស់ម៉ាក ត្រូវបង់កម្រៃតាមការកំណត់នៅក្នុងសេចក្តីប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ។

**មាត្រា ៦.-**

សិទ្ធិអាទិភាពក្នុងការចុះបញ្ជីម៉ាក ត្រូវបានផ្តល់តាមលក្ខខណ្ឌ ដូចខាងក្រោម :

ក- អ្នកស្នើសុំចុះបញ្ជីអាចស្នើសុំអាទិភាព នៃការចុះបញ្ជី ដោយអមមកជាមួយនូវប្រកាសស្តីពីអាទិភាពដែលខ្លួនមានតាមរយៈការស្នើសុំចុះបញ្ជីនៅប្រទេសណាមួយ ដែលជាសមាជិកនៃអនុសញ្ញាក្រុងប៉ារីស ។

ខ- តម្លៃនៃប្រកាសស្តីពីអាទិភាពខាងលើ ត្រូវតែស្របទៅតាមលក្ខខណ្ឌ ដែលមានចែងនៅក្នុងអនុសញ្ញាទីក្រុងប៉ារីស ។

**មាត្រា ៧.-**

អ្នកស្នើសុំចុះបញ្ជីអាចដកពាក្យស្នើសុំរបស់ខ្លួននៅពេលណាក៏បាន ។

**មាត្រា ៨.-**

ក្រោយពេលទទួលពាក្យស្នើសុំចុះបញ្ជី មន្ត្រីកាន់កាប់បញ្ជីត្រូវ :

ក- ពិនិត្យមើលពាក្យស្នើសុំនោះឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌនៃមាត្រា ៥ និងបទបញ្ញាដែលជាប់ទាក់ទង ។

ខ- ពិនិត្យ និងកំណត់ថា ម៉ាកនោះគឺជាម៉ាកស្របតាមលក្ខខណ្ឌដូចមានចែងនៅក្នុងមាត្រា ២ ចំណុច ក និងមិនអាចចុះបញ្ជីបាន តាមមាត្រា ៤ ដោយលើកលែងតែចំណុច ឆ នៃមាត្រា ៤ នេះចេញ ។

**មាត្រា ៩.-**

អាទិភាពនៃការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ត្រូវបានកំណត់ដូចតទៅ :

ក- កាលណាមានពាក្យស្នើសុំចុះបញ្ជីច្រើន ទាក់ទងនឹងម៉ាកដែលដូច ឬប្រហាក់ប្រហែលគ្នា ដែលត្រូវបានប្រើចំពោះទំនិញ ឬសេវាដូច ឬប្រហាក់ប្រហែលគ្នា ហើយបានដាក់ពាក្យស្នើសុំតាមពេលវេលាខុសគ្នា មន្ត្រីកាន់កាប់បញ្ជីអាចបដិសេធការចុះបញ្ជីម៉ាកណាមួយនៃម៉ាកទាំងនោះ រហូតដល់ពេលដែលសិទ្ធិនៃអ្នកស្នើសុំទាំងនោះ ត្រូវបានកំណត់ដោយមន្ត្រីកាន់កាប់បញ្ជី ឬត្រូវបានដោះស្រាយដោយការព្រមព្រៀងគ្នា និងមានការយល់ព្រមពីមន្ត្រីកាន់កាប់បញ្ជី ។

ខ- កាលណាមានពាក្យស្នើសុំចុះបញ្ជីច្រើន ទាក់ទងនឹងម៉ាកដែលដូច ឬប្រហាក់ប្រហែលគ្នាដែលត្រូវបានប្រើចំពោះទំនិញ ឬសេវាដូច ឬប្រហាក់ប្រហែលគ្នា ហើយបានដាក់ពាក្យស្នើសុំក្នុងពេលជាមួយគ្នា ក្រោយពីការពិគ្រោះឯកភាពគ្នាទៅវិញទៅមក ក្នុងចំណោមអ្នកស្នើសុំទាំងអស់មានអ្នកស្នើសុំតែម្នាក់គត់ដែលអាចទទួលបាននូវការចុះបញ្ជីម៉ាក ។

**មាត្រា ១០.-**

សិទ្ធិរបស់មន្ត្រីកាន់កាប់បញ្ជី ក្នុងការចុះបញ្ជីម៉ាកមានដូចខាងក្រោម :

ក- ក្នុងករណីដែលមន្ត្រីកាន់កាប់បញ្ជីរកឃើញថា លក្ខខណ្ឌទាំងឡាយ ដែលមានចែងក្នុងមាត្រា ៨ និងមាត្រា ៩ បានត្រូវបំពេញ មន្ត្រីកាន់កាប់បញ្ជីត្រូវចុះបញ្ជីម៉ាក ចេញវិញ្ញាបនប័ត្រនៃការចុះបញ្ជីជូនអ្នកស្នើសុំ និងចុះផ្សាយក្នុងព្រឹត្តិប័ត្រផ្លូវការរបស់ក្រសួងពាណិជ្ជកម្ម ។

ខ- ពាក្យស្នើសុំចុះបញ្ជី ដែលមិនបានសមស្របតាមមាត្រា ៨ អ្នកស្នើសុំចុះបញ្ជី អាចកែតម្រូវក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃជូនដំណឹងជាលាយលក្ខណ៍អក្សររបស់មន្ត្រីកាន់កាប់

បញ្ជី ។ ក្នុងករណីគ្មានការកែតម្រូវពាក្យស្នើសុំពីអ្នកសុំចុះបញ្ជីតាមកាលកំណត់ មន្ត្រីកាន់កាប់បញ្ជីមានសិទ្ធិបដិសេធការចុះបញ្ជីម៉ាកនោះ ។

គ- ក្នុងរង្វង់ ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីបានចុះផ្សាយ ក្នុងព្រឹត្តិប័ត្រផ្លូវការហើយ ជនណាដែលមានការពាក់ព័ន្ធ អាចជូនដំណឹងទៅមន្ត្រីកាន់កាប់បញ្ជីពីការជំទាស់របស់ខ្លួន ចំពោះការចុះបញ្ជីម៉ាកតាមបែបបទដែលបានកំណត់ ដោយឈរលើមូលដ្ឋាននៃការមិនបានបំពេញតាមលក្ខខណ្ឌណាមួយនៃមាត្រា ២ ចំណុច ក មាត្រា ៤ និង មាត្រា ៥ និងបទបញ្ញាទាំងឡាយដែលពាក់ព័ន្ធ ។

ឃ- មន្ត្រីកាន់កាប់បញ្ជីត្រូវបញ្ជូនជាបន្ទាន់ នូវសេចក្តីជូនដំណឹងនោះ មួយច្បាប់ ទៅអ្នកសុំចុះបញ្ជីតាមពេលវេលា និងបែបបទ ដែលបានកំណត់ ។ បន្ទាប់មក អ្នកស្នើសុំចុះបញ្ជីត្រូវបញ្ជូនទៅមន្ត្រីកាន់កាប់បញ្ជីនូវចម្លើយបញ្ជាក់ អំពីមូលដ្ឋានបង្អែកទាំងឡាយសម្រាប់ការចុះបញ្ជីរបស់ខ្លួន ។ ប្រសិនបើមិនបានឆ្លើយតបទេ ម្ចាស់ម៉ាកនោះ ត្រូវចាត់ទុកថា បានបោះបង់ចោលការចុះបញ្ជីរបស់ខ្លួន ។

ង- ប្រសិនបើអ្នកសុំចុះបញ្ជីធ្វើពាក្យជំទាស់ មន្ត្រីកាន់កាប់បញ្ជីត្រូវផ្តល់ចម្លើយមួយច្បាប់ទៅអ្នកដែលបានប្តឹងជំទាស់ ។ ប្រសិនបើភាគីម្ខាង ឬភាគីទាំងសងខាង មានបំណងចង់ឱ្យមានសវនាការ មន្ត្រីកាន់កាប់បញ្ជីត្រូវរៀបចំឱ្យមានសវនាការនោះ ។ បន្ទាប់ពីបានស្តាប់ភាគីទាំងសងខាង និងពិចារណាលើពាក្យតវ៉ា មន្ត្រីកាន់កាប់បញ្ជីត្រូវសម្រេចថា ម៉ាកដែលបានចុះបញ្ជីនេះ ត្រូវរក្សាទុក ឬបដិសេធ ។

**មាត្រា ១១.-**

សិទ្ធិដែលទទួលបានតាមរយៈការចុះបញ្ជីម៉ាក មានដូចខាងក្រោម :

ក- ចំពោះម៉ាកដែលទាក់ទងនឹងទំនិញ ឬសេវា ដែលបានចុះបញ្ជីរួចហើយ ការប្រើប្រាស់ម៉ាកនោះដោយជនណាមួយក្រៅពីម្ចាស់ដើម ត្រូវមានការយល់ព្រមពីម្ចាស់ដើមជាមុនសិន ។

ខ- ម្ចាស់ដើមនៃម៉ាកមានសិទ្ធិប្តឹងទៅតុលាការ ប្រឆាំងនឹងជនណាម្នាក់ ដែលប្រើប្រាស់ដោយរំលោភនូវម៉ាករបស់ខ្លួន ដោយគ្មានការយល់ព្រមពីម្ចាស់ដើម ។ ម្ចាស់ដើមក៏មានសិទ្ធិប្តឹងផងដែរ ចំពោះការប្រើប្រាស់នូវសញ្ញា ដែលប្រហាក់ប្រហែលនឹងម៉ាកដែលខ្លួនបានចុះបញ្ជី រួចហើយ និងការប្រើប្រាស់ម៉ាកដែលទាក់ទិនទៅនឹងទំនិញ និងសេវា ដែលប្រហាក់ប្រហែលទៅនឹងទំនិញ ឬសេវានៃម៉ាកដែលចុះបញ្ជីរួចហើយ នោះហើយដែលអាចបណ្តាលឱ្យមានការភ័ន្តច្រឡំជាសាធារណៈ ។

គ- សិទ្ធិដែលទទួលបានតាមរយៈការចុះបញ្ជី ម៉ាកនឹងមិនរាប់បញ្ចូលនូវការដាក់លក់ទំនិញនៅលើទីផ្សារ ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយម្ចាស់ដែលបានចុះបញ្ជី ឬដោយមានការយល់ព្រមពីម្ចាស់ម៉ាកនោះទេ ។

**មាត្រា ១២.-**

សុពលភាពក្នុងការចុះបញ្ជីម៉ាក និងការចុះបញ្ជីសាជាថ្មី ត្រូវបានកំណត់តាមលក្ខខណ្ឌដូចខាងក្រោម :

ក- ម៉ាកដែលបានចុះបញ្ជីហើយ មានសុពលភាព ១០ (ដប់) ឆ្នាំ ចាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យស្នើសុំចុះបញ្ជី ។

ខ- តាមការស្នើសុំ ការចុះបញ្ជីម៉ាកមួយ អាចធ្វើឡើងសាជាថ្មីសំរាប់រយៈពេល ១០ (ដប់) ឆ្នាំម្តងជាបន្តបន្ទាប់ ក្នុងលក្ខខណ្ឌដែលម្ចាស់ដើមបង់អាករចុះបញ្ជីជាថ្មីតាមការកំណត់ ។

គ- ក្នុងការដាក់ពាក្យស្នើសុំចុះបញ្ជីសាជាថ្មីនូវម៉ាកដែលបានចុះបញ្ជីរួចហើយ មុនពេលដែលច្បាប់នេះចូលជាធរមាន អ្នកស្នើសុំត្រូវបញ្ជាក់ឱ្យបានច្បាស់នូវប្រភេទទំនិញ ឬសេវាដែលចង់បានការការពារ ដោយផ្អែកតាមចំណាត់ថ្នាក់អន្តរជាតិ ។

ឃ- ការអនុគ្រោះចំពោះការយឺតយ៉ាវ ក្នុងការចុះបញ្ជីសាជាថ្មី ត្រូវបានអនុញ្ញាតត្រឹមតែរយៈពេល ៦ (ប្រាំមួយ) ខែ ។

## ជំពូកទី ៣
## មោឃភាព និងការលុបម៉ាកចេញពីបញ្ជី

**មាត្រា ១៣.-**

មោឃភាព និងអានុភាពនៃមោឃភាពត្រូវបានកំណត់ដូចខាងក្រោម :

ក- ជនណាដែលមានការពាក់ព័ន្ធ អាចស្នើសុំមកក្រសួងពាណិជ្ជកម្មឱ្យផ្តល់មោឃភាពដល់ការចុះបញ្ជីម៉ាកបាន ។

ខ- ក្រសួងពាណិជ្ជកម្មត្រូវទុកការចុះបញ្ជីជាមោឃៈ ប្រសិនបើជនដែលស្នើសុំឱ្យមានមោឃភាពនោះបង្ហាញថាមានលក្ខខណ្ឌ ណាមួយនៃមាត្រា ២ ចំណុច ក និងមាត្រា ៤ មិនត្រូវបានបំពេញ ។

គ- មោឃភាពនៃការចុះបញ្ជីម៉ាក ត្រូវមានអានុភាព ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជី ហើយត្រូវបានកត់ត្រា និងបោះពុម្ពផ្សាយជាបន្ទាន់ ។

**មាត្រា ១៤.-**

ក្រសួងពាណិជ្ជកម្មមានសិទ្ធិលុបចោលម៉ាកដែលបានចុះបញ្ជីរួចហើយក្នុងករណីដូចខាងក្រោម :

ក- អ្នកសុំចុះបញ្ជីមិនបានដាក់ពាក្យស្នើសុំចុះ បញ្ជីសាជាថ្មីនូវម៉ាក ដែលបានចុះបញ្ជីរួចហើយ តាមរយៈពេលដែលបានកំណត់ក្នុងមាត្រា ១២ ចំណុច ខ និងចំណុច ឃ ។

ខ- ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចហើយ ស្នើសុំលុប ។

គ- ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចហើយ មិនគោរពលក្ខខណ្ឌនៃការផ្តល់ឯកសារគាំទ្រ ឬការកម្រិតដែលបានកំណត់នៅក្នុងមាត្រា ៨ ។

ឃ- ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួចហើយ លែងមានអាស័យដ្ឋានទាក់ទងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ង- ជឿជាក់ដោយផ្អែកលើភ័ស្តុតាងថា ម្ចាស់ម៉ាកដែលបានចុះបញ្ជីរួច ហើយមិនមែនជាម្ចាស់ស្របច្បាប់ ។

ច- ជឿជាក់ថា ម៉ាកដែលបានចុះបញ្ជីរួចហើយ ប្រហាក់ប្រហែល ឬដូចគ្នាទៅនឹងម៉ាកល្បី ដែលជាកម្មសិទ្ធិរបស់ភាគីទីបី ។

**មាត្រា ១៥.-**

ម៉ាកដែលបានចុះបញ្ជីរួច ប៉ុន្តែមិនបានប្រើប្រាស់សោះក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ត្រូវបានលុបចេញពីបញ្ជី។ ប្រសិនបើម្ចាស់ម៉ាក បង្ហាញថា កាលៈទេសៈពិសេសបានរារាំងការប្រើប្រាស់ម៉ាក ហើយគ្មានបំណងមិនប្រើ ឬបោះបង់ចោលម៉ាកនោះទេ ម៉ាកនោះនឹងមិនត្រូវបានលុបចេញពីបញ្ជីឡើយ ។ ជនណាដែលពាក់ព័ន្ធអាចស្នើសុំឱ្យក្រសួងពាណិជ្ជកម្ម លុបម៉ាកចេញពីបញ្ជី ១ (មួយ) ខែ មុនកាលបរិច្ឆេទ ៥ (ប្រាំ) ឆ្នាំ នៃការមិនបានប្រើប្រាស់ ឬក្រោយកាលបរិច្ឆេទនេះ ។

## ជំពូកទី ៤
## ម៉ាកសមូហភាព

**មាត្រា ១៦.-**

បទប្បញ្ញត្តិទាំងឡាយដែលមានចែងពីមាត្រា ៣ ដល់មាត្រា ១៥ ព្រមទាំងមាត្រា ១៧ និងមាត្រា ១៨ នៃច្បាប់នេះ ត្រូវអនុវត្ត ចំពោះម៉ាកសមូហភាព ។

**មាត្រា ១៧.-**

បែបបទនៃការចុះបញ្ជីម៉ាកសមូហភាព មានដូចតទៅ :

ក- ពាក្យស្នើសុំចុះបញ្ជីម៉ាកសមូហភាព ត្រូវបញ្ជាក់ថា ជាម៉ាកសមូហភាព និងត្រូវភ្ជាប់មកជាមួយនូវបទបញ្ញារួម ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ម៉ាកសមូហភាពនោះមួយច្បាប់ ។

ខ- ម្ចាស់ម៉ាកសមូហភាព ដែលបានចុះបញ្ជី ហើយត្រូវជូនដំណឹងទៅមន្ត្រីកាន់កាប់បញ្ជីអំពីការផ្លាស់ប្តូរទាំងឡាយតាមបទបញ្ញាដែលបានយោងក្នុងកថាខ័ណ្ឌ ក ។

**មាត្រា ១៨.-**

បន្ថែមលើខ្លឹមសារដូចមានចែងក្នុងមាត្រា ១៣ ចំណុច ក និងចំណុច ខ មន្ត្រីកាន់កាប់បញ្ជីត្រូវចាត់ទុកការចុះបញ្ជីម៉ាកសមូហភាពជាមោឃៈ ប្រសិនបើជនដែលទាមទារនូវមោឃភាពនោះបង្ហាញថា មានតែម្ចាស់ដែលបានចុះបញ្ជីម្នាក់ឯងប៉ុណ្ណោះ ដែលប្រើប្រាស់ម៉ាក ឬបង្ហាញថា ម្ចាស់ដែលបានចុះបញ្ជីប្រើប្រាស់ ឬអនុញ្ញាតឱ្យប្រើប្រាស់ រំលោភទៅនឹងបទបញ្ញារួម ដែលបានបញ្ញត្តិនៅក្នុងមាត្រា ១៧ ចំណុច ក ឬបង្ហាញថា ម្ចាស់ដែលបានចុះបញ្ជីអនុញ្ញាតឱ្យប្រើប្រាស់តាមរបៀបមួយដែលអាចបំភ័ន្តមជ្ឈដ្ឋានពាណិជ្ជកម្ម ឬសាធារណជន អំពីប្រភពដើម ឬលក្ខណៈរួមផ្សេងទៀតនៃទំនិញ ឬសេវាដែលពាក់ព័ន្ធ ។

## ជំពូកទី ៥
## ការផ្តល់អាជ្ញាប័ណ្ណចំពោះម៉ាក

**មាត្រា ១៩.-**

ការផ្តល់អាជ្ញាប័ណ្ណចំពោះម៉ាកត្រូវបានកំណត់ដូចខាងក្រោម :

ក- កិច្ចសន្យាអាជ្ញាប័ណ្ណណាមួយអំពីការចុះ បញ្ជីម៉ាក ឬពាក្យស្នើសុំទទួលស្គាល់កិច្ចសន្យាអាជ្ញាប័ណ្ណនោះ ត្រូវចែងអំពីការត្រួតពិនិត្យដោយមានប្រសិទ្ធភាព ពីសំណាក់អ្នកប្រគល់អាជ្ញាប័ណ្ណ ចំពោះគុណភាពទំនិញ ឬសេវារបស់អ្នកទទួលអាជ្ញាប័ណ្ណដែលម៉ាកនោះ ត្រូវបានប្រើប្រាស់ ។ ប្រសិនបើកិច្ចសន្យាអាជ្ញាប័ណ្ណមិនបានចែងអំពីការត្រួតពិនិត្យគុណភាពនោះ ឬប្រសិនបើការត្រួតពិនិត្យគុណភាពនោះមិនត្រូវបានអនុវត្ត ដោយមានប្រសិទ្ធភាពទេ កិច្ចសន្យាអាជ្ញាប័ណ្ណនោះនឹងត្រូវចាត់ទុកជាមិនបានការ ។

ខ- ការចុះបញ្ជីម៉ាកសមូហភាពមួយ ឬពាក្យស្នើសុំចុះបញ្ជីម៉ាកសមូហភាពនោះ មិនអាចជាកម្មវត្ថុនៃកិច្ចសន្យាអាជ្ញាប័ណ្ណបានឡើយ ។

## ជំពូកទី ៦
## ពាណិជ្ជនាម

**មាត្រា ២០.-**

នាម ឬសញ្ញាសំគាល់ មិនអាចត្រូវបានប្រើប្រាស់ជាពាណិជ្ជនាមឡើយ ប្រសិនបើសារជាតិ ឬការប្រើប្រាស់នាម ឬសញ្ញាសំគាល់ដែលបានកំណត់នោះ ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬសីលធម៌ និងជាពិសេសអាចបំភាន្តដល់មជ្ឈដ្ឋានពាណិជ្ជកម្ម ឬសាធារណជន អំពីប្រភេទនៃសហគ្រាស ដែលកំណត់ដោយនាមនោះ ។

**មាត្រា ២១.-**

ការការពារ និងការរំលោភលើពាណិជ្ជនាម ត្រូវបានចែងដូចខាងក្រោម :

ក- ទោះជាច្បាប់ ឬបទបញ្ញាទាំងឡាយចែងអំពីកាតព្វកិច្ចក្នុងការចុះបញ្ជីពាណិជ្ជនាមក៏ដោយ ក៏នាមទាំងនោះត្រូវបានការពារ ប្រឆាំងនឹងទង្វើមិនស្របច្បាប់របស់ភាគីទីបី ទោះមុនការចុះបញ្ជី ឬគ្មានការចុះបញ្ជីក៏ដោយ ។

ខ- ការប្រើប្រាស់ពាណិជ្ជនាមជាបន្តបន្ទាប់ ដោយភាគីទីបី ទោះបីជាពាណិជ្ជនាម ឬម៉ាក ឬជាម៉ាកសមូហភាព ឬការប្រើប្រាស់ណាមួយ ដែលអាចធ្វើឱ្យសាធារណជនភាន្តច្រឡំ ត្រូវចាត់ទុកថាមិនស្របច្បាប់ ។

## ជំពូកទី ៧
## អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

**មាត្រា ២២.-**

អំពើនៃការប្រកួតប្រជែងណា ដែលផ្ទុយពីគោលការណ៍នៃការអនុវត្តន៍ទៀងត្រង់នៅក្នុងវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្ម ត្រូវចាត់ទុកថា ជាការប្រកួតប្រជែងមិនស្មោះត្រង់ ។

**មាត្រា ២៣.-**

ទង្វើទាំងឡាយដូចខាងក្រោម ត្រូវចាត់ទុកថា បានបង្កើតនូវអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ :

ក- ការបង្កើតឱ្យមានការភ័ន្តច្រឡំតាមមធ្យោបាយណាមួយ ជាមួយសហគ្រាស ជាមួយទំនិញ ឬជាមួយសកម្មភាពឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្មនៃគូប្រកួតប្រជែង ។

ខ- ការពោលអះអាងមិនត្រឹមត្រូវក្នុងពាណិជ្ជកម្ម ដែលធ្វើឱ្យខូចកេរ្តិ៍ឈ្មោះ សហគ្រាស ទំនិញ ឬ សកម្មភាពឧស្សាហកម្ម ពាណិជ្ជកម្ម ឬសេវាកម្មនៃគូប្រកួតប្រជែង ។

គ- ការបញ្ជាក់ ឬការពោលអះអាងដែលបានប្រើប្រាស់នៅក្នុងពាណិជ្ជកម្ម ហើយដែលអាចធ្វើឱ្យសាធារណជនភ័ន្តច្រឡំ អំពីប្រភេទ ដំណើរការផលិត លក្ខណៈ ភាពសមស្រប សំរាប់គោលបំណងរបស់គេ ឬបរិមាណនៃទំនិញ ។

## ជំពូកទី ៨
## ការរំលោភ និងវិធានការដោះស្រាយ

**មាត្រា ២៤.-**

ដោយផ្អែកតាមមាត្រា ១២ ខាងលើ ការរំលោភលើម៉ាក គឺជាការប្រព្រឹត្ត ដែលទាក់ទងទៅនឹងមាត្រា ១១ នៃច្បាប់នេះ ដោយជនណាម្នាក់ក្រៅពីម្ចាស់ម៉ាក ដែលបានចុះបញ្ជីរួចហើយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលពុំមានការយល់ព្រមពីម្ចាស់ម៉ាក ។

**មាត្រា ២៥.-**

ការប្រើប្រាស់នូវសញ្ញាដូច ឬប្រហាក់ប្រហែល ដែលធ្វើឱ្យភ័ន្តច្រឡំទៅនឹងម៉ាកល្បី ដែលបានចុះបញ្ជីរួចហើយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយគ្មានការយល់ព្រមពីម្ចាស់នៃម៉ាកល្បី ជាការរំលោភលើម៉ាកល្បីនោះ ប្រសិនបើសញ្ញាទាំងនោះត្រូវបានយកមកប្រើប្រាស់ :

ក- ទាក់ទងទៅនឹងទំនិញ និងសេវា ដែលដូច ឬប្រហាក់ប្រហែលនឹងទំនិញ និងសេវានៃម៉ាកល្បី ដែលបានចុះបញ្ជីរួច ។

ខ- ទាក់ទងទៅនឹងទំនិញ និងសេវា ដែលមិនដូច ឬមិនប្រហាក់ប្រហែលនឹងទំនិញនិងសេវានៃម៉ាកល្បី ដែលបានចុះបញ្ជីរួច ហើយការប្រើប្រាស់នូវសញ្ញាទាក់ទងនឹងទំនិញ ឬសេវានោះ បញ្ជាក់នូវការ

ពាក់ព័ន្ធគ្នារវាងទំនិញ និងសេវានោះជាមួយនឹងម្ចាស់នៃម៉ាកល្បី ហើយដែលផលប្រយោជន៍នៃម្ចាស់ម៉ាកល្បី អាចនឹងត្រូវខូចខាតដោយការប្រើប្រាស់នោះ ។

**មាត្រា ២៦.-**

ការប្រើប្រាស់នូវសញ្ញាដែលដូច ឬប្រហាក់ប្រហែលនឹងម៉ាកល្បី ដែលមិនបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយគ្មានការយល់ព្រមពីម្ចាស់នៃម៉ាកល្បី ជាការរំលោភលើម៉ាកល្បីនោះ ប្រសិនបើសញ្ញានោះត្រូវបានប្រើប្រាស់ទាក់ទងទៅនឹងទំនិញ ឬសេវាដូច ឬប្រហាក់ប្រហែលនឹងទំនិញ ឬសេវានៃម៉ាកល្បីនោះ ។

**មាត្រា ២៧.-**

តាមសំណើរបស់ម្ចាស់ម៉ាក ឬអ្នកទទួលអាជ្ញាប័ណ្ណ តុលាការ អាចចេញនូវសេចក្តីសម្រេចបណ្តោះអាសន្នមួយ ដើម្បីទប់ស្កាត់ការរំលោភ ការដែលនឹងមានការរំលោភ ឬទង្វើដែលមិនស្របច្បាប់ដូចមានចែងក្នុងមាត្រា ២១ មាត្រា ២២ និងមាត្រា ២៣ និងសម្រេចឱ្យសងការខូចខាត ហើយផ្តល់នូវដំណោះស្រាយផ្សេងៗ ដែលមានចែងក្នុងច្បាប់ជាធរមាន ។ ប្រសិនបើអ្នកទទួលអាជ្ញាប័ណ្ណបានស្នើទៅម្ចាស់ម៉ាកឱ្យប្តឹងទៅតុលាការ ដើម្បីឱ្យជួសជុលនូវសំណងដ៏ជាក់លាក់មួយ ប៉ុន្តែបើម្ចាស់ម៉ាក បានបដិសេធ ឬខកខានមិនបានធ្វើតាម អ្នកទទួលអាជ្ញាប័ណ្ណអាចប្តឹងទៅតុលាការដោយផ្ទាល់បាន ។

**មាត្រា ២៨.-**

តាមសំណើរបស់អាជ្ញាធរមានសមត្ថកិច្ចណាមួយ ឬជនណាមួយដែលមានការពាក់ព័ន្ធដូចជា សមាគម ឬសហជីពនៃផលិតករ ឧស្សាហករ ឬពាណិជ្ជករ តុលាការអាចសំរេចឱ្យមានការជួសជុលសំណង ចំពោះករណីនៃការប្រកួតប្រជែងមិនស្មោះត្រង់ ដូចមានចែងនៅក្នុងមាត្រា ២២ និងមាត្រា ២៣ ។

## ជំពូកទី ៩
## វិធានការបណ្តោះអាសន្ន

**មាត្រា ២៩.-**

តាមសំណើរបស់អ្នកប្តឹង តុលាការមានអំណាចដាក់ចេញនូវវិធានការបណ្តោះអាសន្នជាបន្ទាន់ និងមានប្រសិទ្ធភាព ដើម្បីទប់ស្កាត់ការរំលោភ ការរំលោភដែលប្រុងនឹងកើតមាន ឬរក្សាទុកនូវភ័ស្តុតាងដែលពាក់ព័ន្ធ ។

**មាត្រា ៣០.-**

នៅពេលចាំបាច់ ជាពិសេសនៅពេលការយឺតយ៉ាវ អាចបណ្តាលឱ្យមានភាពអន្តរាយ ដែលមិនអាចជួសជុលបាន ចំពោះម្ចាស់សិទ្ធិ ឬនៅពេលដែលភ័ស្តុតាងអាចនឹងត្រូវបំផ្លាញ តុលាការអាចដាក់ចេញនូវវិធានការបណ្តោះអាសន្ន ប្រសិនបើដើមចោទផ្តល់នូវ :

ក- ភ័ស្តុតាងត្រឹមត្រូវដែលមាន ដែលអាចធ្វើឱ្យតុលាការយល់ស្របក្នុងកម្រិតមួយគ្រប់គ្រាន់ សម្រាប់សន្និដ្ឋានបញ្ជាក់ថា ដើមចោទ គឺជាម្ចាស់ពិតប្រាកដ ហើយសិទ្ធិរបស់អ្នកប្តឹងកំពុងត្រូវបានគេរំលោភ ឬការរំលោភនោះ អាចនឹងកើតមានឡើងក្នុងពេលឆាប់ៗ ។

ខ- ប្រាក់កក់ធានាដែលតម្រូវ ឬការធានាដែលមានតម្លៃ ស្មើនៃប្រាក់កក់គ្រប់គាន់ ក្នុងការការពារចុងចម្លើយ និងទប់ស្កាត់មិនឱ្យមានការរំលោភបំពាន ។ ប្រាក់កក់ធានានេះ ត្រូវស្ថិតនៅក្រោមការកំណត់របស់តុលាការ ។

**មាត្រា ៣១.-**

នៅពេលដែលវិធានការបណ្តោះអាសន្នត្រូវបានដាក់ចេញ តុលាការត្រូវជូនដំណឹងដល់ចុងចម្លើយអំពីសេចក្តីសម្រេចស្តីពីការចាត់វិធានការបណ្តោះអាសន្ននោះ ។

**មាត្រា ៣២.-**

នៅពេលដែលវិធានការបណ្តោះអាសន្ន ត្រូវបានដាក់ចេញ តាមមាត្រា ៣០ និងមាត្រា ៣១ ចុងចម្លើយអាចដាក់ពាក្យបណ្តឹងទៅតុលាការស្នើសុំឱ្យពិនិត្យវិធានការនោះឡើងវិញ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ ។ តុលាការត្រូវផ្តល់នូវឱកាសសវនាការឱ្យដល់ភាគីដែលពាក់ព័ន្ធ ហើយត្រូវពិនិត្យវិធានការនោះឡើងវិញ និងតម្កល់ កែតម្រូវ ឬលុបចោលនូវសេចក្តីសម្រេចរបស់ខ្លួន ក្នុងរយៈពេលមួយសមស្របតាមច្បាប់កំណត់ ។

**មាត្រា ៣៣.-**

ក្នុងករណីដើមចោទ នៅក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលដំណឹងអំពីការដាក់ចេញនូវវិធានការបណ្តោះអាសន្នហើយ ឬនៅក្នុងរយៈពេលមួយសមស្រប ដែលកំណត់ដោយតុលាការ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន មិនបានផ្តួចផ្តើមបន្តសំណុំរឿងបណ្តឹង ដែលនាំដល់សេចក្តី

សម្រេចអំពីអង្គសេចក្តីនៃករណី តុលាការត្រូវលុបនូវវិធានការបណ្តោះអាសន្ននោះចោលវិញ ដោយផ្អែកតាមសំណើរបស់ចុងចម្លើយ ។

## មាត្រា ៣៤.-

ក្នុងករណីដែលវិធានការបណ្តោះអាសន្នត្រូវបានលុបចោលវិញ ឬក្នុងករណីដែលតុលាការសម្រេចនូវអង្គសេចក្តីនៃករណីតាមដំណាក់ការជំរះក្តី ស្របតាមមាត្រា ៣៣ តាមការផ្តួចផ្តើមរបស់ដើមចោទ ប៉ុន្តែបែរជាគ្មានការរំលោភ ឬ ការគំរាមរំលោភវិញ ដោយយោងតាមសំណើរបស់ចុងចម្លើយ តុលាការត្រូវសម្រេចឱ្យដើមចោទសងឱ្យចុងចម្លើយនូវសំណងសមស្រប ចំពោះការខូចខាតនានា ដែលកើតមានឡើងដោយការអនុវត្តន៍នូវវិធានការបណ្តោះអាសន្ននោះ ។

# ជំពូកទី ១០
# វិធានការតាមមាត់ច្រកព្រំដែន

## មាត្រា ៣៥.-

ម្ចាស់ម៉ាកដែលបានចុះបញ្ជីហើយ អាចធ្វើពាក្យបណ្តឹងទៅរដ្ឋបាលគយ និងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ច ឬតុលាការ ឱ្យព្យួរទុកនូវការធ្វើបែបបទទំនិញណា ដែលសង្ស័យថា មានម៉ាកក្លែងក្លាយ ដោយបង្ហាញនូវភ័ស្តុតាងច្បាស់លាស់ថា គាត់ជាម្ចាស់នៃម៉ាក ដែលបានចុះបញ្ជី ។

## មាត្រា ៣៦.-

ពាក្យបណ្តឹងទាំងឡាយដែលបានលើកនៅក្នុងមាត្រា ៣៥ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ និងត្រូវអមដោយ :

ក- វិញ្ញាបនប័ត្រចុះបញ្ជីម៉ាក ។

ខ- សេចក្តីថ្លែងពីមូលហេតុនៃការប្តឹង និងជាពិសេស ភ័ស្តុតាងដំបូង ដែលបង្ហាញថា ទំនិញនោះពាក់ម៉ាកក្លែងក្លាយមែន ។

គ- ការរៀបរាប់ដ៏ល្អិតល្អន់ពីទំនិញដែលម៉ាករបស់វា ត្រូវបានប្រើប្រាស់ ព្រមទាំងគំរូនៃផលិតផលពិតប្រាកដផង ប្រសិនបើមានសំណូមពរ ។

ឃ- ឈ្មោះ និងអាស័យដ្ឋានរបស់អ្នកប្តឹង និងតំណាងរបស់គេ ដែលត្រូវរៀបរាប់ឱ្យបានសព្វគ្រប់តាមការកំណត់ ។

ង- លិខិតអនុញ្ញាតពីម្ចាស់ម៉ាក ដែលបានចុះបញ្ជី ប្រសិនបើពាក្យបណ្តឹងនោះត្រូវបានដាក់ដោយតំណាងដែលទទួលសិទ្ធិ ។

ច- កម្រៃរដ្ឋបាល តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៣៧.-**

ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលនូវពាក្យបណ្តឹង តាមមាត្រា ៣៥ រដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងទៅអ្នកប្តឹងថា ពាក្យបណ្តឹងរបស់ខ្លួនត្រូវបានទទួលស្គាល់ថា ត្រឹមត្រូវ ឬ បដិសេធ ឬមួយរក្សាទុក សម្រាប់ពិចារណានៅពេលក្រោយ ។

**មាត្រា ៣៨.-**

រដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀត ដែលកំណត់ដោយអនុក្រឹត្យ មានសិទ្ធិស្នើឱ្យអ្នកប្តឹងបង់ប្រាក់ធានា ឬតម្រូវឱ្យមានការធានា ដែលមានតំលៃស្មើនៃប្រាក់កក់គ្រប់គ្រាន់សម្រាប់ការពារ អ្នកនាំចូល អ្នកទទួល អ្នកនាំចេញ ឬម្ចាស់ទំនិញ និងអាជ្ញាធរមានសមត្ថកិច្ច ។ ប្រាក់ធានា ឬការធានាដែលមានតម្លៃស្មើនៃប្រាក់កក់នេះ ត្រូវបានកំណត់តាមរបៀប និងបែបបទមួយដែលមិនត្រូវឱ្យរាំងដល់ការអនុវត្តន៍នីតិវិធីនេះដោយមិនសមហេតុផល ។

**មាត្រា ៣៩.-**

ក្នុងពេលយល់ព្រមតាមពាក្យបណ្តឹងក្នុងមាត្រា ៣៥ រដ្ឋបាល គយនិងរដ្ឋាករ ត្រូវព្យួរទុកនូវការធ្វើបែបបទទំនិញ ដែលមានទាក់ទងទៅនឹងពាក្យបណ្តឹង ។ ការព្យួរទុកនេះ ត្រូវនៅជាធរមាន ក្នុងរយៈពេលដំបូង និងក្នុងរយៈពេលដែលបានពន្យារមិនលើសពី ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ។ រដ្ឋបាលគយនិងរដ្ឋាករ ត្រូវជូនពត៌មានភ្លាមទៅអ្នកនាំចូល និងអ្នកប្តឹង អំពីការព្យួរទុកនូវការធ្វើបែបបទទំនិញ ហើយត្រូវបញ្ជាក់ពីមូលហេតុនៃការព្យួរទុកនេះផង ។ រដ្ឋបាលគយនិងរដ្ឋាករ ត្រូវជូនដំណឹងពីឈ្មោះ និងអាស័យដ្ឋាននៃអ្នកប្តឹង ដល់អ្នកនាំចូលផងដែរ ។

## មាត្រា ៤០.-

ក្នុងរយៈពេលមិនហួសពី ១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពេលដែលអ្នកប្តឹងបានទទួលនូវពត៌មាន អំពីការឃាត់ទំនិញ ប្រសិនបើរដ្ឋបាលគយនិងរដ្ឋាករបានទទួលនូវពត៌មានថា ចំណាត់ការដែលនាំដល់ការសម្រេចនូវអង្គសេចក្តីនៃករណីមិនត្រូវបានផ្តួចផ្តើមឡើង ដោយភាគីមួយទៀតផ្សេងពីចុងចម្លើយ ឬថាអាជ្ញាធរដែលបានប្រគល់សិទ្ធិត្រឹមត្រូវ មិនបានអនុវត្តនូវវិធានការបណ្តោះអាសន្ន ដើម្បីពន្យារការដោះលែងទំនិញទេ ទំនិញនោះនឹងត្រូវដោះលែង តែក្នុងករណីដែលលក្ខខណ្ឌផ្សេងៗទៀត សម្រាប់ការនាំចូល ឬនាំចេញត្រូវបានគោរព ។

ក្នុងករណីសមស្រប រយៈពេលនេះអាចត្រូវពន្យារ (១០ ដប់) ថ្ងៃទៀតនៃថ្ងៃធ្វើការ ។

ប្រសិនបើចំណាត់ការ ដែលនាំឱ្យមានការសម្រេចនូវអង្គសេចក្តីនៃករណី ត្រូវបានផ្តួចផ្តើមឡើង ការពិនិត្យឡើងវិញ មានទាំងការធ្វើសវនាការផង ត្រូវបានរៀបចំឡើងតាមការស្នើសុំពីសំណាក់ចុងចម្លើយ ដើម្បីសម្រេចនៅក្នុងរយៈពេលមួយសមស្របថា តើវិធានការនេះត្រូវតម្កល់ កែតម្រូវ ឬលុបចោល ។

## មាត្រា ៤១.-

អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធ មានសិទ្ធិសម្រេចឱ្យអ្នកប្តឹងសងទៅម្ចាស់អ្នកនាំចូល អ្នកនាំចេញ និងអ្នកទទួលទំនិញ នូវសំណងសមស្រប ចំពោះការខូចខាតរបស់គេ ដែលបណ្តាលមកពីការឃាត់ទំនិញដោយមិនត្រឹមត្រូវ ឬការឃាត់ទំនិញដូចមានចែងក្នុងមាត្រា ៣៩ ។ ក្នុងករណីភាគីណាមួយ មិនយល់ព្រមតាមសេចក្តីសម្រេចនោះ ភាគីនោះមានសិទ្ធិប្តឹងទៅតុលាការ ។

## មាត្រា ៤២.-

រដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងៗទៀត អាចអនុញ្ញាតឱ្យម្ចាស់សិទ្ធិអ្នកនាំចូល ឬអ្នកនាំចេញ ពិនិត្យទំនិញដែលបានព្យួរទុកតាមបែបបទគយ ដូចមានចែងក្នុងមាត្រា ៣៩ និងដកយកនូវគំរូ ដើម្បីពិនិត្យសាកល្បង និងវិភាគក្នុងគោលបំណងបញ្ជាក់ឱ្យដឹងថា ទំនិញនោះពាក់ម៉ាកក្លែងក្លាយ ឬមិនក្លែងក្លាយ ។

នៅពេលដែលទំនិញត្រូវបានបញ្ជាក់ឱ្យដឹងថាជាទំនិញពាក់ ម៉ាកក្លែងក្លាយ រដ្ឋបាលគយ និងរដ្ឋាករអាច ជូនពត៌មានទៅម្ចាស់សិទ្ធិ នូវឈ្មោះ និងអាស័យដ្ឋាននៃអ្នកនាំចេញ អ្នកនាំចូល អ្នកទទួល និងបរិមាណ ទំនិញ ។ ដោយមិនឱ្យប៉ះពាល់ដល់ការការពារនូវពត៌មានសម្ងាត់រដ្ឋបាលគយនិងរដ្ឋាករ ឬអាជ្ញាធរ មានសមត្ថកិច្ចផ្សេងៗទៀត អាចផ្តល់ទៅឱ្យម្ចាស់ សិទ្ធិនូវច្បាប់ចម្លងនៃឯកសារទំនិញទាំងនោះ ឬនូវ ពត៌មានដែលមាន ឬឯកសារ ដែលទាក់ទងទៅនឹងការនាំចូល ឬនាំចេញ នូវទំនិញប្រហាក់ប្រហែល ពីមុន ដោយអ្នកនាំចូល ឬអ្នកនាំចេញដដែលនេះ តាមសំណូមពររបស់ម្ចាស់សិទ្ធិ ។

## មាត្រា ៤៣.-

រដ្ឋបាលគយនិងរដ្ឋាករ អាចព្យួរទុកនូវការធ្វើបែបបទទំនិញ ដែលពាក់ម៉ាកក្លែងក្លាយ ដែលខ្លួនបាន ពិនិត្យឃើញ មានភស្តុតាងជាលើកដំបូងថា កំពុងតែមាន ឬអាចនឹងមានការនាំចូលនូវទំនិញប្រភេទ នេះ ។

## មាត្រា ៤៤.-

រដ្ឋបាលគយនិងរដ្ឋាករត្រូវជូនពត៌មានភ្លាមទៅឱ្យម្ចាស់សិទ្ធិ អំពីទីកន្លែង និងថ្ងៃដែលព្យួរទុកនូវការធ្វើ បែបបទរបស់គយ ហើយរដ្ឋបាលគយនិងរដ្ឋាករ ក៏អាចស្នើឱ្យម្ចាស់សិទ្ធិផ្តល់នូវពត៌មានទាំងឡាយ ដែលអាចជាជំនួយក្នុងការអនុវត្តន៍នូវអំណាចរបស់ខ្លួនផងដែរ ។

## មាត្រា ៤៥.-

ដោយអនុលោមទៅនឹងបញ្ញត្តិដែលមានចែងក្នុងមាត្រា ៤២ នៃច្បាប់នេះ អាជ្ញាធរសាធារណៈ និង មន្ត្រីទទួលបន្ទុកត្រូវបានលើកលែង ពីការទទួលខុសត្រូវ ចំពោះវិធានការដោះស្រាយដោយសមស្រប នៅ ពេលដែលសកម្មភាពទាំងនោះ ត្រូវបានធ្វើ ឬមានបំណងនឹងធ្វើដោយស្មោះត្រង់ ។

## មាត្រា ៤៦.-

រដ្ឋបាលគយនិងរដ្ឋាករ និងអាជ្ញាធរមានសមត្ថកិច្ច តាមរយៈសេចក្តីសម្រេចរបស់តុលាការ មានសិទ្ធិ បំផ្លាញចោលនូវទំនិញ ដែលពាក់ម៉ាកក្លែងក្លាយនោះ ។ រដ្ឋបាលគយនិងរដ្ឋាករ មិនត្រូវអនុញ្ញាតឱ្យ ធ្វើការនាំចេញបន្តនូវទំនិញដែលមានម៉ាកក្លែងក្លាយ ឬដាក់ទំនិញនេះ ឱ្យនៅក្រោមនីតិវិធីផ្សេងទៀត របស់គយឡើយ ។

**មាត្រា ៤៧.-**

ទំនិញពាក់ម៉ាកក្លែងក្លាយដែលមិនមានលក្ខណៈពាណិជ្ជកម្ម ដែលនៅក្នុងអីវ៉ាន់ផ្ទាល់ខ្លួននៃអ្នកដំណើរ អាចស្ថិតនៅក្រៅការអនុវត្តន៍នៃច្បាប់នេះ ។

## ជំពូកទី ១១
## ការប្តូរម្ចាស់កម្មសិទ្ធិ

**មាត្រា ៤៨.-**

តាមសំណើរបស់ភាគីដែលពាក់ព័ន្ធមកមន្ត្រីកាន់កាប់បញ្ជី ការប្តូរម្ចាស់កម្មសិទ្ធិណាមួយនៃការចុះបញ្ជីម៉ាក ត្រូវសរសេរជាលាយល័ក្ខណ៍អក្សរ ហើយត្រូវបានចុះបញ្ជី និងចុះផ្សាយដោយមន្ត្រីកាន់កាប់បញ្ជី ។ ការប្តូរបែបនេះនឹងមិនមានអានុភាពចំពោះភាគីទីបីឡើយ រហូតដល់ការចុះបញ្ជីត្រូវបានធ្វើរួចជាស្ថាពរ ។

**មាត្រា ៤៩.-**

ការប្តូរម្ចាស់កម្មសិទ្ធិណាមួយនៃការចុះបញ្ជីម៉ាកសមូហភាព តម្រូវឱ្យមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មជាមុន ។

**មាត្រា ៥០.-**

ការប្តូរម្ចាស់កម្មសិទ្ធិណាមួយនៃពាណិជ្ជនាម ត្រូវធ្វើឡើង ដោយការផ្ទេរសហគ្រាសទាំងមូល ឬមួយផ្នែក ហើយត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ។

**មាត្រា ៥១.-**

ការប្តូរម្ចាស់កម្មសិទ្ធិនៃការចុះបញ្ជីម៉ាក ត្រូវចាត់ទុកជាមោឃៈ ប្រសិនបើម៉ាកនោះទំនងជាមានលក្ខណៈបោកបញ្ឆោត ឬបណ្តាលឱ្យមានការភ័ន្តច្រឡំ ជាពិសេសចំពោះប្រភេទ ប្រភពដើម ដំណើរការ ផលិតកម្ម ចរិតលក្ខណៈ ភាពសមស្រប ដើម្បីគោលបំណងនៃទំនិញ ឬសេវា ដែលម៉ាកនោះ បម្រុងប្រើប្រាស់ ឬកំពុងប្រើប្រាស់ ។

**មាត្រា ៥២.-**

កិច្ចសន្យាអាជ្ញាប័ណ្ណណាមួយពាក់ព័ន្ធនឹងម៉ាក ដែលបានចុះបញ្ជីរួចហើយ ឬពាក្យស្នើសុំទទួលស្គាល់កិច្ចសន្យា ត្រូវដាក់ជូនមន្ត្រីកាន់កាប់បញ្ជី ដែលត្រូវរក្សាការសម្ងាត់ ចំពោះខ្លឹមសារនៃកិច្ចសន្យានោះ ប៉ុន្តែត្រូវចុះបញ្ជី និងចុះផ្សាយនូវពត៌មានដែលពាក់ព័ន្ធ ។ កិច្ចសន្យាអាជ្ញាប័ណ្ណនឹងមិនមានអានុភាពចំពោះភាគីទីបីឡើយ រហូតដល់ការចុះបញ្ជីនោះ ត្រូវបានធ្វើរួចជាស្ថាពរ ។

## ជំពូកទី ១២
## ការកាន់កាប់បញ្ជីម៉ាក

**មាត្រា ៥៣.-**

ក្រសួងពាណិជ្ជកម្មមានតួនាទីបំពេញភារកិច្ច ដែលទាក់ទងទៅនឹងនីតិវិធី ដើម្បីធ្វើការចុះបញ្ជីម៉ាក និងដើម្បីធ្វើការគ្រប់គ្រងម៉ាក ដែលបានចុះបញ្ជីរួចហើយ ដូចបានបញ្ជាក់នៅក្នុងច្បាប់នេះ និងនៅក្នុងបទបញ្ជាទាំងឡាយ ។

